ធរណីមាត្រក្នុងប្លង់

ធរណីមាត្រក្នុងប្លង់

៣២ ទ្រឹស្តីបទ

៣៣ លំហាត់

សម្រាប់

- អ្នកសិក្សាទូទៅ
- ត្រៀមប្រឡងសិស្សពូកែ



រៀបរៀងដោយ ងា ពិសិដ្ឋ

ធរណីមាត្រក្នុងប្លង់

ដោយ ជា ពិសិដ្ឋ

អារម្ភកថា

សួស្តីប្រិយមិត្តអ្នកអានដែលកំពុងតែកាន់សៀវភៅធរណីមាត្រក្នុងប្លង់មួយក្បាលនេះ ។ សៀវភៅនេះត្រូវបានរៀបរៀងឡើងក្នុងគោលបំណងផ្តល់ជាឯកសារពិគ្រោះសម្រាប់ធ្វើការសិក្សាស្រាវជ្រាវបន្ថែមលើផ្នែកធរណីមាត្រក្នុងប្លង់ ។ បុព្វហេតុដែលធ្វើឲ្យសៀវភៅមួយក្បាលនេះលេចរូបរាងឡើងគឺដោយសារពួកយើងសង្កេតឃើញថាក្នុងស្រុកយើងមិនសូវមានអ្នកសរសេរចំណេះដឹងផ្នែកធរណីមាត្រនេះផ្សព្វផ្សាយឲ្យបានទូលំទូលាយនៅឡើយទេ ។ មួយវិញទៀតសិស្សភាគច្រើនយល់ឃើញថា ធរណីមាត្រជាផ្នែកមួយដ៏ពិបាកក្នុងគណិតវិទ្យា ។ ក្រោយពីការសិក្សាស្វែងយល់មួយចំនួនមកយើងបានរកឃើញថាផ្នែកមួយដែលធ្វើឲ្យការពិបាកនេះកើតមានឡើង គឺកង្វះឯកសារក្នុងការស្រាវជ្រាវបន្ថែម ។

សៀវភៅនេះត្រូវបានចែកចេញជាបីជំពូក គឺ **ជំពូក I (ទ្រឹស្តីបទ-សម្រាយបញ្ជាក់) ជំពូក II (ប្រធានលំហាត់) និងជំពូក III (លំហាត់-ដំណោះស្រាយ)**។ ក្នុងជំពូក I ពួកយើងបានចងក្រងនូវទ្រឹស្តីបទចំនួន ៣២ ទ្រឹស្តីបទព្រមទាំងមានការស្រាយបញ្ជាក់យ៉ាងក្បោះក្បាយដើម្បីឲ្យមិត្តអ្នកអានកាន់តែមានការអភិវឌ្ឍបន្ថែមក្នុងការស្រាយបញ្ជាក់នូវបញ្ហា។ លើសពីនេះទៅទៀតពួកយើងបានលើកយកឧទាហរណ៍មួយចំនួនមកបកស្រាយពីអត្ថន័យនៃទ្រឹស្តីបទបន្ថែមក្នុងគោលបំណងឲ្យមិត្តអ្នកអានកាន់តែយល់ស៊ីជម្រៅទៅលើទ្រឹស្តីបទទាំងនោះ។ ចំណែកឯក្នុងជំពូក II វិញយើងបានដកស្រង់នូវបញ្ហាធរណីមាត្រចេញពីបណ្តាការប្រឡងនានាដើម្បីដាក់ជាបញ្ហាឲ្យមិត្តអ្នកអានសាកល្បងដោះស្រាយតាមរយៈចំណេះដឹងដែលបានរៀនក្នុងជំពូកទ្រឹស្តីបទ-សម្រាយបញ្ជាក់។ ក្នុងជំពូកនេះ មិត្តអ្នកអានគួរតែសាកល្បងគិតលំហាត់ទាំងនោះឲ្យបានច្រើនជាមុនសិនមុននឹងសិក្សាជំពូក ៣ នៃសៀវភៅនេះ។ ផ្នែកចុងក្រោយនៃសៀវភៅនេះគឺ ជំពូក III ដែលផ្តោតទៅលើលំហាត់ និង ដំណោះស្រាយ ។ ក្នុងផ្នែកនេះយើងបានលើកយកលំហាត់ដែលបានដាក់ឲ្យមិត្តអ្នកអានដោះស្រាយក្នុងជំពូក II មកធ្វើការបកស្រាយយ៉ាងក្បោះក្បាយសម្រាប់ជាទុនដល់មិត្តអ្នកអានក្នុងការដោះស្រាយបញ្ហាធរណីមាត្រក្នុងប្លង់ ។ សូមចងចាំថាទោះបីជាអ្នកមិនអាចដោះស្រាយ រឺស្រាយបញ្ជាក់នូវបញ្ហាមួយចំនួនបានក៏ដោយក៏អ្នកនៅតែទទួលបានចំណេះដឹងដែរ

នៅពេលដែលអ្នកព្យាយាមគិតលំហាត់ទាំងនោះ ។
ពួកយើងគិតថាមានមនុស្សតិចអ្នកណាស់ដែលអាចដោះស្រាយបញ្ហាក្នុងសៀវភៅនេះបានទាំងអស់ដោយមិនមើលចម្លើយសោះ។ ហេតុនេះទោះបីជាអ្នកមិនអាចដោះស្រាយបញ្ហាបានទាំងអស់ក៏ដោយ សូមកុំអស់សង្ឃឹម ។ សូមព្យាយាមប្រឹងប្រែងបន្ថែម ។
សូមយកសៀវភៅមួយក្បាលនេះធ្វើជាមិត្តរបស់អ្នកចុះ ។

ជាចុងក្រោយពួកយើងមានតែការជូនពរដល់មិត្តអ្នកអានឲ្យជួបប្រទះតែសំណាងល្អ សុខភាពល្អ និង ទទួលបានជោគជ័យលើការសិក្សា និង ការងារ ។
ក្នុងនាមជាអ្នករៀបរៀងសៀវភៅមួយក្បាលនេះពួកយើងក៏សូមអភ័យទោសផងដែរសម្រាប់កំហុសឆ្គងបច្ចេកទេសដែលកើតមានដោយអចេតនា ។

ភ្នំពេញ ថ្ងៃទី ០១ ខែកក្កដា ឆ្នាំ ២០១៧

សេចក្តីថ្លែងអំណរគុណ

សៀវភៅនេះអាចលេចចេញជារូបរាងបានក៏ដោយសារតែមានការជួយគាំទ្រពីមជ្ឈដ្ឋានជុំវិញខ្លួនរបស់ពួកយើងទាំងអស់គ្នា។ ពួកយើងគ្មានអ្វីក្រៅពីការអរគុណដោយទឹកចិត្តស្មោះសរចំពោះលោកទាំងអស់ឡើយ។ ជាដំបូងពួកយើងសូមអរគុណដល់លោកឪពុក អ្នកម្ដាយដែលបានផ្តល់កំណើតដល់ពួកយើងព្រមទាំងចិញ្ចឹមបីបាច់ថែរក្សាទាំងរូបរាងកាយ និងផ្លូវចិត្ត។ ពួកយើងអាចទទួលបានចំណេះដឹងមកសរសេរសៀវភៅមួយក្បាលនេះ ក៏ដោយសារតែពួកគាត់បានខិតខំប្រឹងប្រែងរកប្រាក់ដើម្បីឲ្យពួកយើងបានសិក្សារៀនសូត្រ ។ ពាក្យម៉ែមួយឃ្លាដែលធ្វើឲ្យកូនចងចាំជានិច្ចគឺ ម៉ែមិនពូកែដូចគេទេតែម៉ែនឹងព្យាយាមចិញ្ចឹមកូនឲ្យបានរស់ដូចគេដូចឯង។ ពាក្យនេះបានអង្រួនចិត្តពួកកូនខ្លាំងណាស់។ ពាក្យនេះធ្វើឲ្យកូនមានចិត្តអាណិតម៉ែខ្លាំងណាស់។ វាគឺជាឃ្លាដែលបង្កប់ដោយអត្ថន័យយ៉ាងជ្រាលជ្រៅពីការស្រលាញ់របស់ម៉ែមកលើកូន។ កូនក៏សូមអភ័យទោសរាល់ទង្វើ រឺ ពាក្យសំដីលើសលួសទាំងអស់លើអ្នកមានគុណ ។

លើសពីនេះពួកយើងក៏សូមអរគុណផងដែរ ចំពោះលោកគ្រូអ្នកគ្រូដែលបានបង្ហាត់បង្រៀនពួកយើងតាំងពីបឋមសិក្សារហូតដល់ការសិក្សានៅវិទ្យាស្ថានជាតិអប់រំជាពិសេសគឺលោកគ្រូ ថៃ ហេង លោកគ្រូ ចាន់ រ៉ាដា លោកគ្រូ ហួត សុខលឿន លោកគ្រូ ឃី មឿយ និង លោកគ្រូស៊ឹម វិសុទ្ធ។ លោកគ្រូបានបង្ហាត់បង្រៀនដល់ពួកយើងអស់ពីកម្លាំងកាយចិត្តដោយមិនខ្លាចនឿយហត់ ។

ជាចុងបញ្ចប់ពួកយើងខ្ញុំជាអ្នករៀបរៀងសៀវភៅមួយក្បាលនេះសូមជូនពរឲ្យលោកជួបប្រទះតែសំណាងល្អ សុខភាពល្អ និង ជោគជ័យក្នុងការងារ។

ភ្នំពេញ ថ្ងៃទី០១ ខែកក្កដា ឆ្នាំ ២០១៧

ពីអ្នករៀបរៀង ជា ពិសិដ្ឋ

មាតិកា

ជំពូក I

ទ្រឹស្តីបទ និង សម្រាយបញ្ជាក់

1 ច្បាប់អង្កត់ទ្រូងកែងគ្នា

គេឲ្យអង្កត់ពីរ $[AC]$ និង $[BD]$ ។ យើងបាន $[AC]$ កែងនឹង $[BD]$ លុះត្រាតែ $AB^2 + CD^2 = DA^2 + BC^2$ ។

សម្រាយ



យក X និង Y ជាចំណោលកែងនៃ D និង B លើអង្កត់ទ្រូង $[AC]$ រៀងគ្នា

តាមទ្រឹស្តីបទពីតាគ័រយើងបាន

$$\begin{aligned}
AB^2 &= BY^2 + AY^2 \\
BC^2 &= BY^2 + CY^2 \\
CD^2 &= DX^2 + CX^2 \\
DA^2 &= AX^2 + DX^2
\end{aligned}$$

នោះ

$$\begin{aligned}
BC^2 + DA^2 - AB^2 - CD^2 &= BY^2 + CY^2 + AX^2 + DX^2 - BY^2 - AY^2 - DX^2 - CX^2 \\
&= AX^2 - CX^2 + CY^2 - YA^2 \\
&= (AX^2 - YA^2) + (CY^2 - CX^2) \\
&= (AX - AY)(AX + AY) + (CY - CX)(CY + CX) \\
&= XY(AX + AY) + XY(CX + CY) \\
&= XY(AX + CX + AY + CY) \\
&= 2AC \times XY
\end{aligned}$$

ហេតុនេះ $[AC] \perp [BD]$ លុះត្រាតែ $XY = 0 \Leftrightarrow AB^2 + CD^2 = DA^2 + BC^2$

2 ទ្រឹស្តីបទចំណោលកែង

គេឲ្យត្រីកោណ ABC មួយមានរង្វាស់ជ្រុង $BC = a, CA = b$ និង $AB = c$ ។ គេបាន

$$\begin{aligned}
a &= b\cos C + c\cos B \\
b &= c\cos A + a\cos C \\
c &= a\cos B + b\cos A
\end{aligned}$$

សម្រាយ



យើងមាន $a = BC = BH + HC$ ដោយ $\cos B = \dfrac{BH}{c} \Rightarrow BH = c\cos B$
ដូចគ្នាដែរ $HC = b\cos C$ នោះ $a = b\cos C + c\cos B$
ស្រាយដូចគ្នាយើងបាន $b = c\cos A + a\cos C$ និង $c = a\cos B + b\cos A$

3 ទ្រឹស្តីបទកូស៊ីនុស

ក្នុងត្រីកោណ ABC មួយគេបាន

$$a^2 = b^2 + c^2 - 2bc\cos A$$
$$b^2 = c^2 + a^2 - 2ca\cos B$$
$$c^2 = a^2 + b^2 - 2ab\cos C$$

សម្រាយ

របៀបទី ១
តាមទ្រឹស្តីបទចំណោលកែង $a = b\cos C + c\cos B$
នោះ $a^2 = ab\cos C + ac\cos B$ (1)
ដូចគ្នាដែរ $-b^2 = -bc\cos A - ab\cos C$ (2)
និង $-c^2 = -ac\cos B - bc\ \cos A$ (3)
បូក (1),(2) និង (3) យើងបាន $a^2 - b^2 - c^2 = -2bc\cos A$
ដូចនេះ $a^2 = b^2 + c^2 - 2bc\cos A$
ស្រាយដូចគ្នាយើងបាន $b^2 = c^2 + a^2 - 2ca\cos B$ និង $c^2 = a^2 + b^2 - 2ab\cos C$

របៀបទី ២
យើងមាន $\overrightarrow{BC}=\overrightarrow{BA}+\overrightarrow{AC}$
នោះ

$$\begin{aligned}\overrightarrow{BC}^2 &= (\overrightarrow{BA}+\overrightarrow{AC})^2\\ &= \overrightarrow{BA}^2+2\overrightarrow{BA}\overrightarrow{AC}+\overrightarrow{CA}^2\\ \Rightarrow a^2 &= c^2-2\overrightarrow{AB}\overrightarrow{AC}+b^2\\ &= b^2+c^2-2bc\cos A\end{aligned}$$

ដូចនេះ $a^2=b^2+c^2-2bc\cos A$
ស្រាយដូចគ្នាយើងបាន $b^2=c^2+a^2-2ca\cos B$ និង $c^2=a^2+b^2-2ab\cos C$
សម្គាល់

សូមមិត្តអ្នកអានសាកល្បងស្រាយតាមរបៀបផ្សេងទៀត ។

4 ទ្រឹស្តីបទស៊ីនុស

គេឲ្យត្រីកោណ ABC មួយ ហើយ R ជាកាំរង្វង់ចារឹកក្រៅត្រីកោណនេះ ។
គេបាន $\dfrac{a}{\sin A}=\dfrac{b}{\sin B}=\dfrac{c}{\sin C}=2R$ ។

សម្រាយ



យក $[AD]$ ជាអង្កត់ផ្ចិតនៃរង្វង់ នោះ $\triangle ACD$ ជាត្រីកោណចារឹកកន្លះរង្វង់
$\Rightarrow \triangle ACD$ ជាត្រីកោណកែងត្រង់ C
យើងបាន $\sin\angle ADC = \dfrac{AC}{AD} = \dfrac{b}{2R}$ ដោយ $\angle ADC = \angle ABC$ (មុំចារឹកស្កាត់ធ្នូរួម)
នោះ $\sin B = \dfrac{b}{2R} \Rightarrow \dfrac{b}{\sin B} = 2R$
ស្រាយដូចគ្នាយើងបាន $\dfrac{a}{\sin A} = 2R$ និង $\dfrac{c}{\sin C} = 2R$
ដូចនេះ $\dfrac{a}{\sin A} = \dfrac{b}{\sin B} = \dfrac{c}{\sin C} = 2R$

5 ទ្រឹស្តីបទ Stewart

គេឲ្យត្រីកោណ ABC មួយ និង D ជាចំណុចមួយនៅលើជ្រុង $[BC]$ ។ តាង $BC = a, CA = b, AB = c, AD = d, BD = n$ និង $CD = m$ ។ គេបាន $b^2n + c^2m = a(d^2 + mn)$ ។

សម្រាយ



បង្ហាញថា $b^2n + c^2m = a(d^2 + mn)$
តាមទ្រឹស្តីបទកូស៊ីនុសយើងបាន $c^2 = d^2 + n^2 - 2nd\cos\angle ADB$
នោះ $c^2m = d^2m + mn^2 - 2mnd\cos\angle ADB$ (i)
និង $b^2 = d^2 + m^2 - 2md\cos\angle ADC$

ដោយ $\angle ADC + \angle ADB = \pi$ នោះ

$$\angle ADC = \pi - \angle ADB$$
$$\Rightarrow \cos\angle ADC = -\cos\angle ADB$$

គេបាន $b^2 = d^2 + m^2 + 2md\cos\angle ADB$
នោះ $b^2 n = d^2 n + m^2 n + 2mnd\cos\angle ADB$(ii)
បូក (i) និង (ii) យើងបាន

$$\begin{aligned} c^2 m + b^2 n &= d^2 m + mn^2 + d^2 n + m^2 n \\ &= (m+n)d^2 + mn(m+n) \\ &= ad^2 + amn \end{aligned}$$

ដូចនេះ $b^2 n + c^2 m = a(d^2 + mn)$
ឧទាហរណ៍ ១
(រូបមន្តមេដ្យាន)
គេឲ្យ m_a ជារង្វាស់មេដ្យានដែលគូសចេញពីកំពូល A នៃត្រីកោណ ABC ។
បង្ហាញថា $m_a^2 = \dfrac{b^2 + c^2}{2} - \dfrac{a^2}{4}$ ។
សម្រាយ



តាមទ្រឹស្តីបទ Stewart យើងបាន

$$AB^2 \times MC + AC^2 \times BM = BC(AM^2 + BM \times MC)$$
$$\Rightarrow c^2\left(\frac{a}{2}\right) + b^2\left(\frac{a}{2}\right) = a\left[m_a^2 + \left(\frac{a}{2}\right)\left(\frac{a}{2}\right)\right]$$
$$\Rightarrow \frac{b^2 + c^2}{2} = m_a^2 + \frac{a^2}{4}$$

ដូចនេះ $m_a^2=\dfrac{b^2+c^2}{2}-\dfrac{a^2}{4}$
ឧទាហរណ៍ ២
(រូបមន្ត Leibniz)
គេឲ្យត្រីកោណ ABC មួយចារឹកក្នុងរង្វង់ផ្ចិត O និង កាំ R ។ យក G ជាទីប្រជុំទំងន់នៃត្រីកោណនេះ ។ បង្ហាញថា $OG^2=R^2-\dfrac{a^2+b^2+c^2}{9}$ ។

សម្រាយ



បង្ហាញថា $OG^2=R^2-\dfrac{a^2+b^2+c^2}{9}$
អនុវត្តទ្រឹស្តីបទ Stewart ចំពោះត្រីកោណ AOM
យើងបាន $OA^2\times GM+OM^2\times GA=AM(OG^2+GA\times GM)$
ដោយ $GM=\dfrac{1}{3}AM, GA=\dfrac{2}{3}AM, OM^2=OC^2-MC^2=R^2-\dfrac{a^2}{4}$
យើងបាន

$$R^2\left(\frac{1}{3}AM\right)+\frac{2}{3}AM\left(R^2-\frac{a^2}{4}\right)=AM\left[OG^2+\left(\frac{1}{3}AM\right)\left(\frac{2}{3}AM\right)\right]$$
$$\frac{R^2}{3}+\frac{2}{3}\left(R^2-\frac{a^2}{4}\right)=OG^2+\frac{2}{9}AM^2$$
$$\Rightarrow R^2-\frac{a^2}{6}=OG^2+\frac{2}{9}AM^2$$

ម្យ៉ាងទៀត $AM^2=\dfrac{b^2+c^2}{2}-\dfrac{a^2}{4}$ (រូបមន្តមេដ្យាន)

នោះ

$$
\begin{aligned}
R^2-\frac{a^2}{6} &= OG^2+\frac{2}{9}\left(\frac{b^2+c^2}{2}-\frac{a^2}{4}\right)\\
\Rightarrow OG^2 &= R^2-\frac{a^2}{6}-\frac{b^2+c^2}{9}+\frac{a^2}{18}\\
&= R^2-\frac{a^2+b^2+c^2}{9}
\end{aligned}
$$

ដូចនេះ $OG^2=R^2-\dfrac{a^2+b^2+c^2}{9}$

6 រូបមន្តក្រឡាផ្ទៃនៃត្រីកោណទី ១

គេឲ្យត្រីកោណ ABC មួយ ហើយ $[AH]$ ជាកម្ពស់នៃត្រីកោណនេះ ។ ក្រឡាផ្ទៃនៃត្រីកោណ ABC កំណត់ ដោយ $[ABC]=\dfrac{1}{2}AH\times BC$ ។



7 រូបមន្តក្រឡាផ្ទៃត្រីកោណទី ២

ក្រឡាផ្ទៃត្រីកោណ ABC កំណត់ដោយ $[ABC]=\dfrac{1}{2}bc\sin A=\dfrac{1}{2}ca\sin B=\dfrac{1}{2}ab\sin C$ ។

សម្រាយ

យើងមាន $[ABC]=\frac{1}{2}AH\times BC$
ដោយ $\sin B=\frac{AH}{AB}$ នោះ $AH=AB\sin B=c\sin B$
យើងបាន $[ABC]=\frac{1}{2}c\sin Ba=\frac{1}{2}ca\sin B$
ស្រាយដូចគ្នាយើងបាន $[ABC]=\frac{1}{2}bc\sin A=\frac{1}{2}ca\sin B=\frac{1}{2}ab\sin C$

8 រូបមន្តក្រឡាផ្ទៃត្រីកោណទី ៣

គេឲ្យត្រីកោណ ABC ចារឹកក្នុងរង្វង់ដែលមានប្រវែងកាំស្មើនឹង R ។ ក្រឡាផ្ទៃនៃត្រីកោណ ABC កំណត់ ដោយ $[ABC]=\frac{abc}{4R}$ ។

សម្រាយ

តាមទ្រឹស្តីបទស៊ីនុសគេបាន $\frac{a}{\sin A}=\frac{b}{\sin B}=\frac{c}{\sin C}=2R$ នោះ $\sin A=\frac{a}{2R}$
ដោយ $[ABC]=\frac{1}{2}bc\sin A$
$\Rightarrow [ABC]=\frac{1}{2}bc\left(\frac{a}{2R}\right)=\frac{abc}{4R}$
ដូចនេះ $[ABC]=\frac{abc}{4R}$

9 រូបមន្តក្រឡាផ្ទៃត្រីកោណទី ៤

យក r ជាកាំរង្វង់ចារឹកក្នុងត្រីកោណ ABC ។ គេបាន $[ABC]=pr$ ដែល $p=\frac{a+b+c}{2}$ ជាកន្លះបរិមាត្រ នៃត្រីកោណ ABC ។

សម្រាយ



យក I ជាផ្ចិតរង្វង់ចារឹកក្នុងត្រីកោណ ABC យើងបាន

$$\begin{aligned}[ABC] &= [ABI]+[IBC]+[AIC]\\ &= \frac{1}{2}ra+\frac{1}{2}rb+\frac{1}{2}rc\\ &= r\left(\frac{a+b+c}{2}\right)=pr\end{aligned}$$

10 រូបមន្តក្រឡាផ្ទៃនៃត្រីកោណទី ៥ (រូបមន្តហេរុង)

គេឲ្យត្រីកោណ ABC មួយមានប្រវែងជ្រុង $BC=a, CA=b$ និង $AB=c$ ហើយ $p=\dfrac{a+b+c}{2}$ ជាកន្លះបរិមាត្រនៃត្រីកោណនេះ ។ ក្រឡាផ្ទៃនៃត្រីកោណ ABC កំណត់ដោយ $[ABC]=\sqrt{p(p-a)(p-b)(p-c)}$ ។



សម្រាយ

យើងមាន $[ABC]=\dfrac{1}{2}bc\sin A$
ដោយ

$$\begin{aligned}
\sin^2 A &= 1-\cos^2 A\\
&= 1-\left(\frac{b^2+c^2-a^2}{2bc}\right)^2\\
&= \frac{(2bc)^2-(b^2+c^2-a^2)^2}{(2bc)^2}\\
&= \frac{(2bc+b^2+c^2-a^2)(2bc-b^2-c^2+a^2)}{(2bc)^2}\\
&= \frac{[(b+c)^2-a^2][a^2-(b-c)^2]}{(2bc)^2}\\
&= \frac{(b+c+a)(b+c-a)(a+b-c)(a-b+c)}{(2bc)^2}\\
&= \frac{16\left(\frac{a+b+c}{2}\right)\left(\frac{-a+b+c}{2}\right)\left(\frac{a-b+c}{2}\right)\left(\frac{a+b-c}{2}\right)}{4(bc)^2}
\end{aligned}$$

តាមបម្រាប់ $p=\dfrac{a+b+c}{2}$ នោះ $p-a=\dfrac{-a+b+c}{2}, p-b=\dfrac{a-b+c}{2}$ និង $p-c=\dfrac{a+b-c}{2}$
យើងបាន $\sin^2 A=\dfrac{4p(p-a)(p-b)(p-c)}{(bc)^2}$

ម៉្យាងទៀត A ជារង្វាស់មុំនៃត្រីកោណ នោះ $0 < A < \pi \Rightarrow \sin A > 0$

នោះ $\sin A = \dfrac{2\sqrt{p(p-a)(p-b)(p-c)}}{bc}$

យើងបាន $[ABC] = \dfrac{1}{2}bc \times \dfrac{2\sqrt{p(p-a)(p-b)(p-c)}}{bc}$

ដូចនេះ $[ABC] = \sqrt{p(p-a)(p-b)(p-c)}$

11 រូបមន្ត Brahmagupta

គេឲ្យចតុកោណចារឹកក្នុងរង្វង់ $ABCD$ មួយមានរង្វាស់ជ្រុង $AB = a, BC = b, CD = c$ និង $DA = d$ ហើយ $p = \dfrac{a+b+c+d}{2}$ ជាកន្លះបរិមាត្រនៃចតុកោណនេះ ។ ក្រឡាផ្ទៃនៃចតុកោណ $ABCD$ កំណត់ ដោយរូបមន្ត $S = \sqrt{(p-a)(p-b)(p-c)(p-d)}$ ។



សម្រាយ

បង្ហាញថា $S=\sqrt{(p-a)(p-b)(p-c)(p-d)}$
យើងមាន $S=[ABD]+[BCD]=\frac{1}{2}ad\sin A+\frac{1}{2}bc\sin C$
ដោយ $A+C=\pi$ ព្រោះ $ABCD$ ជាចតុកោណចារឹកក្នុងរង្វង់
នោះ $C=\pi-A\Rightarrow \sin C=\sin A$ និង $\cos C=-\cos A$
យើងបាន $S=\frac{1}{2}ad\sin A+\frac{1}{2}bc\sin A=\frac{1}{2}(ad+bc)\sin A$
តាមទ្រឹស្តីបទកូស៊ីនុស $BD^2=a^2+d^2-2ad\cos A$
និង $BD^2=b^2+c^2-2bc\cos C=b^2+c^2+2bc\cos A$
គេបាន

$$\begin{aligned}a^2+d^2-2ad\cos A&=b^2+c^2+2bc\cos A\\ \Rightarrow 2bc\cos A+2ad\cos A&=a^2+d^2-b^2-c^2\\ \Rightarrow 2(ad+bc)\cos A&=a^2+d^2-b^2-c^2\\ \Rightarrow \cos A&=\frac{a^2+d^2-b^2-c^2}{2(ad+bc)}\end{aligned}$$

តាមរូបមន្ត $\sin^2 A+\cos^2 A=1\Rightarrow \sin^2 A=1-\cos^2 A$

នោះ

$$\begin{aligned}\sin^2 A &= 1-\left[\frac{a^2+d^2-b^2-c^2}{2(ad+bc)}\right]^2\\ &= \frac{[2(ad+bc)]^2-(a^2+d^2-b^2-c^2)^2}{[2(ad+bc)]^2}\\ &= \frac{[2(ad+bc)+a^2+d^2-b^2-c^2][2(ad+bc)-a^2-d^2+b^2+c^2]}{[2(ad+bc)]^2}\\ &= \frac{[(a+d)^2-(b-c)^2][(b+c)^2-(a-d)^2]}{[2(ad+bc)]^2}\end{aligned}$$

$$\begin{aligned}&= \frac{(a+b-c+d)(a-b+c+d)(a+b+c-d)(-a+b+c+d)}{[2(ad+bc)]^2}\\ &= \frac{16\left(\frac{a+b-c+d}{2}\right)\left(\frac{a-b+c+d}{2}\right)\left(\frac{a+b+c-d}{2}\right)\left(\frac{-a+b+c+d}{2}\right)}{4(ad+bc)^2}\end{aligned}$$

ម៉្យាងទៀត $p=\dfrac{a+b+c+d}{2}\Rightarrow p-a=\dfrac{-a+b+c+d}{2}, p-b=\dfrac{a-b+c+d}{2}$
$, p-c=\dfrac{a+b-c+d}{2}$ និង $p-d=\dfrac{a+b+c-d}{2}$
យើងបាន $\sin^2 A=\dfrac{4(p-a)(p-b)(p-c)(p-d)}{(ad+bc)^2}$
តែ $A+C=\pi$ នោះ $0<A<\pi\Rightarrow \sin A>0$
គេបាន $\sin A=\dfrac{2\sqrt{(p-a)(p-b)(p-c)(p-d)}}{ad+bc}$
នោះ $S=\dfrac{1}{2}(ad+bc)\times\dfrac{2\sqrt{(p-a)(p-b)(p-c)(p-d)}}{ad+bc}$
ដូចនេះ $S=\sqrt{(p-a)(p-b)(p-c)(p-d)}$

12 ទ្រឹស្តីបទកន្លះបន្ទាត់ពុះមុំ

យក $[AD]$ ជាកន្លះបន្ទាត់ពុះមុំនៃ $\angle A$ នៃត្រីកោណ ABC ។ គេបាន $\dfrac{AB}{BD}=\dfrac{AC}{CD}$ ។
សម្រាយ



របៀបទី ១

យក H_1 និង H_2 ជាចំណោលកែងនៃ D លើ $[AB]$ និង $[AC]$ ដូចរូប

នោះ $DH_1 = DH_2$

យើងបាន $[ABD] = \frac{1}{2}DH_1 \times AB$ និង $[ACD] = \frac{1}{2}DH_2 \times AC = \frac{1}{2}DH_1 \times AC$

នោះ $\frac{[ABD]}{[ACD]} = \frac{\frac{1}{2}DH_1 \times AB}{\frac{1}{2}DH_1 \times AC} = \frac{AB}{AC}$ (1)

ម៉្យាងទៀត ត្រីកោណ ABD និង ACD មានកម្ពស់រួម

នោះ $\frac{[ABD]}{[ACD]} = \frac{BD}{CD}$ (2)

តាម (1)និង (2) យើងបាន $\frac{AB}{AC} = \frac{BD}{CD} \Rightarrow \frac{AB}{BD} = \frac{AC}{CD}$



របៀបទី ២

យក B' និង C' ជាចំណោលកែងនៃ B និង C លើ $[AD]$ រៀងគ្នា យើងបាន

+ត្រីកោណកែង ABB' ដូចត្រីកោណកែង ACC'

នោះ $\frac{AB}{AC} = \frac{BB'}{CC'}$ (1)

+ត្រីកោណកែង $BB'D$ ដូចត្រីកោណកែង $CC'D$

នោះ $\frac{BB'}{CC'} = \frac{BD}{CD}$ (2)

តាម (1) និង (2) យើងបាន $\frac{AB}{AC} = \frac{BD}{CD}$

ដូចនេះ $\frac{AB}{BD} = \frac{AC}{CD}$



របៀបទី ៣

យក E ជាចំណុចប្រសព្វនៃបន្ទាត់កាត់តាម C ស្របនឹង (AB) និង កន្លះបន្ទាត់ $[AD)$

នោះ $\angle AEC = \angle EAB$ (មុំឆ្លាស់ក្នុង)

ដោយ $\angle EAB = \angle CAE \Rightarrow \angle AEC = \angle CAE$

នោះ ត្រីកោណ ACE ជាត្រីកោណសមបាតកំពូល C

វិបាក $AC = CE$

ម៉្យាងទៀត ត្រីកោណ ABD ដូចត្រីកោណ ECD នោះ $\frac{AB}{CE} = \frac{BD}{CD}$

$\Rightarrow \frac{AB}{AC} = \frac{BD}{CD}$

ដូចនេះ $\frac{AB}{BD} = \frac{AC}{CD}$

របៀបទី ៤

Lemma

យក B' និង C' ជាចំណុចនៅលើជ្រុង $[AC]$ និង $[AB]$ ដែល $[B'D]//[AB]$ និង $[C'D]//[AC]$

គេបាន $AB'DC'$ ជាចតុកោណស្មើ ។

សម្រាយ



យើងមាន $[B'D]//[AC']$ និង $[C'D]//[AB']$ នោះ $AB'DC'$ ជាប្រលេឡូក្រាម
ពិនិត្យក្នុងត្រីកោណ $AB'D$ និង $AC'D$ មាន
$\angle ADB' = \angle C'DA = \angle C'AD = \angle B'AD$
និង $[AD]$ ជាជ្រុងរួម
នោះ $\triangle AB'D \cong \triangle AC'D \Rightarrow B'D = DC'$
ហេតុនេះ $AB'DC'$ ជាចតុកោណស្មើ
តាមទ្រឹស្តីបទ $Thales$ យើងបាន
$\dfrac{B'D}{AB} = \dfrac{CD}{BC}$ (1)
$\dfrac{C'D}{AC} = \dfrac{BD}{BC}$ (2)
ធ្វើផលធៀបរវាង (2) និង (1) យើងបាន $\dfrac{AB}{AC} = \dfrac{BD}{CD}$
ឧទាហរណ៍
គេឲ្យត្រីកោណ ABC មួយកែងត្រង់ B ដែលមាន $[CI)$ ជាកន្លះបន្ទាត់ពុះមុំ C ។ បើ $IB = 1, BC = 3$ ហើយ គេតាង $AI = x$ និង $AC = y$ ។ គណនា x និង y ។



ចម្លើយ
ត្រីកោណ ABC ជាត្រីកោណកែងត្រង់ B
តាមទ្រឹស្តីបទពីតាគ័រយើងបាន
$AB^2+BC^2=AC^2$
$(x+1)^2+3^2=y^2$
$x^2+2x+1+9=y^2$
$x^2-y^2+2x+10=0$ (1)
ម្យ៉ាងទៀត តាមទ្រឹស្តីបទកន្លះបន្ទាត់ពុះមុំយើងបាន $\dfrac{AC}{AI}=\dfrac{BC}{BI}\Rightarrow\dfrac{y}{x}=3\Rightarrow y=3x$
តាម (1) យើងបាន
$x^2-9x^2+2x+10=0$
$-8x^2+2x+10=0$
ដោយ $a+c=-8+10=2=b$ គេបាន $x=-1,x=-\dfrac{10}{-8}=\dfrac{5}{4}$
ដូចនេះ $x=\dfrac{5}{4}$ និង $y=\dfrac{15}{4}$

13 ប្រវែងអង្កត់ដែលចែកដោយកន្លះបន្ទាត់ពុះមុំ

គេឲ្យត្រីកោណ ABC មួយមាន $BC=a,CA=b$ និង $AB=c$ ហើយ $[AD)$ ជាកន្លះបន្ទាត់ពុះមុំក្នុងនៃ $\angle A$ ។ គណនា BD និង DC ។
សម្រាយ



គណនា BD និង DC
តាមទ្រឹស្តីបទកន្លះបន្ទាត់ពុះមុំយើងបាន $\frac{AB}{BD}=\frac{AC}{CD}$
នោះ $\frac{c}{BD}=\frac{b}{CD}=\frac{b+c}{BD+CD}=\frac{b+c}{BC}=\frac{b+c}{a}$
ចំពោះ $\frac{c}{BD}=\frac{b+c}{a}\Rightarrow BD=\frac{ca}{b+c}$
ចំពោះ $\frac{b}{CD}=\frac{b+c}{a}\Rightarrow CD=\frac{ab}{b+c}$
ដូចនេះ $BD=\frac{ca}{b+c}$ និង $CD=\frac{ab}{b+c}$

14 រូបមន្តមេដ្យាន

គេឲ្យត្រីកោណ ABC មានរង្វាស់ជ្រុង a,b និង c ។ យក m_a,m_b និង m_c ជាប្រវែងមេដ្យានដែលគូសចេញពីកំពូល A,B និងC រៀងគ្នា ។ គេបានរូបមន្ត
$m_a^2=\frac{b^2+c^2}{2}-\frac{a^2}{4}$
$m_b^2=\frac{c^2+a^2}{2}-\frac{b^2}{4}$
$m_c^2=\frac{a^2+b^2}{2}-\frac{c^2}{4}$ ។
សម្រាយ



បង្ហាញថា $m_a^2 = \dfrac{b^2+c^2}{2} - \dfrac{a^2}{4}$
យើងមាន $\overrightarrow{AB}+\overrightarrow{AC} = 2\overrightarrow{AM}$
នោះ

$$(\overrightarrow{AB}+\overrightarrow{AC})^2 = (2\overrightarrow{AM})^2$$
$$\Rightarrow AB^2+AC^2+2\overrightarrow{AB}\overrightarrow{AC} = 4AM^2$$
$$\Rightarrow AB^2+AC^2+2AB\times AC\cos A = 4AM^2$$

គេបាន $b^2+c^2+2bc\cos A = 4m_a^2$ ដោយ $\cos A = \dfrac{b^2+c^2-a^2}{2bc}$
យើងបាន $b^2+c^2+2bc\left(\dfrac{b^2+c^2-a^2}{2bc}\right) = 4m_a^2$
នោះ $b^2+c^2+b^2+c^2-a^2 = 4m_a^2$
$\Rightarrow 4m_a^2 = 2(b^2+c^2)-a^2$
$\Rightarrow m_a^2 = \dfrac{2(b^2+c^2)}{4} - \dfrac{a^2}{4}$
ដូចនេះ $m_a^2 = \dfrac{b^2+c^2}{2} - \dfrac{a^2}{4}$
ឧទាហរណ៍ ១
(ច្បាប់ប្រលេឡូក្រាម)
គេឲ្យ $ABCD$ ជាប្រលេឡូក្រាម ។ បង្ហាញថា $AC^2+BD^2 = 2(AB^2+AD^2)$ ។
សម្រាយ



យក O ជាចំណុចប្រសព្វនៃអង្កត់ទ្រូង $[AC]$ និង $[BD]$
គេបាន O ជាចំណុចកណ្តាលនៃ $[BD]$
នោះ $[OA]$ ជាមេដ្យាននៃត្រីកោណ ABD
តាមរូបមន្តមេដ្យានយើងបាន $OA^2 = \frac{AB^2+AD^2}{2} - \frac{BD^2}{4}$
ដោយ $OA = \frac{AC}{2}$ នោះ $\left(\frac{AC}{2}\right)^2 = \frac{AB^2+AD^2}{2} - \frac{BD^2}{4}$
គេបាន $\frac{AC^2}{4} = \frac{AB^2+AD^2}{2} - \frac{BD^2}{4} \Rightarrow AC^2 = 2(AB^2+AD^2) - BD^2$
ដូចនេះ $AC^2 + BD^2 = 2(AB^2+AD^2)$
ឧទាហរណ៍ ២
គេឲ្យ m_a, m_b, m_c និង h_a, h_b, h_c ជារង្វាស់មេដ្យាន និង កម្ពស់នៃត្រីកោណ ABC មួយ ។ បង្ហាញថា $(m_a^2+m_b^2+m_c^2)(h_a^2+h_b^2+h_c^2) \geq 27S^2$ ។

សម្រាយ

តាមរូបមន្តមេដ្យាន $m_a^2 = \frac{b^2+c^2}{2} - \frac{a^2}{4}, m_b^2 = \frac{c^2+a^2}{2} - \frac{b^2}{4}$ និង $m_c^2 = \frac{a^2+b^2}{2} - \frac{c^2}{4}$
យើងបាន $m_a^2+m_b^2+m_c^2 = \frac{3}{4}(a^2+b^2+c^2)$
តាមវិសមភាព *Cauchy* យើងបាន $m_a^2+m_b^2+m_c^2 \geq \frac{3}{4}\left(3\sqrt[3]{a^2b^2c^2}\right)$ (1)
ដោយ $S = \frac{1}{2}ah_a \Rightarrow h_a = \frac{2S}{a}$
ដូចគ្នាដែរ $h_b = \frac{2S}{b}$ និង $h_c = \frac{2S}{c}$
យើងបាន $h_a^2+h_b^2+h_c^2 = \frac{4S^2}{a^2} + \frac{4S^2}{b^2} + \frac{4S^2}{c^2} = 4S^2\left(\frac{1}{a^2}+\frac{1}{b^2}+\frac{1}{c^2}\right)$
តាមវិសមភាព *Cauchy* យើងបាន $h_a^2+h_b^2+h_c^2 \geq 4S^2\left(\frac{3}{\sqrt[3]{a^2b^2c^2}}\right) = \frac{12S^2}{\sqrt[3]{a^2b^2c^2}}$ (2)

គុណ (1) និង (2) យើងបាន

$$(m_a^2+m_b^2+m_c^2)(h_a^2+h_b^2+h_c^2) \geq \frac{3}{4}\left(3\sqrt[3]{a^2b^2c^2}\right)\left(\frac{12S^2}{\sqrt[3]{a^2b^2c^2}}\right) = 27S^2$$

ដូចនេះ $(m_a^2+m_b^2+m_c^2)(h_a^2+h_b^2+h_c^2) \geq 27S^2$

15 ទ្រឹស្តីបទ Viviani

គេឲ្យ ABC ជាត្រីកោណសម័ង្ស និង P ជាចំណុចមួយនៅក្នុងត្រីកោណនេះ ។ យក P_A, P_B និង P_C ជាចំណោលកែងនៃ P លើជ្រុង $[BC], [CA]$ និង $[AB]$ រៀងគ្នា ។
គេបាន $PP_A + PP_B + PP_C = h$ ដែល h ជាកម្ពស់នៃត្រីកោណ ABC ។
សម្រាយ



ភ្ជាប់ពី P ទៅកំពូល A, B និង C យើងបាន $[APB]+[BPC]+[APC]=[ABC]$

ដោយ $[APB] = \frac{1}{2}PP_C \times AB$

$[BPC] = \frac{1}{2}PP_A \times BC = \frac{1}{2}PP_A \times AB$

$[APC] = \frac{1}{2}PP_B \times CA = \frac{1}{2}PP_B \times AB$

$[ABC] = \frac{1}{2}h \times AB$ ព្រោះ ABC ជាត្រីកោណសម័ង្ស

នោះ $\frac{1}{2}PP_A \times AB + \frac{1}{2}PP_B \times AB + \frac{1}{2}PP_C \times AB = \frac{1}{2}h \times AB$

$\frac{1}{2}AB(PP_A + PP_B + PP_C) = \frac{1}{2}h \times AB$

ដូចនេះ $PP_A + PP_B + PP_C = h$

16 ទ្រឹស្តីបទ Steiner

ទ្រឹស្តីបទ

គេឲ្យត្រីកោណ ABC មួយ ហើយ M និង N ជាពីរចំណុចនៅលើអង្កត់ $[BC]$ ដែល $[AM]$ និង $[AN]$ ឆ្លុះគ្នាធៀបនឹងកន្លះបន្ទាត់ពុះមុំក្នុងនៃ $\angle BAC$ ។ គេបាន $\dfrac{CM\times CN}{BM\times BN}=\dfrac{AC^2}{AB^2}$ ។

សម្គាល់

$[AM]$ និង $[AN]$ ហៅថា Isogonal Cevian ។

សម្រាយ



អនុវត្តទ្រឹស្តីបទស៊ីនុស

ចំពោះត្រីកោណ ABM យើងបាន $\dfrac{AB}{\sin\angle AMB}=\dfrac{BM}{\sin\angle BAM}$

$\Rightarrow \dfrac{AB}{BM}=\dfrac{\sin\angle AMB}{\sin\angle BAM}$

ដូចគ្នាដែរ ចំពោះត្រីកោណ AMC យើងបាន $\dfrac{CM}{AC}=\dfrac{\sin\angle MAC}{\sin\angle AMC}$

ដោយ $\angle AMC=\pi-\angle AMB \Rightarrow \sin\angle AMC=\sin\angle AMB$

នោះ $\dfrac{CM}{AC}=\dfrac{\sin\angle MAC}{\sin\angle AMB}$

យើងបាន $\dfrac{AB}{BM}\times\dfrac{CM}{AC}=\dfrac{\sin\angle AMB}{\sin\angle BAM}\times\dfrac{\sin\angle MAC}{\sin\angle AMB}$

$\Rightarrow \dfrac{AB}{BM}\times\dfrac{CM}{AC}=\dfrac{\sin\angle MAC}{\sin\angle BAM}\ (1)$

ស្រាយដូចគ្នាចំពោះត្រីកោណ ACN និង ត្រីកោណ ANB

យើងបាន $\dfrac{AC}{CN}\times\dfrac{BN}{AB}=\dfrac{\sin\angle NAB}{\sin\angle CAN}$

រឺ $\dfrac{AB}{BN}\times\dfrac{CN}{AC}=\dfrac{\sin\angle CAN}{\sin\angle NAB}$

ម៉្យាងទៀត $[AM]$ និង $[AN]$ ឆ្លុះគ្នាធៀបនឹងកន្លះបន្ទាត់ពុះមុំក្នុងនៃ $\angle A$
នោះ $\angle CAN = \angle BAM$ និង $\angle NAB = \angle MAC$
នោះ $\dfrac{AB}{BN} \times \dfrac{CN}{AC} = \dfrac{\sin\angle BAM}{\sin\angle MAC}$ (2)
គុណ (1) និង (2) យើងបាន $\dfrac{AB^2}{AC^2} \times \dfrac{CM \times CN}{BM \times BN} = 1$
ដូចនេះ $\dfrac{CM \times CN}{BM \times BN} = \dfrac{AC^2}{AB^2}$

17 រូបមន្ត Leibniz

រូបមន្ត ១
គេឲ្យ G ជាទីប្រជុំទំងន់នៃត្រីកោណ ABC និង O ជាផ្ចិតរង្វង់ចារឹកក្រៅត្រីកោណ ABC ។ បង្ហាញថា $OG^2 = R^2 - \dfrac{a^2+b^2+c^2}{9}$ ។
សម្រាយ



ក្នុងត្រីកោណ AGO មាន $\cos\angle AGO = \dfrac{OG^2 + AG^2 - OA^2}{2OG \times GA}$ (1)
ក្នុងត្រីកោណ OGM មាន $\cos\angle OGM = \dfrac{OG^2 + GM^2 - OM^2}{2OG \times GM}$
ដោយ $\angle AGO + \angle OGM = \pi$
$\Rightarrow \angle OGM = \pi - \angle AGO$
$\Rightarrow \cos\angle OGM = -\cos\angle AGO$
$\Rightarrow -\cos AGO = \dfrac{OG^2 + GM^2 - OM^2}{2OG \times GM}$

$\Rightarrow \cos\angle AGO = -\dfrac{OG^2+GM^2-OM^2}{2OG\times GM}$ (2)

តាម (1) និង (2) យើងបាន $\dfrac{OG^2+AG^2-OA^2}{2OG\times AG} = -\dfrac{OG^2+GM^2-OM^2}{2OG\times GM}$

$\Rightarrow \dfrac{OG^2+AG^2-OA^2}{AG} = -\dfrac{OG^2+GM^2-OM^2}{GM}$

ដោយ $AG = \dfrac{2}{3}AM, GM = \dfrac{1}{3}AM, OM^2 = R^2 - \dfrac{a^2}{4}$ និង $AG = 2GM$

នោះ

$$\frac{OG^2+\frac{4}{9}AM^2-R^2}{2} = -OG^2-\frac{1}{9}AM^2+\left(R^2-\frac{a^2}{4}\right)$$

$$OG^2+\frac{4}{9}AM^2-R^2 = -2OG^2-\frac{2}{9}AM^2+2R^2-\frac{a^2}{2}$$

យើងបាន $3OG^2 = 3R^2-\dfrac{2}{3}AM^2-\dfrac{a^2}{2}$

ម៉្យាងទៀត $AM^2 = \dfrac{b^2+c^2}{2}-\dfrac{a^2}{4}$ (រូបមន្តមេដ្យាន)

នោះ

$$\begin{aligned}3OG^2 &= 3R^2-\frac{2}{3}\left(\frac{b^2+c^2}{2}-\frac{a^2}{4}\right)-\frac{a^2}{2}\\ &= 3R^2-\frac{b^2+c^2}{3}+\frac{a^2}{6}-\frac{a^2}{2}\\ &= 3R^2-\frac{a^2+b^2+c^2}{3}\end{aligned}$$

ដូចនេះ $OG^2 = R^2-\dfrac{a^2+b^2+c^2}{9}$

រូបមន្ត ២ (Generalization)

គេឲ្យ G ជាទីប្រជុំទំងន់នៃត្រីកោណ ABC និង P ជាចំណុចមួយនៅក្នុងប្លង់ ។

បង្ហាញថា $PA^2+PB^2+PC^2 = \dfrac{1}{3}(a^2+b^2+c^2)+3PG^2$ ។

សម្រាយ

បង្ហាញថា $PA^2+PB^2+PC^2 = \dfrac{1}{3}(a^2+b^2+c^2)+3PG^2$

ដោយ G ជាទីប្រជុំទំងន់នៃត្រីកោណ ABC នោះ $\overrightarrow{GA}+\overrightarrow{GB}+\overrightarrow{GC} = \overrightarrow{0}$

យើងមាន $\overrightarrow{PA} = \overrightarrow{PG}+\overrightarrow{GA}$

$\Rightarrow PA^2 = PG^2+GA^2+2\overrightarrow{PG}\overrightarrow{GA}$

ដូចគ្នាដែរ $PB^2 = PG^2+GB^2+2\overrightarrow{PG}\overrightarrow{GB}$

និង $PC^2 = PG^2 + GC^2 + 2\overrightarrow{PG}\overrightarrow{GC}$
បូកអង្គ និង អង្គយើងបាន

$$\begin{aligned}PA^2 + PB^2 + PC^2 &= 3PG^2 + GA^2 + GB^2 + GC^2 + 2\overrightarrow{PG}(\overrightarrow{GA} + \overrightarrow{GB} + \overrightarrow{GC})\\ &= 3PG^2 + GA^2 + GB^2 + GC^2\end{aligned}$$

ម៉្យាងទៀត $GA = \dfrac{2}{3}m_a \Rightarrow GA^2 = \dfrac{4}{9}m_a^2$
ដោយ $m_a^2 = \dfrac{b^2 + c^2}{2} - \dfrac{a^2}{4}$
$\Rightarrow GA^2 = \dfrac{4}{9}\left(\dfrac{b^2 + c^2}{2} - \dfrac{a^2}{4}\right) = \dfrac{2(b^2 + c^2)}{9} - \dfrac{a^2}{9}$
ដូចគ្នាដែរ $GB^2 = \dfrac{2(c^2 + a^2)}{9} - \dfrac{b^2}{9}$ និង $GC^2 = \dfrac{2(a^2 + b^2)}{9} - \dfrac{c^2}{9}$
នោះ

$$\begin{aligned}GA^2 + GB^2 + GC^2 &= \frac{4(a^2 + b^2 + c^2) - (a^2 + b^2 + c^2)}{9}\\ &= \frac{3(a^2 + b^2 + c^2)}{9}\\ &= \frac{a^2 + b^2 + c^2}{3}\end{aligned}$$

ដូចនេះ $PA^2 + PB^2 + PC^2 = \dfrac{1}{3}(a^2 + b^2 + c^2) + 3PG^2$

សម្គាល់

សូមមិត្តអ្នកអានសាកល្បងស្រាយរូបមន្ត ១ តាមវ៉ិចទ័រ ។

18 ទ្រឹស្តីបទ Carnot I

ទ្រឹស្តីបទ
គេមានត្រីកោណ ABC មួយ ហើយ $(l_1), (l_2)$ និង (l_3) កែងទៅនឹងជ្រុង $[BC], [CA]$ និង $[AB]$ ត្រង់ចំណុច A_1, B_1 និង C_1 រៀងគ្នា ។ គេបាន $(l_1), (l_2)$ និង (l_3) ប្រសព្វគ្នាត្រង់មួយចំណុច លុះត្រាតែ $A_1B^2 + C_1A^2 + B_1C^2 = A_1C^2 + C_1B^2 + B_1A^2$ ។
សម្រាយ



$\Rightarrow$ ឧបមាថាបន្ទាត់ $(l_1),(l_2)$ និង (l_3)ប្រសព្វគ្នាត្រង់ចំណុច M តែមួយ
យើងបាន
$A_1B^2 = BM^2 - MA_1^2$
$C_1A^2 = AM^2 - MC_1^2$
$B_1C^2 = CM^2 - MB_1^2$
នោះ $A_1B^2 + C_1A^2 + B_1C^2 = AM^2 + BM^2 + CM^2 - MA_1^2 - MB_1^2 - MC_1^2$ (i)
ម៉្យាងទៀត
$A_1C^2 = MC^2 - MA_1^2$
$C_1B^2 = MB^2 - MC_1^2$
$B_1A^2 = AM^2 - MB_1^2$
យើងបាន $A_1C^2 + C_1B^2 + B_1A^2 = AM^2 + BM^2 + CM^2 - MA_1^2 - MB_1^2 - MC_1^2$ (ii)
តាម (i) និង (ii) យើងបាន $A_1B^2 + C_1A^2 + B_1C^2 = A_1C^2 + C_1B^2 + B_1A^2$
$\Leftarrow$ ឧបមាថា $A_1B^2 + C_1A^2 + B_1C^2 = A_1C^2 + C_1B^2 + B_1A^2$ (iii)
យក N ជាចំណុចប្រសព្វនៃ (l_1) និង (l_2) ហើយ C_2 ជាចំណោលកែងនៃ N លើ $[AB]$
តាមសម្រាយខាងលើយើងបាន $A_1B^2 + C_2A^2 + B_1C^2 = A_1C^2 + C_2B^2 + B_1A^2$ (iv)
ដកអង្គ និង អង្គរវាង (iv) និង (iii) យើងបាន
$C_2A^2 - C_1A^2 = C_2B^2 - C_1B^2$
$C_1A^2 - BC_1^2 = C_2A^2 - BC_2^2$
$(C_1A + C_1B)(C_1A - C_1B) = (C_2A + C_2B)(C_2A - C_2B)$

$AB(C_1A - C_1B) = AB(C_2A - C_2B)$
$C_1A - C_1B = C_2A - C_2B$ នោះ C_1 និង C_2 ត្រួតស៊ីគ្នា
ដូចនេះ ទ្រឹស្តីបទត្រូវបានស្រាយបញ្ជាក់
ឧទាហរណ៍
(USAMO 1997)
គេឲ្យត្រីកោណ ABC មួយ ហើយ D, E និង F ជាចំណុចនៅលើមេដ្យាទ័រនៃជ្រុង $[BC], [CA]$ និង $[AB]$ រៀងគ្នា ។ បង្ហាញថា បន្ទាត់ដែលកាត់តាមកំពូល A, B និង C ហើយកែងទៅនឹង $[EF], [FD]$ និង $[DE]$ រៀងគ្នាប្រសព្វគ្នាត្រង់មួយចំណុច ។
សម្រាយ



យក A', B' និង C' ជាចំណោលកែងនៃ A, B និង C លើ $(FE), (FD)$ និង (DE) រៀងគ្នា
តាមទ្រឹស្តីបទពីតាគ័រយើងបាន

$$\begin{aligned} FA'^2 &= AF^2 - AA'^2 \\ &= AF^2 - (AE^2 - EA'^2) \\ \Rightarrow FA'^2 - EA'^2 &= AF^2 - AE^2 \end{aligned}$$

ដូចគ្នាដែរ $EC'^2 - DC'^2 = CE^2 - CD^2$ និង $DB'^2 - FB'^2 = BD^2 - BF^2$

យើងបាន

$$
\begin{aligned}
FA'^2 - EA'^2 + EC'^2 - DC'^2 + DB'^2 - FB'^2 &= AF^2 - AE^2 + CE^2 - CD^2 + BD^2 - BF^2 \\
&= (AF^2 - BF^2) + (CE^2 - AE^2) + (BD^2 - CD^2) \\
&= (AF^2 - AF^2) + (AE^2 - AE^2) + (CD^2 - CD^2)
\end{aligned}
$$

$\Rightarrow FA'^2 + EC'^2 + DB'^2 = EA'^2 + DC'^2 + FB'^2$
តាមទ្រឹស្តីបទ $CarnotI$ បន្ទាត់ដែលកាត់តាមកំពូល A,B និង C ហើយកែងទៅនឹង $[EF],[FD]$ និង $[DE]$ រៀងគ្នាប្រសព្វគ្នាត្រង់មួយចំណុច ។

19 កាំរង្វង់ចារឹកក្នុង និង ចារឹកក្រៅនៃត្រីកោណមួយ

យើងមាន $S = \sqrt{p(p-a)(p-b)(p-c)}$
ដោយ $S = pr$
នោះ

$$
\begin{aligned}
pr &= \sqrt{p(p-a)(p-b)(p-c)} \\
\Rightarrow r &= \sqrt{\frac{p(p-a)(p-b)(p-c)}{p^2}} \\
&= \sqrt{\frac{(p-a)(p-b)(p-c)}{p}}
\end{aligned}
$$

ម៉្យាងទៀត $S = \dfrac{abc}{4R}$
យើងបាន $\dfrac{abc}{4R} = \sqrt{p(p-a)(p-b)(p-c)}$
$\Rightarrow R = \dfrac{abc}{4\sqrt{p(p-a)(p-b)(p-c)}}$
ជាទូទៅ
បើ a, b និង c ជារង្វាស់ជ្រុងនៃត្រីកោណមួយ ហើយ R,r ជាកាំនៃរង្វង់ចារឹកក្រៅ និង ចារឹកក្នុងនៃត្រីកោណរៀងគ្នា យើងបាន $r = \sqrt{\dfrac{(p-a)(p-b)(p-c)}{p}}$ និង $R = \dfrac{abc}{4\sqrt{p(p-a)(p-b)(p-c)}}$ ។

20 ចម្ងាយពីផ្ចិតរង្វង់ចារឹកក្នុងត្រីកោណទៅកំពូលនៃត្រីកោណ

ទ្រឹស្តីបទ

គេឲ្យ ABC ជាត្រីកោណមួយដែលមានរង្វាស់ជ្រុង $BC = a, CA = b$ និង $AB = c$ ។ យក I ជាផ្ចិតរង្វង់ចារឹកក្នុងនៃត្រីកោណ ABC ។

គេបាន $IA = \sqrt{\frac{(p-a)bc}{p}}, IB = \sqrt{\frac{(p-b)ca}{p}}$ និង $IC = \sqrt{\frac{(p-c)ab}{p}}$ ។

សម្រាយ



បង្ហាញថា $IA = \sqrt{\frac{(p-a)bc}{p}}$

ក្នុងត្រីកោណកែង ADI មាន

$$\begin{aligned} AI^2 &= ID^2 + DA^2 \\ &= r^2 + (p-a)^2 \end{aligned}$$

ដោយ $r = \sqrt{\frac{(p-a)(p-b)(p-c)}{p}}$

យើងបាន

$$\begin{aligned} AI^2 &= \sqrt{\frac{(p-a)(p-b)(p-c)}{p}}^2 + (p-a)^2 \\ &= \frac{(p-a)(p-b)(p-c)}{p} + (p-a)^2 \\ &= \left(\frac{p-a}{p}\right)[(p-b)(p-c)+p(p-a)] \end{aligned}$$

ដោយ

$$\begin{aligned} (p-b)(p-c) &= \left(\frac{a-b+c}{2}\right)\left(\frac{a+b-c}{2}\right) \\ &= \frac{a^2-(b-c)^2}{4} \end{aligned}$$

និង

$$\begin{aligned} p(p-a) &= \left(\frac{a+b+c}{2}\right)\left(\frac{b+c-a}{2}\right) \\ &= \frac{(b+c)^2-a^2}{4} \end{aligned}$$

នោះ

$$\begin{aligned} AI^2 &= \left(\frac{p-a}{p}\right)\left[\frac{a^2-(b-c)^2+(b+c)^2-a^2}{4}\right] \\ &= \left(\frac{p-a}{p}\right)bc \end{aligned}$$

ដូចនេះ $IA = \sqrt{\frac{(p-a)bc}{p}}$

ស្រាយដូចគ្នាយើងបាន $IB = \sqrt{\frac{(p-b)ca}{p}}$ និង $IC = \sqrt{\frac{(p-c)ab}{p}}$

សម្គាល់



ឧបមាថារង្វង់ចារឹកក្នុងត្រីកោណ ABC ប៉ះទៅនឹងជ្រុង [AB], [BC] និង [CA] ត្រង់ចំណុច D, E និង
F រៀងគ្នា ។ គេបាន

$$\begin{aligned} & x+y+y+z+z+x=2p \\ \Rightarrow & 2(x+y+z)=2p \\ \Rightarrow & x+y+z=p \\ \Rightarrow & x+a=p \\ \Rightarrow & x=p-a \end{aligned}$$

ដូចគ្នាដែរ គេបាន $y=p-b$ និង $z=p-c$

21 កាំរង្វង់ចារឹកក្នុងត្រីកោណ

ទ្រឹស្តីបទ

គេឲ្យត្រីកោណ ABC មានរង្វាស់ជ្រុង $BC=a, CA=b, AB=c, p=\dfrac{a+b+c}{2}$ ជាកន្លះបរិមាត្រ និង r ជាកាំរង្វង់ចារឹកក្នុងនៃត្រីកោណនេះ ។

គេបាន $r=(p-a)\tan\frac{A}{2}=(p-b)\tan\frac{B}{2}=(p-c)\tan\frac{C}{2}$ ។

សម្រាយ



បង្ហាញថា $r=(p-a)\tan\frac{A}{2}$

ក្នុងត្រីកោណកែង $AC'I$ មាន $\tan\frac{A}{2}=\frac{IC'}{AC'}$

នោះ $IC'=AC'\tan\frac{A}{2}\Rightarrow r=AC'\tan\frac{A}{2}$

ដោយ

$$\begin{aligned}AC'&=c-BC'\\&=c-BA'\\&=c-(a-A'C)\\&=c-a+A'C\\&=c-a+CB'\\&=c-a+b-AB'\\&=c-a+b-AC'\end{aligned}$$

នោះ $AC'=\frac{b+c-a}{2}=p-a$

ដូចនេះ $r=(p-a)\tan\frac{A}{2}$

តាមរបៀបដូចគ្នាយើងបាន $r=(p-b)\tan\frac{B}{2}$ និង $r=(p-c)\tan\frac{C}{2}$

សម្គាល់

មិត្តអ្នកអានអាចស្រាយ $AC' = p - a$ តាមរបៀបមួយទៀតដូចសម្គាល់នៃចំណុច 20 ។
ឧទាហរណ៍
គេឲ្យ ABC ជាត្រីកោណមួយ ។ បង្ហាញថា

1. $abc = 4prR$
2. $ab + bc + ca = p^2 + r^2 + 4rR$
3. $a^2 + b^2 + c^2 = 2p^2 - 2r^2 - 8rR$
4. $a^3 + b^3 + c^3 = 2(p^3 - 3pr^2 - 6prR)$
5. $\tan\frac{A}{2} + \tan\frac{B}{2} + \tan\frac{C}{2} = \frac{4R + r}{p}$
6. $\cos A + \cos B + \cos C = 1 + \frac{r}{R}$

សម្រាយ

1. $abc = 4prR$
   យើងមាន $\frac{abc}{4R} = S \Rightarrow abc = 4RS$
   ដោយ $S = pr \Rightarrow abc = 4Rpr$
   ដូចនេះ $abc = 4prR$
2. $ab + bc + ca = p^2 + r^2 + 4rR$
   តាមរូបមន្តហេរ៉ុង $S = \sqrt{p(p-a)(p-b)(p-c)}$
   នោះ $pr = \sqrt{p^4 - (a+b+c)p^3 + (ab+bc+ca)p^2 - abcp}$
   $\Rightarrow p^2r^2 = p^4 - (a+b+c)p^3 + (ab+bc+ca)p^2 - abcp$
   ដោយ $a + b + c = 2p$ និង $abc = 4prR$
   យើងបាន $p^2r^2 = p^4 - 2p^4 + (ab+bc+ca)p^2 - 4p^2rR$
   $\Rightarrow r^2 = -p^2 + ab + bc + ca - 4rR$
   ដូចនេះ $ab + bc + ca = p^2 + r^2 + 4rR$
3. $a^2 + b^2 + c^2 = 2p^2 - 2r^2 - 8rR$
   យើងមាន $(a+b+c)^2 = a^2 + b^2 + c^2 + 2(ab+bc+ca)$
   នោះ $a^2 + b^2 + c^2 = (a+b+c)^2 - 2(ab+bc+ca)$
   ដោយ $a + b + c = 2p$ និង $a^2 + b^2 + c^2 = p^2 + r^2 + 4rR$
   យើងបាន
   $$\begin{aligned} a^2 + b^2 + c^2 &= (2p)^2 - 2(p^2 + r^2 + 4rR) \\ &= 4p^2 - 2p^2 - 2r^2 - 8rR \\ &= 2p^2 - 2r^2 - 8rR \end{aligned}$$

ដូចនេះ $a^2+b^2+c^2=2p^2-2r^2-8rR$

4. $a^3+b^3+c^3=2(p^3-3pr^2-6prR)$
យើងមាន

$$\begin{aligned} a^3+b^3+c^3-3abc &= (a+b+c)(a^2+b^2+c^2-ab-bc-ca) \\ \Rightarrow a^3+b^3+c^3-12prR &= 2p(2p^2-2r^2-8rR-p^2-r^2-4rR) \\ \Rightarrow a^3+b^3+c^3 &= 2p(p^2-3r^2-12rR)+12prR \\ &= 2p(p^2-3r^2-6rR) \end{aligned}$$

ដូចនេះ $a^3+b^3+c^3=2(p^3-3pr^2-6prR)$

5. $\tan\frac{A}{2}+\tan\frac{B}{2}+\tan\frac{C}{2}=\frac{4R+r}{p}$
យើងមាន $r=(p-a)\tan\frac{A}{2}$ នោះ $\tan\frac{A}{2}=\frac{r}{p-a}$
ដូចគ្នាដែរយើងបាន $\tan\frac{B}{2}=\frac{r}{p-b}$ និង $\tan\frac{C}{2}=\frac{r}{p-c}$
យើងបាន

$$\begin{aligned} \tan\frac{A}{2}+\tan\frac{B}{2}+\tan\frac{C}{2} &= \frac{r}{p-a}+\frac{r}{p-b}+\frac{r}{p-c} \\ &= r\left[\frac{(p-b)(p-c)+(p-a)(p-c)+(p-a)(p-b)}{(p-a)(p-b)(p-c)}\right] \\ &= pr\left[\frac{3p^2-2(a+b+c)p+ab+bc+ca}{p(p-a)(p-b)(p-c)}\right] \\ &= S\left(\frac{3p^2-4p^2+p^2+r^2+4rR}{S^2}\right) \\ &= \frac{r^2+4rR}{pr}=\frac{r+4R}{p} \end{aligned}$$

ដូចនេះ $\tan\frac{A}{2}+\tan\frac{B}{2}+\tan\frac{C}{2}=\frac{4R+r}{p}$

6. $\cos A+\cos B+\cos C=1+\frac{r}{R}$

តាមទ្រឹស្តីបទកូស៊ីនុសយើងបាន

$$\begin{aligned}\cos A+\cos B+\cos C &= \frac{b^2+c^2-a^2}{2bc}+\frac{c^2+a^2-b^2}{2ca}+\frac{a^2+b^2-c^2}{2ab}\\ &= \frac{ab^2+ac^2-a^3+bc^2+a^2b-b^3+a^2c+b^2c-c^3}{2abc}\\ &= \frac{a^2(a+b+c)+b^2(a+b+c)+c^2(a+b+c)-2(a^3+b^3+c^3)}{2abc}\\ &= \frac{(a+b+c)(a^2+b^2+c^2)-2(a^3+b^3+c^3)}{2abc}\end{aligned}$$

ដោយ $a+b+c=2p, a^2+b^2+c^2=2p^2-2r^2-8rR, a^3+b^3+c^3=2(p^3-3pr^2-6prR)$ និង $abc=4prR$
យើងបាន

$$\begin{aligned}\cos A+\cos B+\cos C &= \frac{2p(2p^2-2r^2-8rR)-4(p^3-3pr^2-6prR)}{8prR}\\ &= \frac{2p^2-2r^2-8rR-2p^2+6r^2+12rR}{4rR}\\ &= \frac{4rR+4r^2}{4rR}\\ &= 1+\frac{r}{R}\end{aligned}$$

ដូចនេះ $\cos A+\cos B+\cos C=1+\dfrac{r}{R}$

22 ទ្រឹស្តីបទតង់សង់

គេឲ្យត្រីកោណ ABC មួយមានរង្វាស់ជ្រុង $BC=a, AC=b$ និង $AB=c$ ។
គេបាន $\dfrac{a-b}{a+b}=\dfrac{\tan\left(\frac{A-B}{2}\right)}{\tan\left(\frac{A+B}{2}\right)}$, $\dfrac{b-c}{b+c}=\dfrac{\tan\left(\frac{B-C}{2}\right)}{\tan\left(\frac{B+C}{2}\right)}$ និង $\dfrac{C-A}{C+A}=\dfrac{\tan\left(\frac{C-A}{2}\right)}{\tan\left(\frac{C+A}{2}\right)}$ ។

សម្រាយ

តាមទ្រឹស្តីបទស៊ីនុសយើងបាន $a=2R\sin A$ និង $b=2R\sin B$
យើងបាន $\dfrac{a-b}{a+b}=\dfrac{2R\sin A-2R\sin B}{2R\sin A+2R\sin B}$
$=\dfrac{\sin A-\sin B}{\sin A+\sin B}$

$= \dfrac{2\sin\left(\frac{A-B}{2}\right)\cos\left(\frac{A+B}{2}\right)}{2\sin\left(\frac{A+B}{2}\right)\cos\left(\frac{A-B}{2}\right)}$
$= \dfrac{\tan\left(\frac{A-B}{2}\right)}{\tan\left(\frac{A+B}{2}\right)}$
ស្រាយដូចគ្នាយើងបាន $\dfrac{b-c}{b+c} = \dfrac{\tan\left(\frac{B-C}{2}\right)}{\tan\left(\frac{B+C}{2}\right)}$ និង $\dfrac{C-A}{C+A} = \dfrac{\tan\left(\frac{C-A}{2}\right)}{\tan\left(\frac{C+A}{2}\right)}$

23 ប្រវែងកន្លះបន្ទាត់ពុះមុំ l_a, l_b និង l_c

ទ្រឹស្តីបទ
គេឲ្យត្រីកោណ ABC មួយមានជ្រុង $BC = a, CA = b$ និង $AB = c$ ។ យក $[AA'), [BB')$ និង $[CC')$ ជាកន្លះបន្ទាត់ពុះមុំក្នុងនៃ A, B និង C រៀងគ្នា ហើយ $AA' = l_a, BB' = l_b$ និង $CC' = l_c$ ។ គេបាន $l_a = \dfrac{2bc}{b+c}\cos\dfrac{A}{2}$, $l_b = \dfrac{2ca}{c+a}\cos\dfrac{B}{2}$ និង $l_c = \dfrac{2ab}{a+b}\cos\dfrac{C}{2}$ ។
សម្រាយ



យើងមាន $[ABC] = [ABA'] + [AA'C]$
$\Rightarrow \dfrac{1}{2}bc\sin A = \dfrac{1}{2}cl_a\sin\dfrac{A}{2} + \dfrac{1}{2}bl_a\sin\dfrac{A}{2}$
$\Rightarrow 2bc\sin\dfrac{A}{2}\cos\dfrac{A}{2} = l_a(b+c)\sin\dfrac{A}{2}$
យើងបាន $l_a = \dfrac{2bc}{b+c}\cos\dfrac{A}{2}$

ស្រាយដូចគ្នាយើងបាន $l_b=\dfrac{2ca}{c+a}\cos\dfrac{B}{2}$ និង $l_c=\dfrac{2ab}{a+b}\cos\dfrac{C}{2}$

24 កន្សោម $\sin\dfrac{A}{2},\cos\dfrac{A}{2}$ និង $\tan\dfrac{A}{2}$

ទ្រឹស្តីបទ

គេឲ្យត្រីកោណ ABC មួយមានរង្វាស់ជ្រុង $BC=a,CA=b,AB=c$ ហើយ $p=\dfrac{a+b+c}{2}$ ជាកន្លះបរិមាត្រនៃត្រីកោណនេះ ។ គេបាន $\sin\dfrac{A}{2}=\sqrt{\dfrac{(p-b)(p-c)}{bc}},\cos\dfrac{A}{2}=\sqrt{\dfrac{p(p-a)}{bc}}$ និង $\tan\dfrac{A}{2}=\sqrt{\dfrac{(p-b)(p-c)}{p(p-a)}}$ ។

សម្រាយ



បង្ហាញថា $\sin\dfrac{A}{2}=\sqrt{\dfrac{(p-b)(p-c)}{bc}}$

របៀបទី ១

យើងមាន $\sin\dfrac{A}{2}=\dfrac{ID}{IA}=\dfrac{r}{IA}$

ដោយ $r=\sqrt{\dfrac{(p-a)(p-b)(p-c)}{p}}$ និង $IA=\sqrt{\left(\dfrac{p-a}{p}\right)bc}$

យើងបាន $\sin\dfrac{A}{2}=\dfrac{\sqrt{\frac{(p-a)(p-b)(p-c)}{p}}}{\sqrt{\left(\frac{p-a}{p}\right)bc}}$

$=\sqrt{\dfrac{(p-a)(p-b)(p-c)}{p}\times\dfrac{p}{(p-a)bc}}$

$=\sqrt{\dfrac{(p-b)(p-c)}{bc}}$

ដូចនេះ $\sin\dfrac{A}{2}=\sqrt{\dfrac{(p-b)(p-c)}{bc}}$

របៀបទី ២

យើងមាន $\sin^2\dfrac{A}{2}=\dfrac{1-\cos A}{2}$ ដោយ $\cos A=\dfrac{b^2+c^2-a^2}{2bc}$

នោះ

$$\begin{aligned}\sin^2\frac{A}{2}&=\frac{1-\left(\frac{b^2+c^2-a^2}{2bc}\right)}{2}\\&=\frac{2bc-b^2-c^2+a^2}{4bc}\\&=\frac{a^2-(b-c)^2}{4bc}\\&=\frac{(a-b+c)(a+b-c)}{4bc}\\&=\frac{(p-b)(p-c)}{bc}\end{aligned}$$

ដូចនេះ $\sin\dfrac{A}{2}=\sqrt{\dfrac{(p-b)(p-c)}{bc}}$

បង្ហាញថា $\cos\dfrac{A}{2}=\sqrt{\dfrac{p(p-a)}{bc}}$

របៀបទី ១

យើងមាន $\cos\dfrac{A}{2}=\dfrac{AD}{IA}$ ដោយ $AD=p-a$

យើងបាន

$$\begin{aligned}\cos\frac{A}{2} &= \frac{p-a}{\sqrt{\left(\frac{p-a}{p}\right)bc}}\\ &= (p-a)\sqrt{\frac{p}{(p-a)bc}}\\ &= \sqrt{(p-a)^2\times\frac{p}{(p-a)bc}} = \sqrt{\frac{p(p-a)}{bc}}\end{aligned}$$

ដូចនេះ $\cos\frac{A}{2} = \sqrt{\frac{p(p-a)}{bc}}$

របៀបទី ២

យើងមាន

$$\begin{aligned}\cos^2\frac{A}{2} &= \frac{1+\cos A}{2}\\ &= \frac{1+\frac{b^2+c^2-a^2}{2bc}}{2}\\ &= \frac{2bc+b^2+c^2-a^2}{4bc}\\ &= \frac{(b+c)^2-a^2}{4bc}\\ &= \frac{(b+c-a)(b+c+a)}{4bc}\\ &= \frac{p(p-a)}{bc}\end{aligned}$$

ដូចនេះ $\cos\frac{A}{2} = \sqrt{\frac{p(p-a)}{bc}}$

បង្ហាញថា $\tan\frac{A}{2} = \sqrt{\frac{(p-b)(p-c)}{p(p-a)}}$

យើងមាន

$$\begin{aligned}\tan\frac{A}{2} &= \frac{\sin\frac{A}{2}}{\cos\frac{A}{2}}\\ &= \frac{\sqrt{\frac{(p-b)(p-c)}{bc}}}{\sqrt{\frac{p(p-a)}{bc}}}\\ &= \sqrt{\frac{(p-b)(p-c)}{bc}}\times\sqrt{\frac{bc}{p(p-a)}}\\ &= \sqrt{\frac{(p-b)(p-c)}{p(p-a)}}\end{aligned}$$

ដូចនេះ $\tan\frac{A}{2} = \sqrt{\frac{(p-b)(p-c)}{p(p-a)}}$

25 ទ្រឹស្តីបទ Ptolemy

គេឲ្យ $ABCD$ ជាចតុកោណចារឹកក្នុងរង្វង់ ។ គេបាន $AB\times CD+AD\times BC=AC\times BD$ ។
សម្រាយ



យក K ជាចំណុចមួយនៅលើ $[AC]$ ដែល $\angle ABK=\angle DBC$
ដោយ $\angle KAB=\angle BDC$ (មុំចារឹកស្កាត់ធ្នូរួម)
គេបាន $\triangle ABK\sim\triangle DBC$

នោះ $\frac{AB}{BD}=\frac{AK}{CD}\Rightarrow AB\times CD=BD\times AK$ (1)
ម្យ៉ាងទៀត $\triangle KBC$ និង $\triangle ABD$ មាន
$\angle KCB=\angle ADB$ (មុំចារឹកស្កាត់ធ្នូរួម) និង $\angle KBC=\angle ABD$ ព្រោះ $\angle ABK=\angle DBC$
នោះ $\triangle ABD\sim\triangle KBC$
យើងបាន $\frac{BD}{BC}=\frac{AD}{KC}\Rightarrow AD\times BC=BD\times KC$ (2)
បូក (1) និង (2) យើងបាន

$$\begin{aligned} AB\times CD+AD\times BC &= BD\times AK+BD\times KC \\ &= BD(AK+KC)=BD\times AC \end{aligned}$$

ដូចនេះ $AB\times CD+AD\times BC=AC\times BD$
ឧទាហរណ៍ ១
គេមានត្រីកោណសម័ង្ស ABC មួយចារឹកក្នុងរង្វង់ ។ យក P ជាចំណុចមួយនៅលើធ្នូតូច BC ហើយ $[AP]$ និង $[BC]$ ប្រសព្វគ្នាត្រង់ចំណុច Q ។ បង្ហាញថា $\frac{1}{PQ}=\frac{1}{PB}+\frac{1}{PC}$ ។

សម្រាយ



បង្ហាញថា $\frac{1}{PQ}=\frac{1}{PB}+\frac{1}{PC}$
ដោយ $ABPC$ ជាចតុកោណចារឹកក្នុងរង្វង់ តាមទ្រឹស្តីបទ Ptolemy យើងបាន
$AB\times PC+AC\times BP=AP\times BC$
ដោយ $AB=BC=CA$ ព្រោះ ABC ជាត្រីកោណសម័ង្ស
យើងបាន $PC+PB=PA$ (1)
ត្រីកោណ PBQ និង APC មាន

$\angle PBQ = \angle PAC$ (មុំចារឹកស្កាត់ធ្នូរួម)
ម្យ៉ាងទៀត $\angle QPB = \angle ACB$ និង $\angle APC = \angle ABC = \angle ACB$
$\Rightarrow \angle QPB = \angle APC$
យើងបាន $\triangle PBQ \sim \triangle PAC$
វិបាក $\frac{PB}{PA} = \frac{PQ}{PC}$ នោះ $\frac{1}{PQ} = \frac{PA}{PB \times PC}$ (2)
តាម (1) និង (2) យើងបាន $\frac{1}{PQ} = \frac{PB+PC}{PB \times PC} = \frac{1}{PB} + \frac{1}{PC}$
ដូចនេះ $\frac{1}{PQ} = \frac{1}{PB} + \frac{1}{PC}$
ឧទាហរណ៍ ២
គេឲ្យការេ $ABCD$ ចារឹកក្នុងរង្វង់មួយ ។ យក P ជាចំណុចមួយនៅលើធ្នូតូច BC ។
បង្ហាញថា $\frac{PA+PC}{PB+PD} = \frac{PD}{PA}$ ។
សម្រាយ



បង្ហាញថា $\frac{PA+PB}{PC+PD} = \frac{PD}{PA}$
យើងមាន $ABPD$ ជាចតុកោណចារឹកក្នុងរង្វង់ តាមទ្រឹស្តីបទ Ptolemy យើងបាន
$AD \times PB + AB \times PD = PA \times BD$ ដោយ $AD = AB$ (ជ្រុងការេ)
នោះ $AD(PB+PD) = PA \times BD$
$\Rightarrow \frac{PA}{PB+PD} = \frac{AD}{BD}$ (1)
ម្យ៉ាងទៀត $APCD$ ជាចតុកោណចារឹកក្នុងរង្វង់ តាមទ្រឹស្តីបទ Ptolemy យើងបាន
$PA \times DC + AD \times PC = PD \times AC$
ដោយ $AC = BD$ និង $DC = AD$ នោះ $PA \times AD + AD \times PC = PD \times BD$
$\Rightarrow AD(PA+PC) = PD \times BD$

$\Rightarrow \dfrac{AD}{BD} = \dfrac{PD}{PA+PC}$ (2)

តាម (1) និង (2) យើងបាន $\dfrac{PA}{PB+PD} = \dfrac{PD}{PA+PC}$

ដូចនេះ $\dfrac{PA+PC}{PB+PD} = \dfrac{PD}{PA}$

26 ទ្រឹស្តីបទ Carnot II

ទ្រឹស្តីបទ

គេមានត្រីកោណមុំស្រួច ABC មួយ ហើយ d_a, d_b និង d_c ជាចម្ងាយពីផ្ចិតរង្វង់ចារឹកក្រៅត្រីកោណនេះទៅកាន់ជ្រុង $[BC], [CA]$ និង $[AB]$ រៀងគ្នា ។ បង្ហាញថា $d_a + d_b + d_c = R + r$ ។

សម្រាយ



យក A', B' និង C' ជាចំណោលកែងនៃ O លើ $[BC], [CA]$ និង $[AB]$ រៀងគ្នា

នោះ A', B' និង C' ជាចំណុចកណ្តាលនៃជ្រុង $[BC], [CA]$ និង $[AB]$ រៀងគ្នា

យើងបាន $[A'B'], [B'C']$ និង $[C'A']$ ជាបាតមធ្យមនៃត្រីកោណ ABC

នោះ $A'B' = \dfrac{AB}{2} = \dfrac{c}{2}, B'C' = \dfrac{BC}{2} = \dfrac{a}{2}$ និង $C'A' = \dfrac{CA}{2} = \dfrac{b}{2}$

ហើយ $AC'OB', OC'BA'$ និង $OA'CB'$ ជាចតុកោណចារឹកក្នុងរង្វង់

ចំពោះចតុកោណ $AC'OB'$

តាមទ្រឹស្តីបទ Ptolemy យើងបាន $AC' \times OB' + OC' \times AB' = OA \times B'C'$

$\dfrac{1}{2}cd_b + \dfrac{1}{2}bd_c = \dfrac{1}{2}aR$

$cd_b+bd_c=aR(1)$
ស្រាយដូចគ្នាចំពោះចតុកោណ $OC'BA'$ និង $OA'CB'$ យើងបាន
$cd_a+ad_c=bR$ (2)
$bd_a+ad_b=cR$ (3)
ម៉្យាងទៀត $[ABC]=[AOB]+[BOC]+[COA]$
$\Rightarrow pr=\frac{1}{2}ad_a+\frac{1}{2}bd_b+\frac{1}{2}cd_c$
$\Rightarrow ad_a+bd_b+cd_c=(a+b+c)r$ (4)
បូក (1),(2),(3) និង (4) យើងបាន $(a+b+c)(d_a+d_b+d_c)=(R+r)(a+b+c)$
ដូចនេះ $d_a+d_b+d_c=R+r$

27 ទ្រឹស្តីបទ Casey

ទ្រឹស្តីបទ
យក O ជាផ្ចិត និង កាំនៃរង្វង់មួយ ហើយ O_A,O_B,O_C និង O_D ជាផ្ចិតនៃរង្វង់ប៉ះក្នុងនៃរង្វង់ផ្ចិត O (រង្វង់ទាំងបួនគ្មានចំណុចប្រសព្វរួម) ។ តាង ij ជាប្រវែងនៃអង្កត់ប៉ះក្រៅនៃរង្វង់ផ្ចិត O_i និង O_j ។ គេបាន $AB\times CD+BD\times AC=AD\times BC$ ។
សម្រាយ



យក K_A,K_B,K_C និង K_D ជាចំណុចប៉ះរង្វង់ O_A,O_B,O_C និង O_D ទៅនឹងរង្វង់ផ្ចិត O រៀងគ្នា
ចំពោះរង្វង់ផ្ចិត O_A និង O_B
តាមទ្រឹស្តីបទពីតាគ័រយើងបាន $AB^2=O_AO_B^2-(R_B-R_A)^2$

តាមទ្រឹស្តីបទកូស៊ីនុស

$$\begin{aligned} O_AO_B^2 &= OO_A^2 + OO_B^2 - 2OO_A \times OO_B \cos\angle O_AOO_B \\ &= (R-R_A)^2 + (R-R_B)^2 - 2(R-R_A)(R-R_B)\cos\angle O_AOO_B \\ &= (R-R_A)^2 + (R-R_B)^2 - 2(R-R_A)(R-R_B)\cos\angle K_AOK_B \end{aligned}$$

យក C ជាចំណុចមួយនៅលើរង្វង់ផ្ចិត O
អនុវត្តទ្រឹស្តីបទស៊ីនុសក្នុងត្រីកោណ K_ACK_B យើងបាន
$K_AK_B = 2R\sin\angle K_ACK_B$ ដោយ $\angle K_ACK_B = \pi - \dfrac{\angle K_AOK_B}{2}$

$$\begin{aligned} \sin\angle K_ACK_B &= \sin\left(\pi - \frac{\angle K_AOK_B}{2}\right) \\ &= \sin\frac{\angle K_AOK_B}{2} \end{aligned}$$

យើងបាន $K_AK_B = 2R\sin\dfrac{\angle K_AOK_B}{2} \Rightarrow \sin\dfrac{\angle K_AOK_B}{2} = \dfrac{K_AK_B}{2R}$
នោះ

$$\begin{aligned} \cos\angle K_AOK_B &= 1 - 2\sin^2\frac{\angle K_AOK_B}{2} \\ &= 1 - 2\left(\frac{K_AK_B}{2R}\right)^2 = 1 - \frac{K_AK_B^2}{2R^2} \end{aligned}$$

នោះ $O_AO_B^2 = (R-R_A)^2 + (R-R_B)^2 - 2(R-R_A)(R-R_B)\left(1 - \dfrac{K_AK_B^2}{2R^2}\right)$
$= [(R-R_A)-(R-R_B)]^2 + \dfrac{(R-R_A)(R-R_B)K_AK_B^2}{R^2}$
គេបាន

$$\begin{aligned} AB^2 &= (R_B-R_A)^2 + \frac{(R-R_A)(R-R_B)K_AK_B^2}{R^2} - (R_B-R_A)^2 \\ &= \frac{(R-R_A)(R-R_B)K_AK_B^2}{R^2} \end{aligned}$$

$\Rightarrow AB = \dfrac{K_AK_B\sqrt{(R-R_A)(R-R_B)}}{R}$
ស្រាយដូចគ្នាយើងបាន
$AC = \dfrac{K_AK_C\sqrt{(R-R_A)(R-R_C)}}{R}$

$$CD = \frac{K_C K_D \sqrt{(R-R_C)(R-R_D)}}{R}$$
$$BD = \frac{K_B K_D \sqrt{(R-R_B)(R-R_D)}}{R}$$
$$BC = \frac{K_B K_C \sqrt{(R-R_B)(R-R_C)}}{R}$$
$$AD = \frac{K_A K_D \sqrt{(R-R_A)(R-R_D)}}{R}$$
យើងបាន $AB \times CD + BC \times AD$
$$= \frac{K_A K_B \times K_C K_D \sqrt{(R-R_A)(R-R_B)(R-R_C)(R-R_D)}}{R}$$
$$+ \frac{K_B K_C \times K_A K_D \sqrt{(R-R_A)(R-R_B)(R-R_C)(R-R_D)}}{R}$$
$$= \frac{(K_A K_B \times K_C K_D + K_B K_C \times K_A K_D)\sqrt{(R-R_A)(R-R_B)(R-R_C)(R-R_D)}}{R}$$
ម្យ៉ាងទៀត $K_A K_B K_C K_D$ ជាចតុកោណចារឹកក្នុងរង្វង់

នោះ $K_A K_B \times K_C K_D + K_B K_C \times K_A K_D = K_A K_C \times K_B K_D$ (ទ្រឹស្តីបទ Ptolemy)

យើងបាន $AB \times CD + BC \times AD = \frac{K_A K_C \times K_B K_D \sqrt{(R-R_A)(R-R_B)(R-R_C)(R-R_D)}}{R}$

ដូចនេះ $AB \times CD + BC \times AD = AD \times BC$

28 ទ្រឹស្តីបទមេអំបៅ

គេឲ្យរង្វង់មួយ និង អង្កត់ធ្នូ $[PQ]$ ។ គេគូសអង្កត់ធ្នូ $[AB]$ និង $[CD]$ ឲ្យកាត់អង្កត់ធ្នូ $[PQ]$ តាមចំណុចកណ្តាល M ហើយ $[AD]$ និង $[BC]$ ប្រសព្វ $[PQ]$ ត្រង់ចំណុច X និង Y រៀងគ្នា ។ គេបាន M ជាចំណុចកណ្តាលនៃ $[XY]$ ។

សម្រាយ



យក E,F ជាចំណោលកែងនៃ X លើ $[AB]$ និង $[CD]$ រៀងគ្នា និង W,Z ជាចំណោលកែងនៃ Y លើ $[AB]$ និង $[CD]$ រៀងគ្នា
នោះ $[EX]//[YW]$
តាមទ្រឹស្តីបទ Thales យើងបាន $\dfrac{XM}{YM}=\dfrac{XE}{YW}$ (1)
ហើយ $[XF]//[ZY]$
តាមទ្រឹស្តីបទ Thales យើងបាន $\dfrac{XM}{YM}=\dfrac{XF}{YZ}$ (2)
តាម (1) និង (2) យើងបាន $\left(\dfrac{XM}{XY}\right)^2=\dfrac{XE\times XF}{YW\times YZ}$ (3)
ត្រីកោណកែង AXE និង ត្រីកោណកែង CZY
មាន $\angle XAE=\angle ZCY$ (មុំចារឹកស្កាត់ធ្នូរួម)
គេបាន $\triangle AXE\sim\triangle CYZ$
វិបាក $\dfrac{AX}{CY}=\dfrac{XE}{YZ}$ (4)
ត្រីកោណកែង XDF និង ត្រីកោណកែង YBW
មាន $\angle XDF=\angle WBY$ (មុំចារឹកស្កាត់ធ្នូរួម) នោះ $\triangle XDF\sim\triangle YBW\Rightarrow\dfrac{XD}{YB}=\dfrac{XF}{YW}$ (5)
តាម (4) និង (5) យើងបាន $\dfrac{AX\times XD}{CY\times YB}=\dfrac{XE\times XF}{YW\times YZ}$ (6)
តាម (3) និង (6) យើងបាន $\left(\dfrac{XM}{YM}\right)^2=\dfrac{AX\times XD}{CY\times YB}$
ម្យ៉ាងទៀត តាមស្វ័យគុណចំណុច
$CY\times YB=PY\times YQ$
$=(PM+YM)(MQ-YM)$

$= (PM+YM)(PM-YM)$
$= PM^2 - YM^2$ (i)
ដូចគ្នាដែរ $AX \times XD$
$= PX \times XQ$
$= PM^2 - YM^2$ (ii)
តាម (i) និង (ii) យើងបាន $CY \times YB = AX \times XD$
នោះ $\left(\frac{XM}{YM}\right)^2 = \frac{AX \times XD}{AX \times XD} = 1 \Rightarrow XM^2 = YM^2 \Rightarrow XM = YM$
ដូចនេះ M ជាចំណុចកណ្ដាលនៃ $[XY]$

29 ទ្រឹស្ដីបទ Euler

Lemma (បទគន្លឹះ)
យក I ជាផ្ចិតរង្វង់ចារឹកក្នុងត្រីកោណ ABC មួយដែលមាន $BC = a, AC = b$ និង $AB = c$ ។ គេបាន
ក) $\frac{IA^2}{bc} + \frac{IB^2}{ca} + \frac{IC^2}{ab} = 1$
ខ) $\frac{AI}{ID} = \frac{b+c}{a}$ ។

សម្រាយ

ក) បង្ហាញថា $\frac{IA^2}{bc} + \frac{IB^2}{ca} + \frac{IC^2}{ab} = 1$
យើងមាន $IA = \frac{r}{\sin\frac{A}{2}} \Rightarrow IA^2 = \frac{r^2}{\sin^2\frac{A}{2}}$
ដោយ

$$\begin{aligned}\sin^2\frac{A}{2} &= \frac{1-\cos A}{2}\\ &= \frac{1-\frac{b^2+c^2-a^2}{2bc}}{2}\\ &= \frac{2bc-b^2-c^2+a^2}{4bc}\\ &= \frac{a^2-(b-c)^2}{4bc}\\ &= \frac{(a-b+c)(a+b-c)}{4bc}\\ &= \frac{(p-b)(p-c)}{bc}\end{aligned}$$

និង $pr=\sqrt{p(p-a)(p-b)(p-c)}\Rightarrow r^2=\frac{(p-a)(p-b)(p-c)}{p}$

នោះ $IA^2=\frac{\frac{(p-a)(p-b)(p-c)}{p}}{\frac{(p-b)(p-c)}{bc}}=\left(\frac{p-a}{p}\right)bc$

$\Rightarrow \frac{IA^2}{bc}=\frac{p-a}{p}$

ដូចគ្នាដែរ $\frac{IB^2}{ca}=\frac{p-b}{p}$ និង $\frac{IC^2}{ab}=\frac{p-c}{p}$

យើងបាន

$$\begin{aligned}\frac{IA^2}{bc}+\frac{IB^2}{ca}+\frac{IC^2}{ab}&=\frac{p-a}{p}+\frac{p-b}{p}+\frac{p-c}{p}\\&=\frac{3p-(a+b+c)}{p}\\&=\frac{3p-2p}{p}\\&=\frac{p}{p}\\&=1\end{aligned}$$

ដូចនេះ $\frac{IA^2}{bc}+\frac{IB^2}{ca}+\frac{IC^2}{ab}=1$

ខ) $\frac{AI}{ID}=\frac{b+c}{a}$



អនុវត្តទ្រឹស្តីបទកន្លះបន្ទាត់ពុះមុំក្នុងត្រីកោណ ACD យើងបាន $\frac{AC}{AI} = \frac{CD}{DI} \Rightarrow \frac{AI}{ID} = \frac{AC}{CD} = \frac{b}{CD}$

ដោយ $CD = \frac{ab}{b+c} \Rightarrow \frac{AI}{ID} = \frac{b}{\frac{ab}{b+c}} = \frac{b+c}{a}$

ទ្រឹស្តីបទ

គេឲ្យត្រីកោណ ABC មួយមានប្រវែងជ្រុង $BC = a, CA = b$ និង $AB = c$ ។ យក I ជាផ្ចិតរង្វង់ចារឹកក្នុង ត្រីកោណនេះ ហើយ X ជាចំណុចមួយនៅក្នុងប្លង់ ។

គេបាន $aXA^2 + bXB^2 + cXC^2 = (a+b+c)XI^2 + abc$ ។



សម្រាយ

យើងមាន $\overrightarrow{XA}=\overrightarrow{XI}+\overrightarrow{IA}$ នោះ $XA^2=XI^2+2\overrightarrow{XI}\overrightarrow{IA}+IA^2$
គេបាន $aXA^2=aXI^2+2a\overrightarrow{XI}\overrightarrow{IA}+aIA^2$
ដូចគ្នាដែរ $bXB^2=bXI^2+2b\overrightarrow{XI}\overrightarrow{IB}+bIB^2$
និង $cXA^2=cXI^2+2c\overrightarrow{XI}\overrightarrow{IC}+cIC^2$
យើងបាន
$aXA^2+bXB^2+cXC^2=(a+b+c)XI^2+aIA^2+bIB^2+cIC^2+2\overrightarrow{XI}(a\overrightarrow{IA}+b\overrightarrow{IB}+c\overrightarrow{IC})$
(i)
ដោយ $\dfrac{IA^2}{bc}+\dfrac{IB^2}{ca}+\dfrac{IC^2}{ab}=1$ នោះ $aIA^2+bIB^2+cIC^2=abc$ (ii)
ម៉្យាងទៀត

$$\begin{aligned}&\frac{AB}{BD}=\frac{AC}{CD}\\ \Rightarrow&\frac{c}{BD}=\frac{b}{CD}\\ \Rightarrow& bBD=cDC\\ \Rightarrow& b\overrightarrow{BD}=c\overrightarrow{DC}\\ \Rightarrow& b(\overrightarrow{BI}+\overrightarrow{ID})=c(\overrightarrow{DI}+\overrightarrow{IC})\\ \Rightarrow& b\overrightarrow{IB}+c\overrightarrow{IC}=(b+c)\overrightarrow{ID}(1)\end{aligned}$$

មួយវិញទៀត

$$\begin{aligned}&\frac{AI}{ID}=\frac{b+c}{a}\\&\Rightarrow aAI=(b+c)ID\\&\Rightarrow a\overrightarrow{IA}=-(b+c)\overrightarrow{ID}\\&\Rightarrow a\overrightarrow{IA}+(b+c)\overrightarrow{ID}=\overrightarrow{0}\,(2)\end{aligned}$$

តាម (1) និង (2)យើងបាន $a\overrightarrow{IA}+b\overrightarrow{IB}+c\overrightarrow{IC}=\overrightarrow{O}$ (iii)
តាម (i),(ii) និង (iii) យើងបាន $aXA^2+bXB^2+cXC^2=(a+b+c)XI^2+abc$
ឧទាហរណ៍
(ចម្ងាយ Euler)
គេឲ្យ O និង I ជាផ្ចិតរង្វង់ចារឹកក្រៅ និង ចារឹកក្នុងនៃត្រីកោណ ABC ហើយ R និង r ជាកាំរង្វង់ចារឹកក្រៅ និង ចារឹកក្នុងនៃត្រីកោណនេះរៀងគ្នា ។ បង្ហាញថា $OI^2=R^2-2Rr$ ។

សម្រាយ

តាមរូបមន្ត Euler យើងបាន $aOA^2+bOB^2+cOC^2=(a+b+c)OI^2+abc$
ដោយ $OA=OB=OC=R$
នោះ

$$\begin{aligned}aR^2+bR^2+cR^2&=(a+b+c)OI^2+abc\\\Rightarrow (a+b+c)OI^2&=(a+b+c)R^2-abc\\\Rightarrow 2pOI^2&=2pR^2-abc\\\Rightarrow OI^2&=R^2-\frac{abc}{2p}\end{aligned}$$

តាម $pr=\dfrac{abc}{4R}\Rightarrow\dfrac{abc}{2p}=2Rr$
យើងបាន $OI^2=R^2-2Rr$

សម្គាល់

តាមឧទាហរណ៍យើងមាន $OI^2=R^2-2Rr\Rightarrow R^2=2Rr+OI^2$
ដោយ $OI^2\geq 0$
$\Rightarrow R^2\geq 2Rr\Rightarrow R\geq 2r$
វិសមភាព $R\geq 2r$ នេះហៅថាវិសមភាព Euler ។

30 ទ្រឹស្តីបទ Ceva

គេមានត្រីកោណ ABC មួយ ហើយ $[AD],[BE]$ និង $[CF]$ កាត់ជ្រុង $[BC],[CA]$ និង $[AB]$ ត្រង់ D,E និង F រៀងគ្នា នោះ $[AD],[BE]$ និង $[CF]$ ប្រសព្វគ្នាត្រង់មួយចំណុច លុះត្រាតែ $\frac{AF}{FB}\times\frac{BD}{DC}\times\frac{CE}{EA}=1$។

សម្រាយ



$\Rightarrow$ ឧបមាថា $[AD],[BE]$ និង $[CF]$ ប្រសព្វគ្នាត្រង់មួយចំណុច

បង្ហាញថា $\frac{AF}{FB}\times\frac{BD}{DC}\times\frac{CE}{EA}=1$

យើងមាន $\frac{[BOD]}{[ODC]}=\frac{\frac{1}{2}h\times BD}{\frac{1}{2}h\times CD}=\frac{BD}{CD}$

ដូចគ្នាដែរ $\frac{[ABD]}{[ACD]}=\frac{BD}{CD}$

យើងបាន $\frac{[BOD]}{[ODC]}=\frac{[ABD]}{[ACD]}=\frac{BD}{CD}=\frac{[ABD]-[BOD]}{[ACD]-[ODC]}=\frac{[AOB]}{[AOC]}$

$\Rightarrow \frac{BD}{CD}=\frac{[AOB]}{[AOC]}$

ស្រាយដូចគ្នាយើងបាន $\frac{AF}{BF}=\frac{[AOC]}{[BOC]}$ និង $\frac{CE}{EA}=\frac{[BOC]}{[AOB]}$

យើងបាន $\frac{AF}{FB}\times\frac{BD}{DC}\times\frac{CE}{EA}=\frac{[AOC]}{[BOC]}\times\frac{[AOB]}{[AOC]}\times\frac{[BOC]}{[AOB]}=1$

ដូចនេះ $\frac{AF}{FB}\times\frac{BD}{DC}\times\frac{CE}{EA}=1$

$\Leftarrow$ ឧបមាថា $\frac{AF}{FB}\times\frac{BD}{DC}\times\frac{CE}{EA}=1$

បង្ហាញថា $[AD]$, $[BE]$ និង $[CF]$ ប្រសព្វគ្នាត្រង់មួយចំណុច
យក O ជាចំណុចប្រសព្វនៃ $[AD]$ និង $[BE]$ ហើយ $[CK]$ ជាអង្កត់មួយទៀតដែលកាត់តាមចំណុច O
តាមសម្រាយខាងលើយើងបាន $\frac{AK}{KB} \times \frac{BD}{DC} \times \frac{CE}{EA} = 1$
ដោយ $\frac{AF}{FB} \times \frac{BD}{DC} \times \frac{CE}{EA} = 1$
យើងបាន $\frac{AF}{FB} = \frac{AK}{KB} \Rightarrow F$ និង K ត្រួតស៊ីគ្នា
ហេតុនេះ $[AD],[BE]$ និង $[CF]$ ប្រសព្វគ្នាត្រង់មួយចំណុច
ឧទាហរណ៍ ១
បង្ហាញថា មេដ្យានទាំងបីនៃត្រីកោណមួយប្រសព្វគ្នាត្រង់មួយចំណុច ។
សម្រាយ



ឧបមាថាយើងមានត្រីកោណ ABC មួយ ហើយ $[AM],[BN]$ និង $[CP]$ ជាមេដ្យាននៃត្រីកោណនេះ
នោះ $BM = MC, CN = NA, AP = PB$ យើងបាន $\frac{BM}{MC} \times \frac{CN}{NA} \times \frac{AP}{PB} = 1$
នោះ $[AM],[BN]$ និង $[CP]$ ប្រសព្វគ្នាត្រង់មួយចំណុច
ឧទាហរណ៍ ២
បង្ហាញថា កម្ពស់ទាំងបីនៃត្រីកោណមួយប្រសព្វគ្នាត្រង់មួយចំណុច ។
សម្រាយ



យក ABC ជាត្រីកោណដែលឲ្យ ហើយ $[AK],[BL]$ និ $[CM]$ ជាកម្ពស់នៃត្រីកោណនេះ
ពិនិត្យ $\triangle BLC \sim \triangle AKC$
យើងបាន $\dfrac{CL}{KC} = \dfrac{BL}{AK}$
$\triangle AMC \sim \triangle ALB$
យើងបាន $\dfrac{AM}{AL} = \dfrac{MC}{BL}$
$\triangle ABK \sim \triangle CBM$
យើងបាន $\dfrac{BK}{BM} = \dfrac{AK}{MC}$
នោះ $\dfrac{CL}{KC} \times \dfrac{AM}{AL} \times \dfrac{BK}{BM} = \dfrac{BL}{AK} \times \dfrac{MC}{BL} \times \dfrac{AK}{MC} = 1$
រឺ $\dfrac{AM}{MB} \times \dfrac{BK}{KC} \times \dfrac{CL}{LA} = 1$
គេបាន $[AK],[BL]$ និង $[CM]$ ប្រសព្វគ្នាត្រង់មួយចំណុច
ដូចនេះ កម្ពស់ទាំងបីនៃត្រីកោណមួយប្រសព្វគ្នាត្រង់មួយចំណុច
ឧទាហរណ៍ ៣
គេឲ្យត្រីកោណ ABC មួយ ។ អង្កត់ $[AD],[BE]$ និង $[CF]$ ប្រសព្វគ្នាត្រង់ចំណុច P ។ បើគេដឹងថា $2BD = 3DC, 3AE = 4EC$ និង $[APF] = 72$ ។ គណនា $[BPF]$ ។
សម្រាយ



ដោយ $[AD]$, $[BE]$ និង $[CF]$ ប្រសព្វគ្នាត្រង់ចំណុច P

តាមទ្រឹស្តីបទ Ceva យើងបាន $\frac{AF}{FB}\times\frac{BD}{DC}\times\frac{CE}{EA}=1$

តាមបម្រាប់ $2BD=3DC$ និង $3AE=4EC$

នោះ $\frac{BD}{DC}=\frac{3}{2}$ និង $\frac{CE}{EA}=\frac{3}{4}$

យើងបាន $\frac{AF}{FB}\times\frac{3}{2}\times\frac{3}{4}=1$ នោះ $\frac{AF}{FB}=\frac{8}{9}$

ម៉្យាងទៀត $\frac{AF}{FB}=\frac{[APF]}{[BPF]}\Rightarrow\frac{[APF]}{[BPF]}=\frac{8}{9}\Rightarrow[BPF]=\frac{9}{8}[APF]$

ដោយ $[APF]=72$

ហេតុនេះ $[BPF]=\frac{9}{8}\times72=81$

ឧទាហរណ៍ ៤

បង្ហាញថា កន្លះបន្ទាត់ពុះមុំទាំងបីនៃត្រីកោណមួយប្រសព្វគ្នាត្រង់មួយចំណុច ។

សម្រាយ



យក $[AX),[BY)$ និង $[CZ)$ ជាកន្លះបន្ទាត់ពុះមុំ A,B និង C រៀងគ្នា
តាមទ្រឹស្តីបទកន្លះបន្ទាត់ពុះមុំយើងបាន
$\frac{AZ}{ZB}=\frac{CA}{BC},\frac{BX}{XC}=\frac{AB}{CA}$ និង $\frac{CY}{YA}=\frac{BC}{AB}$
នោះ $\frac{AZ}{ZB}\times\frac{BX}{XC}\times\frac{CY}{YA}=\frac{CA}{BC}\times\frac{AB}{CA}\times\frac{BC}{AB}=1$
នេះបញ្ជាក់ថា $[AX),[BY)$ និង $[CZ)$ ប្រសព្វគ្នាត្រង់មួយចំណុច

31 ទ្រឹស្តីបទ Menelaus

ទ្រឹស្តីបទ
គេឲ្យត្រីកោណ ABC មួយ ។ យក X,Y និង Z ជាចំណុចនៅលើបន្ទាត់ដែលកើតឡើងដោយជ្រុង $[BC]$,
$[CA]$ និង $[AB]$ រៀងគ្នា ។ បង្ហាញថា បើ X,Y និង Z រត់ត្រង់គ្នា នោះ $\frac{AZ}{ZB}\times\frac{BX}{XC}\times\frac{CY}{YZ}=1$ ។
សម្រាយ



របៀបទី ១

យើងមាន $\frac{AZ}{ZB}=\frac{[YZA]}{[YBZ]}$ និង $\frac{CY}{YA}=\frac{[YZC]}{[YZA]}$

ម៉្យាងទៀត $\frac{BX}{XC}=\frac{[YBX]}{[YXC]}=\frac{[ZBX]}{[ZXC]}=\frac{[YBX]-[ZBX]}{[YXC]-[ZXC]}=\frac{[YBZ]}{[YZC]}$

នោះ $\frac{AZ}{ZB}\times\frac{BX}{XC}\times\frac{CY}{YA}=\frac{[YZA]}{[YZB]}\times\frac{[YBZ]}{[YZC]}\times\frac{[YZC]}{[YZA]}=1$

ដូចនេះ $\frac{AZ}{ZB}\times\frac{BX}{XC}\times\frac{CY}{YZ}=1$



របៀបទី ២

យក D ជាចំណុចមួយនៅលើ (CA) ដែល $[BD]//[XY]$

តាមទ្រឹស្តីបទ Thales យើងបាន $\frac{AZ}{ZB}=\frac{AY}{YD}$ និង $\frac{BX}{XC}=\frac{DY}{YC}$

គេបាន $\frac{AZ}{ZB}\times\frac{BX}{XC}\times\frac{CY}{YA}=\frac{AY}{YD}\times\frac{YD}{YC}\times\frac{CY}{YA}=1$

ដូចនេះ $\frac{AZ}{ZB}\times\frac{BX}{XC}\times\frac{CY}{YZ}=1$
ឧទាហរណ៍ ១
គេឲ្យត្រីកោណ ABC មួយមាន $\angle B=90^{\circ}, BC=3cm$ និង $AB=4cm$ (ដូចរូប) ។ យក D ជាចំណុច មួយនៅលើ $[AC]$ ដែល $AD=1cm$ ហើយ E ជាចំណុចកណ្តាលនៃ $[AB]$ ។ បន្ទាត់ (DE) ជួប (BC) ត្រង់ F ។ គណនា BF ។
សម្រាយ



តាមបម្រាប់ D,E និង F ស្ថិតនៅលើជ្រុង $[CA],[AB][CB)$ នៃត្រីកោណ ABC រៀងគ្នា ហើយចំណុចទាំងបីរត់ត្រង់គ្នា តាមទ្រឹស្តីបទ Menelaus យើងបាន $\frac{AE}{EB}\times\frac{BF}{FC}\times\frac{CD}{DA}=1$
ដោយ $AE=EB=2, DA=1$ និង $FC=FB+BC=BF+3$
ហើយ $CD=AC-AD=\sqrt{BC^2+AB^2}-AD=\sqrt{3^2+4^2}-1=4$
យើងបាន $\frac{BF}{BF+3}\times\frac{4}{1}=1\Rightarrow 4BF=BF+3$
ដូចនេះ $BF=3$
ឧទាហរណ៍ ២
គេឲ្យត្រីកោណ ABC មួយ ហើយ X និង Y ជាចំណុចនៅលើជ្រុង $[BC]$ និង $[CA]$ រៀងគ្នា ។ យក R ជាចំណុចប្រសព្វនៃ $[AX]$ និង $[BY]$ ។ គេឲ្យ $\frac{AY}{YC}=p$ និង $\frac{AR}{RX}=q$ ដែល $0<p<q$ ។ គណនា $\frac{BX}{XC}$ ជាអនុគមន៍នៃ p និង q ។
សម្រាយ



ពិនិត្យត្រីកោណ AXC និង ខ្នាត់ (BRY)

តាមទ្រឹស្តីបទ Menelaus យើងបាន $\dfrac{AR}{RX}\times\dfrac{XB}{BC}\times\dfrac{CY}{YA}=1$

នោះ $\dfrac{BC}{XB}=\dfrac{AR}{RX}\times\dfrac{CY}{YA}=\dfrac{q}{p}\Rightarrow\dfrac{BX+XC}{BX}=\dfrac{q}{p}$

$\Rightarrow 1+\dfrac{XC}{BX}=\dfrac{q}{p}$

$\Rightarrow \dfrac{XC}{BX}=\dfrac{q-p}{p}$

ដូចនេះ $\dfrac{BX}{XC}=\dfrac{p}{q-p}$

ទ្រឹស្តីបទច្រាស

គេឲ្យត្រីកោណ ABC មួយមាន X,Y និង Z ស្ថិតនៅលើ $(BC),(CA)$ និង (AB) រៀងគ្នា ។
បើ $\dfrac{AZ}{ZB}\times\dfrac{BX}{XC}\times\dfrac{CY}{YA}=1$ នោះ X,Y និង Z ជាបីចំណុចរត់ត្រង់គ្នា ។

សម្រាយ

ឧបមាថា Z' ជាចំណុចមួយនៅលើជ្រុង (AB) ដែល X,Y និង Z' រត់ត្រង់គ្នា

តាមទ្រឹស្តីបទ Menelaus យើងបាន $\dfrac{AZ'}{Z'B}\times\dfrac{BX}{XC}\times\dfrac{CY}{YA}=1$ (1)

ដោយ $\dfrac{AZ}{ZB}\times\dfrac{BX}{XC}\times\dfrac{CY}{YA}=1$ (2)

ធ្វើផលធៀបរវាង (1) និង (2) យើងបាន $\dfrac{AZ'}{Z'B}\times\dfrac{ZB}{AZ}=1$

$\Rightarrow \dfrac{AZ'}{Z'B}=\dfrac{AZ}{BZ}$

នេះបញ្ជាក់ថា Z' ត្រួតលើ Z
ដូចនេះ X, Y និង Z រត់ត្រង់គ្នា

32 ស្វ័យគុណចំណុច

32.1 ស្វ័យគុណចំណុច

គេឲ្យរង្វង់ (C) និង ចំណុច P មួយនៅក្នុងប្លង់ (P មិនមែនជាចំណុចនៅលើរង្វង់) ។ បន្ទាត់កាត់តាម P ប្រសព្វរង្វង់ (C) ត្រង់ចំណុច A និង B ហើយបន្ទាត់មួយទៀតកាត់តាម P ដូចគ្នាប្រសព្វរង្វង់ (C) ត្រង់ C និង D ។ គេបានសមភាពមួយកំណត់ដោយ $PA \times PB = PC \times PD$ ។
សម្រាយ

បង្ហាញថា $PA \times PB = PC \times PD$



តាមលក្ខខណ្ឌខាងលើ យើងបានករណីសិក្សាចំនួនពីរដូចខាងក្រោម
+ ករណី P នៅក្នុងរង្វង់
ដោយ $\angle DAP = \angle PCB$ និង $\angle ADP = \angle PBC$ (មុំចារឹកស្កាត់ធ្នូរួម)
នោះ $\triangle ADP \sim \triangle CBP$

យើងបាន $\frac{PA}{PC}=\frac{PD}{PB}$
ដូចនេះ $PA\times PB=PC\times PD$
+ ករណី P នៅក្រៅរង្វង់
យើងមាន $\angle APD=\angle BPC$ (មុំរួម)
និង $\angle PBC=\angle ADP$ (មុំចារឹកស្កាត់ធ្នូរួម)
នោះ $\triangle ADP\sim\triangle CBP$ យើងបាន $\frac{PA}{PC}=\frac{PD}{PB}$
ដូចនេះ $PA\times PB=PC\times PD$

សម្គាល់



បើ (PC) ជាបន្ទាត់ប៉ះទៅនឹងរង្វង់ត្រង់ចំណុច C គេបាន $PC^2=PA\times PB$ ។

ទ្រឹស្តីបទច្រាស

ឧបមាថា A,B,C និង D ជាបួនចំណុចផ្សេងគ្នា ហើយ (AB) និង (CD) ប្រសព្វគ្នាត្រង់ចំណុច P ។ បើ $PA\times PB=PC\times PD$ គេបាន A,B,C និង D ស្ថិតនៅលើរង្វង់តែមួយ ។

សម្រាយ

យើងមាន $PA\times PB=PC\times PD$ នោះ $\frac{PA}{PD}=\frac{PC}{PB}$
ដោយ $\angle APD=\angle CPB$
យើងបាន $\triangle APD\sim\triangle CPB$
វិបាក $\angle PAD=\angle PCB$ និង $\angle ADP=\angle PBC$
ហេតុនេះ A,B,C និង D ស្ថិតនៅលើរង្វង់តែមួយ
តាមទ្រឹស្តីបទខាងលើយើងសង្កេតឃើញថាផលគុណ $PA\times PB$ មិនអាស្រ័យលើទីតាំងនៃចំណុច

A និង B ទេ គឺវាអាស្រ័យតែទៅលើទីតាំងនៃចំណុច P តែប៉ុណ្ណោះ ។ ម៉្យាងទៀត បើយើងយក $[AB]$ ជាអង្កត់ផ្ចិត នៃរង្វង់គេបាន
+ករណី P នៅក្នុងរង្វង់ យើងបាន $PA\times PB=(r-OP)(r+OP)=r^2-OP^2$
+ករណី P នៅក្រៅរង្វង់ យើងបាន $PA\times PB=(OP+r)(OP-r)=OP^2-r^2$
តាមលក្ខណៈនេះគេកំណត់និយមន័យនៃស្វ័យគុណចំណុចដូចខាងក្រោម
និយមន័យ
ឧបមាថារង្វង់ (ω) មានផ្ចិត O និង កាំ r ។ គេកំណត់ស្វ័យគុណនៃចំណុច P ធៀបនឹង (ω) ដោយ $Pow_\omega(P)=OP^2-r^2$ ។

32.2 អ័ក្សរ៉ាឌីកាល់

គេមានរង្វង់ពីរខុសគ្នា $(\omega_1),(\omega_2)$ មានផ្ចិត O_1,O_2 និង កាំ r_1,r_2 រៀងគ្នា ។
សំណុំចំណុច P ដែលមានស្វ័យគុណស្មើគ្នាធៀបទៅនឹង (ω_1) និង (ω_2) គឺជាបន្ទាត់ (Δ) មួយដែលកែង ទៅនឹង (O_1O_2) ។ បន្ទាត់ (Δ) ហៅថាអ័ក្សរ៉ាឌីកាល់នៃរង្វង់ទាំងពីរ ។
សម្រាយ

ក្នុងតម្រុយអរតូណរមេយើងយក $O_1(a,0),O_2(b,0)$ និង $P(x,y)$
គេបាន $Pow_{\omega_1}(P)=O_1P^2-{r_1}^2=(x-a)^2+y^2-{r_1}^2$
ដូចគ្នាដែរ $Pow_{\omega_2}(P)=(x-b)^2+y^2-{r_2}^2$
ដោយ $Pow_{\omega_1}(P)=Pow_{\omega_2}(P)$
$\Rightarrow (x-a)^2+y^2-{r_1}^2=(x-b)^2+y^2-{r_2}^2$
$\Rightarrow (x-a)^2-(x-b)^2={r_1}^2-{r_2}^2$
$\Rightarrow x^2-2ax+a^2-x^2+2bx-b^2={r_1}^2-{r_2}^2$
$\Rightarrow 2(b-a)x={r_1}^2-{r_2}^2+b^2-a^2$
$\Rightarrow (\Delta):x=\frac{1}{2}\left(\frac{{r_1}^2-{r_2}^2}{b-a}\right)+\frac{a+b}{2}$
ជាបន្ទាត់កែងទៅនឹងអ័ក្សអាប់ស៊ីស
ដូចនេះ (Δ) កែងទៅនឹង (O_1O_2)
សម្គាល់

បើ (ω_1) និង (ω_2) កាត់គ្នាត្រង់ពីរចំណុច A និង B យើងបាន $(\Delta)=(AB)$ ។
បើ (ω_1) និង (ω_2) ប៉ះគ្នាត្រង់ចំណុច A នោះ (Δ) ជាបន្ទាត់ប៉ះរួមនៃរង្វង់ទាំងពីរត្រង់ចំណុច A ។

32.3 ផ្ចិតរ៉ាឌីកាល់

គេមាន $(\omega_1),(\omega_2)$ និង (ω_3) ជារង្វង់បីផ្សេងគ្នាមានផ្ចិត O_1,O_2 និង O_3 មិនរត់ត្រង់គ្នា ។ យក (Δ_1) ជាអ័ក្សរ៉ាឌីកាល់នៃ (ω_1) និង (ω_2), (Δ_2) ជាអ័ក្សរ៉ាឌីកាល់នៃ (ω_2) និង (ω_3)ហើយ (Δ_3) ជាអ័ក្សរ៉ាឌីកាល់នៃ (ω_3) និង (ω_1) ។ គេបាន $(\Delta_1),(\Delta_2)$ និង (Δ_3) ប្រសព្វគ្នាត្រង់មួយចំណុច ។

សម្រាយ

យក I ជាចំណុចប្រសព្វនៃ (Δ_1) និង (Δ_2) ដើម្បីបង្ហាញថា $(\Delta_1),(\Delta_2)$ និង (Δ_3) ប្រសព្វគ្នាត្រង់មួយចំណុច យើងគ្រាន់តែបង្ហាញថា (Δ_3) កាត់តាម I

ដោយ $I \in (\Delta_1) \Rightarrow Pow_{\omega_1}(I) = Pow_{\omega_2}(I)$

$I \in (\Delta_2) \Rightarrow Pow_{\omega_2}(I) = Pow_{\omega_3}(I)$

នោះ $Pow_{\omega_1}(I) = Pow_{\omega_3}(I)$

យើងបាន $I \in (\Delta_3)$

ឧទាហរណ៍ ១

គេឲ្យ $[BD)$ ជាកន្លះបន្ទាត់ពុះមុំ B នៃត្រីកោណ ABC ។ រង្វង់ចារឹកក្រៅត្រីកោណ BCD និងត្រីកោណ ABD កាត់ជ្រុង $[AB]$ និង $[BC]$ ត្រង់ចំណុច E និង F រៀងគ្នា ។ បង្ហាញថា $AE = CF$ ។

សម្រាយ



តាមស្វ័យគុណចំណុចយើងបាន $AE \times EB = AD \times AC$

និង $CF \times CB = CD \times CA$

នោះ $\dfrac{AE \times AB}{CF \times CB} = \dfrac{AD}{CD} \Rightarrow \dfrac{AE}{CF} = \dfrac{AD}{CD} \times \dfrac{CB}{AB}$

តាមទ្រឹស្តីបទកន្លះបន្ទាត់ពុះមុំយើងបាន $\frac{AB}{AD}=\frac{CB}{CD}\Rightarrow\frac{AB}{CB}=\frac{AD}{CD}$
នោះ $\frac{AE}{CF}=\frac{AB}{CB}\times\frac{CB}{AB}=1$
ដូចនេះ $AE=CF$
ឧទាហរណ៍ ២
(IMO 2009)
យក O ជាផ្ចិតរង្វង់ចារឹកក្រៅត្រីកោណ ABC ហើយ P និង Q ជាចំណុចនៅលើជ្រុង $[CA]$ និង $[AB]$ រៀងគ្នា ។ រង្វង់ (Γ) កាត់តាមចំណុចកណ្តាលនៃ $[BP],[CQ]$ ហើយប៉ះទៅនឹង $[PQ]$ ត្រង់ចំណុចកណ្តាល L,K និង M រៀងគ្នា ។ បង្ហាញថា $OP=OQ$។

សម្រាយ



បង្ហាញថា $OP=OQ$
ដោយ M និង K ជាចំណុចកណ្តាលនៃ $[PQ]$ និង $[QC]$ រៀងគ្នា
នោះ $[MK]$ ជាបាតមធ្យមនៃត្រីកោណ PQC
គេបាន $[MK]//[PC]\Rightarrow[MK]//[AC]$
នោះ $\angle APQ=\angle KMP$ (មុំឆ្លាស់ក្នុង)
តែ $\angle KMP=\angle KLM$ (មុំចារឹក និង ចារឹកពិសេសស្កាត់ធ្នូរួម)
នោះ $\angle APQ=\angle KLM$
ដូចគ្នាដែរ $[AB]//[LM]$ នោះ $\angle AQP=\angle LKM$
យើងបាន $\triangle APQ\sim\triangle MLK$
វិបាក $\frac{AP}{ML}=\frac{AQ}{MK}\Rightarrow\frac{AP}{AQ}=\frac{ML}{MK}$

ម៉្យាងទៀត$ML = \dfrac{BQ}{2}$ និង $MK = \dfrac{PC}{2}$

យើងបាន $\dfrac{AP}{AQ} = \dfrac{\frac{BQ}{2}}{\frac{PC}{2}} = \dfrac{BQ}{PC} \Rightarrow PA \times PC = QA \times QB$

$\Rightarrow Pow_O(P) = Pow_O(Q) \Rightarrow OP^2 - R^2 = OQ^2 - R^2 \Rightarrow OP^2 = OQ^2$

ដូចនេះ $OP = OQ$

ឧទាហរណ៍ ៣

(IMO 1985)

គេឲ្យត្រីកោណ ABC មួយ និង រង្វង់ផ្ចិត O មួយកាត់តាមកំពូល A និង C ហើយកាត់ជ្រុង $[AB]$ និង $[BC]$ ត្រង់ K និង N រៀងគ្នា ។ ឧបមាថារង្វង់ចារឹកក្រៅត្រីកោណ ABC និង KBN ជួបគ្នាត្រង់ពីរចំណុចផ្សេងគ្នា គឺ B និង M ។ បង្ហាញថា $\angle OMB = 90^\circ$ ។

សម្រាយ



យក I ជាផ្ចិតរ៉ាឌីកាល់នៃរង្វង់ទាំងបី និង r ជាកាំរង្វង់ផ្ចិត O

ដោយ រង្វង់ចារឹកក្រៅត្រីកោណ ABC និង ត្រីកោណ KBN ប្រសព្វគ្នាត្រង់ B និង M

នោះ (BM) ជាអ័ក្សរ៉ាឌីកាល់នៃរង្វង់ទាំងពីរ $\Rightarrow I \in (BM)$

ដូចគ្នាដែរ $I \in (NK)$ និង $I \in (CA)$ ពោលគឺ (BM), (NK) និង (CA) ប្រសព្វគ្នាត្រង់ចំណុច I

យើងបាន $IM \times IB = IK \times IN = OI^2 - r^2$ (1)

ម៉្យាងទៀត $\angle IMN = 180^\circ - \angle BMN = 180^\circ - \angle NKA = 180^\circ - \angle NCI$

ព្រោះ $MBKN$ ជាចតុកោណចារឹកក្នុងរង្វង់

នោះ $\angle IMN + \angle NCI = 180^\circ$

នោះ $IMNC$ ជាចតុកោណចារឹកក្នុងរង្វង់

យើងបាន $BM \times BI = BN \times NC = OB^2 - r^2$ (2)

ដក (1) និង (2) យើងបាន $IM \times IB - BM \times BI = OI^2 - OB^2$
$\Rightarrow IB(IM - BM) = OI^2 - OB^2$
$\Rightarrow (IM + BM)(IM - BM) = OI^2 - OB^2$
$\Rightarrow IM^2 - BM^2 = OI^2 - OB^2$
$\Rightarrow IM^2 + OB^2 = OI^2 + BM^2$
តាមច្បាប់អង្កត់ទ្រូងកែងគ្នាយើងបាន $\angle OMB = 90^\circ$

វិសមភាពសំខាន់ៗ

1. វិសមភាពនៃមធ្យម

បើ $a_1, a_2, ..., a_n$ ជា n ចំនួនពិតវិជ្ជមាន គេកំណត់យក

$AM = \dfrac{a_1 + a_2 + ... + a_n}{n}$ ហៅថា មធ្យមនព្វន្ត (Arithmetic Mean)

$GM = \sqrt[n]{a_1 a_2 ... a_n}$ ហៅថា មធ្យមធរណីមាត្រ (Geometric Mean)

$QM = \sqrt{\dfrac{a_1^2 + a_2^2 + ... + a_n^2}{n}}$ ហៅថា មធ្យមរឹសការេ (Quadratic Mean)

និង $HM = \dfrac{n}{\frac{1}{a_1} + \frac{1}{a_2} + ... + \frac{1}{a_n}}$ ហៅថា មធ្យមអាម៉ូនិច (Harmonic Mean)។

យើងបាន $QM \geq AM \geq GM \geq HM$ សមភាពកើតឡើងពេល $a_1 = a_2 = ... = a_n$ ។

សម្គាល់

វិសមភាព $AM \geq GM$ មានអ្នកខ្លះហៅថា វិសមភាព Cauchy ។

2. វិសមភាព Cauchy-Schwarz

ចំពោះ $2n$ ចំនួនពិត $a_1, a_2, ..., a_n$ និង $b_1, b_2, ..., b_n$ គេបាន

$(a_1 b_1 + a_2 b_2 + ... + a_n b_n)^2 \leq \left(a_1^2 + a_2^2 + ... + a_n^2\right)\left(b_1^2 + b_2^2 + ... + b_n^2\right)$

សមភាពពេល $\vec{u} = (a_1, a_2, ..., a_n),\ \ \vec{v} = (b_1, b_2, ..., b_n)$ កូលីនេអ៊ែរគ្នា។

3. មធ្យមស្វ័យគុណ

យក $a_1, a_2, ..., a_n$ ជា n ចំនួនពិតវិជ្ជមានបំពេញលក្ខខណ្ឌ $\sum_{i=1}^{n} a_i = 1$ ។

ចំពោះ $x_1, x_2, ..., x_n$ ជាចំនួនពិតវិជ្ជមាន គេកំណត់យក

$M_{-\infty} = \min\{x_1, x_2, ..., x_k\}$

$M_{\infty} = \max\{x_1, x_2, ..., x_k\}$

$M_0 = x_1^{a_1} x_2^{a_2} ... x_n^{a_n}$

$M_t = \left(a_1 x_1^t + a_2 x_2^t + ... + a_k x_k^t\right)^{\frac{1}{t}}$ ចំពោះ t ជាចំនួនពិតមិនសូន្យ ។

គេបាន $M_{-\infty} \leq M_s \leq M_t \leq M_{\infty}$ ចំពោះ $s \leq t$។

4. វិសមភាពតម្រៀប (Rearrangement)

បើ $a_1 \leq a_2 \leq ... \leq a_n$ និង $b_1 \leq b_2 \leq ... \leq b_n$ ជាចំនួនពិត និង $c_1, c_2, ..., c_n$ ជាចម្លាស់នៃ $b_1 \leq b_2 \leq ... \leq b_n$ គេបាន វិសមភាព

$$a_1b_n+a_2b_{n-1}+...+a_nb_1 \le a_1c_1+a_2c_2+...+a_nc_n$$
$$\le a_1b_1+a_2b_2+...+a_nb_n$$

សមភាពពេល $a_1=a_2=...=a_n$ រឺ $b_1=b_2=...=b_n$ ។

5. **វិសមភាព** Chebyshev
   គេមាន $a_1,a_2,...,a_n$ និង $b_1,b_2,...,b_n$ ជាពីរស្វ៊ីតចំនួនពិតវិជ្ជមាន ។
   + បើ $a_1 \le a_2 \le ... \le a_n$ និង $b_1 \le b_2 \le ... \le b_n$ គេបាន
   $\frac{1}{n}(x_1+x_2+...+x_n)(y_1+y_2+...+y_n) \le x_1y_1+x_2y_2+...+x_ny_n$ ។
   + បើ $a_1 \le a_2 \le ... \le a_n$ និង $b_1 \ge b_2 \ge ... \ge b_n$ គេបាន
   $\frac{1}{n}(x_1+x_2+...+x_n)(y_1+y_2+...+y_n) \ge x_1y_1+x_2y_2+...+x_ny_n$ ។

6. **វិសមភាព** Schur
   ចំពោះគ្រប់ x,y,z ជាចំនួនពិតវិជ្ជមាន យើងបាន វិសមភាព
   $x^r(x-y)(x-z)+y^r(y-z)(y-x)+z^r(z-x)(z-y) \ge 0$
   សមភាពពេល $x=y=z$ រឺ ពីរក្នុងចំណោម $x,\ y,\ z$ ស្មើគ្នា ហើយមួយចំនួនទៀតស្មើនឹង 0។

7. **វិសមភាព** Jensen
   បើ f ផតលើ $[a,b]$ និង$t_1,t_2,...,t_n \in [0,1]$ ដែល $\sum_{i=1}^{n} t_i = 1$ គេបាន
   $f(t_1x_1+t_2x_2+...+t_nx_n) \le t_1f(x_1)+t_2f(x_2)+...+t_nf(x_n)$
   ចំពោះគ្រប់ $x_1,x_2,...,x_n \in [a,b]$ ។
   • ករណី $t_1=t_2=...=t_n=\frac{1}{n}$ យើងបាន
   $f\left(\frac{x_1+x_2+...+x_n}{n}\right) \ge \frac{f(x_1)+f(x_2)+...+f(x_n)}{n}$

   សម្គាល់

   បើ f ប៉ោងលើ $[a,b]$ នោះវិសមភាពប្តូរទិសដៅ ។

ជំពូក II

ប្រធានលំហាត់

លំហាត់ ១
គេឲ្យ A, B និង C ជាមុំក្នុងត្រីកោណមួយ ។ បង្ហាញថា

1. $\sin A + \sin B + \sin C = 4\cos\frac{A}{2}\cos\frac{B}{2}\cos\frac{C}{2}$
2. $\sin 2A + \sin 2B + \sin 2C = 4\sin A\sin B\sin C$
3. $\sin 3A + \sin 3B + \sin 3C = -4\cos\frac{3A}{2}\cos\frac{3B}{2}\cos\frac{3C}{2}$
4. $\sin 4A + \sin 4B + \sin 4C = -4\sin 2A\sin 2B\sin 2C$
5. $\cos A + \cos B + \cos C = 1 + 4\sin\frac{A}{2}\sin\frac{B}{2}\sin\frac{C}{2}$
6. $\cos A + \cos B + \cos C = -1 - 4\cos A\cos B\cos C$
7. $\cos 3A + \cos 3B + \cos 3C = 1 - 4\sin\frac{3A}{2}\sin\frac{3B}{2}\sin\frac{3C}{2}$
8. $\tan A + \tan B + \tan C = \tan A\tan B\tan C$
9. $\tan\frac{A}{2}\tan\frac{B}{2} + \tan\frac{B}{2}\tan\frac{C}{2} + \tan\frac{C}{2}\tan\frac{A}{2} = 1$
10. $\cot A\cot B + \cot B\cot C + \cot C\cot A = 1$
11. $\cot\frac{A}{2} + \cot\frac{B}{2} + \cot\frac{C}{2} = \cot\frac{A}{2}\cot\frac{B}{2}\cot\frac{C}{2}$ ។

លំហាត់ ២
គេឲ្យ A, B និង C ជាមុំក្នុងត្រីកោណមួយ ។ បង្ហាញថា

1. $\sin A+\sin B+\sin C\leq \frac{3\sqrt{3}}{2}$
2. $1<\cos A+\cos B+\cos C\leq \frac{3}{2}$
3. $\tan A+\tan B+\tan C\geq 3\sqrt{3}$ (A,B និង C ជាមុំស្រួច)
4. $\cot A+\cot B+\cot C\geq \sqrt{3}$
5. $\sin^2 A+\sin^2 B+\sin^2 C\leq \frac{9}{2}$
6. $\cos^2 A+\cos^2 B+\cos^2 C\geq \frac{3}{4}$
7. $\tan^2 A+\tan^2 B+\tan^2 C\geq 9$ (A,B និង C ជាមុំស្រួច)
8. $1<\sin\frac{A}{2}+\sin\frac{B}{2}+\sin\frac{C}{2}\leq \frac{3}{2}$
9. $2<\cos\frac{A}{2}+\cos\frac{B}{2}+\cos\frac{C}{2}\leq \frac{3\sqrt{3}}{2}$
10. $\tan\frac{A}{2}+\tan\frac{B}{2}+\tan\frac{C}{2}\geq \sqrt{3}$
11. $\frac{3}{4}\leq \sin^2\frac{A}{2}+\sin^2\frac{B}{2}+\sin^2\frac{C}{2}<1$
12. $2<\cos^2\frac{A}{2}+\cos^2\frac{B}{2}+\cos^2\frac{C}{2}\leq \frac{9}{4}$
13. $\tan^2\frac{A}{2}+\tan^2\frac{B}{2}+\tan^2\frac{C}{2}\geq 1$
14. $\sin A\sin B\sin C\leq \frac{3\sqrt{3}}{8}$
15. $\cos A\cos B\cos C\leq \frac{1}{8}$
16. $\sin\frac{A}{2}\sin\frac{B}{2}\sin\frac{C}{2}\leq \frac{1}{8}$
17. $\cos\frac{A}{2}\cos\frac{A}{2}\cos\frac{A}{2}\leq \frac{3\sqrt{3}}{8}$
18. $\tan\frac{A}{2}\tan\frac{B}{2}\tan\frac{C}{2}\leq \frac{1}{3\sqrt{3}}$

លំហាត់ ៣

ក្នុងត្រីកោណ ABC មួយ ។ បង្ហាញថា

1. $(p-a)(p-b)(p-c) \leq \frac{1}{8}abc$
2. $\frac{1}{p-a}+\frac{1}{p-b}+\frac{1}{p-c} \geq 2\left(\frac{1}{a}+\frac{1}{b}+\frac{1}{c}\right)$
3. $a^2(p-b)(p-c)+b^2(p-c)(p-a)+c^2(p-a)(p-b) \geq 4S^2$
4. $p^2 \geq 3\sqrt{3}S$
5. $\frac{a}{b+c-a}+\frac{b}{c+a-b}+\frac{c}{a+b-c} \geq 3$
6. $a^2(b+c-a)+b^2(c+a-b)+c^2(a+b-c) \leq 3abc$
7. $a(b^2+c^2-a^2)+b(c^2+a^2-b^2)+c(a^2+b^2-c^2) \leq 3abc$
8. $a(b-c)^2+b(c-a)^2+c(a-b)^2+4abc > a^3+b^3+c^3$
9. $a(b^2+c^2)+b(c^2+a^2)+c(a^2+b^2) \leq 2(a^3+b^3+c^3)$
10. $\frac{a}{b+c}+\frac{b}{c+a}+\frac{c}{a+b}+\frac{3abc}{(a+b)(b+c)(c+a)} < 2$
11. $ab+bc+ca \leq 9R^2$
12. $ab+bc+ca \geq 36r^2$
13. $\frac{1}{a}+\frac{1}{b}+\frac{1}{c} \geq \sqrt{\frac{3}{2Rr}}$
14. $\frac{1}{a+b-c}+\frac{1}{b+c-a}+\frac{1}{c+a-b} \geq \frac{3\sqrt[4]{3}}{2\sqrt{S}}$
15. $a^2+b^2+c^2 \leq 2(ab+bc+ca)-4\sqrt{3}S$
16. $a^2+b^2+c^2 \geq (a-b)^2+(b-c)^2+(c-a)^2+4\sqrt{3}S$
17. $a^2+b^2+c^2 \geq \frac{36}{35}\left(p^2+\frac{abc}{p}\right)$
18. $a^4+b^4+c^4 \geq 16S^2$
19. $r \leq \frac{R}{2}$

20. $\frac{1}{a}(l_a+l_b)+\frac{1}{b}(l_b+l_c)\frac{1}{c}(l_c+l_a)\leq 3\sqrt{3}$

21. $l_a+l_b+l_c\leq \frac{\sqrt{3}}{2}(a+b+c)$

22. $2\sqrt{3}l_a\leq \frac{2(b+c)-a}{2\sqrt{3}}$

23. $m_a+m_b+m_c\leq r+4R$

24. $m_a+m_b+m_c\leq \frac{9R}{2}$

25. $m_a^2+m_b^2+m_c^2\geq 3\sqrt{3}S$

26. $\frac{1}{(m_a+m_b-m_c)^2}+\frac{1}{(m_b+m_c-m_a)^2}+\frac{1}{(m_c+m_a-m_b)^2}\geq \frac{4}{3R^2}$

27. $\frac{4}{5}(m_am_b+m_bm_c+m_cm_a)<ab+ab+ca$
. $<\frac{20}{9}(m_am_b+m_bm_c+m_cm_a)$

28. $\frac{m_a}{h_a}+\frac{m_b}{h_b}+\frac{m_c}{h_c}\leq 1+\frac{R}{r}$

29. $\frac{h_a}{h_b}+\frac{h_b}{h_c}+\frac{h_c}{h_a}\geq \frac{h_b}{h_a}+\frac{h_c}{h_b}+\frac{h_a}{h_c}$ ករណី $A\geq B\geq C$

30. $\frac{h_a^2}{bc}+\frac{h_b^2}{ca}+\frac{h_c^2}{ab}\geq \frac{9r^2}{R^2}$

លំហាត់ ៤

គេអោយត្រីកោណ ABC មួយ។ បង្ហាញថា

1. $\left(\frac{1}{a}+\frac{1}{b}\right)l_c+\left(\frac{1}{b}+\frac{1}{c}\right)l_a+\left(\frac{1}{c}+\frac{1}{a}\right)l_b=2\left(\cos\frac{A}{2}+\cos\frac{B}{2}+\cos\frac{C}{2}\right)$
2. $r=p\tan\frac{A}{2}\tan\frac{B}{2}\tan\frac{C}{2}$
3. $r=\frac{a\sin\frac{B}{2}\sin\frac{C}{2}}{\cos\frac{A}{2}}$
4. $\frac{r}{4R}=\sin\frac{A}{2}\sin\frac{B}{2}\sin\frac{C}{2}$

5. $R=\dfrac{p}{4\cos\frac{A}{2}\cos\frac{B}{2}\cos\frac{C}{2}}$

6. $a\cos A+b\cos B+c\cos C=\dfrac{2pr}{R}$

7. $\dfrac{r+4R}{p}=\tan\dfrac{A}{2}+\tan\dfrac{B}{2}+\tan\dfrac{C}{2}$

8. $a\cot A+b\cot B+c\cot C=2(r+R)$

លំហាត់ ៥

គេឲ្យត្រីកោណ ABC មានរង្វាស់ជ្រុង $BC=a, CA=b$ និង $AB=c$។

បង្ហាញថា $\cot A+\cot B+\cot C=\dfrac{a^2+b^2+c^2}{4S}$។

លំហាត់ ៦

គេឲ្យចតុកោណប៉ោង $ABCD$ មានក្រលាផ្ទៃ S និងកន្លះបរិមាត្រស្មើនឹង 2។
បង្ហាញថា $S\leq 1$ ។

លំហាត់ ៧

យក I ជាផ្ចិតរង្វង់ចារឹកក្នុងត្រីកោណ ABC ។ R និង r ជាកាំរង្វង់ចារឹកក្រៅ និងចារឹកក្នុងនៃត្រីកោណ ABC ។ បង្ហាញថា

ក) $r=4R\sin\dfrac{A}{2}\sin\dfrac{B}{2}\sin\dfrac{C}{2}$

ខ) $IA\times IB\times IC=4Rr^2$ ។

លំហាត់ ៨

តាមចំណុចមួយនៅក្នុងត្រីកោណមួយ គេគូសបន្ទាត់ស្របទៅនឹងជ្រុងទាំងបីនៃត្រីកោណនោះ។ បន្ទាត់ ទាំងនេះចែកត្រីកោណជា ៦ ចំណែក ក្នុងនោះមានបីចំណែកជាត្រីកោណមានក្រលាផ្ទៃតាង ដោយ S_1,S_2 និង S_3។ គណនាក្រលាផ្ទៃនៃត្រីកោណជាអនុគមន៍នៃ S_1,S_2 និង S_3។

លំហាត់ ៩

គេឲ្យ $ABCD$ ជាការេមួយហើយ P ជាចំណុចមួយនៅក្នុងការេនេះដែល $\angle PAB=\angle PBA=15^\circ$។
បង្ហាញថា PCD ជាត្រីកោណសម័ង្ស។

លំហាត់ ១០

ត្រីកោណ ABC មានមុំទាំងបីជាមុំស្រួច។ យក $[AM],[BN]$ និង $[CL]$ ជាកម្ពស់ ហើយ H ជាអរតូសង់នៃត្រីកោណនេះ។ បង្ហាញថា

ក) $\dfrac{HM}{AM}+\dfrac{HN}{BN}+\dfrac{HL}{CL}=1$

ខ) $\dfrac{AM}{HM}+\dfrac{BN}{HN}+\dfrac{CL}{HL}\geq 9$

គ) $AM \times HM \le \frac{BC^2}{4}$ ។

លំហាត់ ១១

គេឲ្យត្រីកោណ ABC មួយ ហើយ O ជាចំណុចមួយនៅក្នុងត្រីកោណនេះ។ បន្ទាត់ $(OA),(OB)$ និង (OC) កាត់ជ្រុង $[BC],[CA]$ និង $[AB]$ ត្រង់ P,Q និង R រៀងគ្នា។ បង្ហាញថា

ក) $\frac{OP}{AP}+\frac{OQ}{BQ}+\frac{OR}{CR}=1$

ខ) $\frac{AP}{OP}+\frac{BQ}{OQ}+\frac{CR}{OR}\ge 9$ ។

លំហាត់ ១២

គេឲ្យត្រីកោណ ABC មួយមានមេដ្យាន m_a,m_b និង m_c គូសចេញពីកំពូល A,B និងC រៀងគ្នា។ បង្ហាញថា $m_a m_b m_c \le \frac{27R^3}{8}$ ។

លំហាត់ ១៣

គេឲ្យត្រីកោណ ABC មានមុំទាំងបីជាមុំស្រួច ។ បង្ហាញថា

ក) $h_a+h_b+h_c \ge 9r$

ខ) $\frac{1}{m_a}+\frac{1}{m_b}+\frac{1}{m_c}\ge\frac{2}{R}$ ។

លំហាត់ ១៤

គេឲ្យត្រីកោណមួយមានរង្វាស់ជ្រុង a,b,c ហើយ l_a,l_b,l_c ជាប្រវែងកន្លះបន្ទាត់ពុះមុំក្នុងទាំងបីនៃត្រីកោណនេះ។ បង្ហាញថា $\frac{1}{a}+\frac{1}{b}+\frac{1}{c}<\frac{1}{l_a}+\frac{1}{l_b}+\frac{1}{l_c}$ ។

លំហាត់ ១៥

(វិសមភាព Ptolemy)

គេឲ្យ $ABCD$ ជាចតុកោណប៉ោង។ បង្ហាញថា $AB\times CD+AD\times BC\ge AC\times BD$។

លំហាត់ ១៦

(IMO, 1991)

គេឲ្យត្រីកោណ ABC មួយហើយ I ជាផ្ចិតរង្វង់ចារឹកក្នុងនៃត្រីកោណនេះ។

កន្លះបន្ទាត់ពុះមុំក្នុងនៃមុំ A,B និង C កាត់ជ្រុង $[BC],[CA],[AB]$ ត្រង់ A',B' និង C'រៀងគ្នា។ បង្ហាញថា $\frac{1}{4}<\frac{AI\times BI\times CI}{AA'\times BB'\times CC'}\le\frac{8}{27}$។

លំហាត់ ១៧

គេឲ្យត្រីកោណ ABC មួយមានមុំទាំងបីជាមុំស្រួច និង a,b,c ជារង្វាស់ជ្រុងនៃត្រីកោណនេះ។ បើ K ជាក្រលាផ្ទៃនៃត្រីកោណនេះ ចូរបង្ហាញថា

$$\sqrt{a^2b^2-4K^2}+\sqrt{b^2c^2-4K^2}+\sqrt{c^2a^2-4K^2}=\frac{a^2+b^2+c^2}{2}$$ ។

លំហាត់ ១៨

គេឲ្យ P ជាចំណុចមួយនៅក្នុងត្រីកោណ ABC។យក D,E និង F ជាចំណោលកែងនៃ P លើជ្រុង $[BC],[CA]$ និង $[AB]$ រៀងគ្នា។ កំណត់ទីតាំងនៃ P ដើម្បីឲ្យផលបូក $\frac{BC}{PD}+\frac{CA}{PE}+\frac{AB}{PF}$ មានតម្លៃអប្បបរមា ។

លំហាត់ ១៩

គេឲ្យ p និងR ជាកន្លះបរិមាត្រ និងកាំរង្វង់ចារឹកក្រៅនៃត្រីកោណ ABC រៀងគ្នា។ កំណត់ប្រភេទត្រីកោណ ABC ដើម្បីឲ្យផលធៀប $\frac{p}{R}$ មានតម្លៃធំបំផុត។

លំហាត់ ២០

គេឲ្យត្រីកោណកែង ABC មួយកែងត្រង់ C មាន $AC=1$ និង $\angle BAC=x^\circ$ ។
យក D ជាចំណុចមួយនៅលើអ៊ីប៉ូតេនុស $[AB]$ ដែល$AD=1$ និង E ជាចំណុចមួយនៅលើ $[BC]$ ដែល $\angle EDC=x^\circ$ ។ បន្ទាត់ (EF) កែងនឹង $[BC]$ ត្រង់ E ហើយជួប $[AB]$ ត្រង់ F ។
គណនា $\lim\limits_{x\to 0} EF$ ។

លំហាត់ ២១

បង្ហាញថារង្វាស់ជ្រុង a,b និង c នៃត្រីកោណមួយជាឫសនៃសមីការដឺក្រេទី ៣
$X^3-2pX^2+\left(r^2+p^2+4rR\right)X-4prR=0$ ក្នុងនោះ $p,\ r$ និង R ជាកន្លះបរិមាត្រ កាំរង្វង់ចារឹកក្នុង និងកាំរង្វង់ចារឹកក្រៅរៀងគ្នានៃត្រីកោណ ABC។

លំហាត់ ២២

(IMO Shortlist, 1988)
គេឲ្យ r និង R ជាកាំរង្វង់ចារឹកក្នុង និង ក្រៅនៃត្រីកោណ ABC រៀងគ្នា។
បង្ហាញថា $\sin\frac{A}{2}\sin\frac{B}{2}+\sin\frac{B}{2}\sin\frac{C}{2}+\sin\frac{C}{2}\sin\frac{A}{2}\le\frac{5}{8}+\frac{r}{4R}$ ។

លំហាត់ ២៣

(IMO Shortlist, 1997)
គេឲ្យឆកោណ $ABCDEF$ មួយកំណត់ដោយ $AB=BC,CD=DE$ និង $EF=FA$។ បង្ហាញថា $\frac{BC}{BE}+\frac{DE}{DA}+\frac{FA}{FC}\ge\frac{3}{2}$ ។

លំហាត់ ២៤

ត្រីកោណ ABC មួយមានរង្វាស់ជ្រុង a,b និងc។
បង្ហាញថា $\frac{\cos A}{b\cos C+c\cos B}+\frac{\cos B}{a\cos C+c\cos A}+\frac{\cos C}{b\cos A+a\cos B}=\frac{a^2+b^2+c^2}{2abc}$។

លំហាត់ ២៥

យក M ជាចំណុចប្រសព្វនៃអង្កត់ទ្រូង $[AC]$ និង $[BD]$ នៃចតុកោណប៉ោង $ABCD$ ។កន្លះបន្ទាត់ពុះមុំ $\angle ACD$ កាត់ $[BA]$ ត្រង់K។
បើ $MA\times MC+MA\times CD=MB\times MD$ បង្ហាញថា $\angle BKC=\angle CDB$។

លំហាត់ ២៦

ត្រីកោណ ABC មួយមានរង្វាស់ជ្រុង a,b និង c ហើយ ចារឹកក្រៅរង្វង់ផ្ចិត O មួយ។ គេសង់បន្ទាត់បី ប៉ះទៅនឹងរង្វង់ផ្ចិត O ហើយស្របរៀងគ្នានឹងជ្រុងទាំងបីនៃត្រីកោណ ABC ។ បន្ទាត់ប៉ះនីមួយៗ និង ជ្រុងពីរផ្សេងទៀតនៃត្រីកោណ ABC ដែលមិនស្របនឹងវា ផ្គុំបានត្រីកោណថ្មី។ ត្រីកោណថ្មីទាំង បីនោះ ចារឹកក្រៅរង្វង់ទាំងបីរៀងគ្នា ។បង្ហាញថា រង្វង់ចារឹកក្នុងត្រីកោណទាំងបួននោះមានផលបូក ក្រឡាផ្ទៃស្មើ នឹង $\left(\frac{\pi S^2}{p^4}\right)\left[p^2+(p-a)^2+(p-b)^2+(p-c)^2\right]$ ដែលS ជាក្រឡាផ្ទៃ និង p ជាកន្លះ បរិមាត្រនៃត្រី- កោណ ABC។

លំហាត់ ២៧

ក្នុងត្រីកោណ ABC មួយបង្ហាញថា

ក) $\frac{h_b}{l_b} \geq \sqrt{\frac{2r}{R}}$

ខ) $r_a l_a + r_b l_b + r_c l_c \leq p^2$

គ) $m_a l_a + m_b l_b + m_c l_c \geq p^2$

ឃ) $\frac{1}{r_a}+\frac{1}{r_b}+\frac{1}{r_c} \geq 3\sqrt[3]{\frac{4R^2}{r(a+b+c)abc}}$

ង) $\frac{a^3}{r_a}+\frac{b^3}{r_b}+\frac{c^3}{r_c} \leq \frac{abc}{r}$

ច) $\frac{a}{r_a}+\frac{b}{r_b}+\frac{c}{r_c} \leq \frac{9R}{p}$

ឆ) $r_a^2+r_b^2+r_c^2 \geq l_a^2+l_b^2+l_c^2$

ជ) $\frac{a^2}{r_a-r}+\frac{b^2}{r_b-r}+\frac{c^2}{r_c-r} \leq 9R$

ឈ) $\frac{3S}{R} \leq a\cos^2\frac{A}{2}+b\cos^2\frac{B}{2}+c\cos^2\frac{C}{2} \leq \frac{3S}{2r}$

ញ) $\sqrt{a+b+c} < \sqrt{r_a \sin A}+\sqrt{r_b \sin B}+\sqrt{r_c \sin C} \leq \frac{3}{2}\sqrt{a+b+c}$

ដ) $\frac{\sqrt{p}abc\sin C}{ab\sin^2 C+pc} \leq \frac{1}{2}\sqrt{abc} < \frac{ab\sin^2 C+pc}{4\sqrt{p}\sin C}$

ឋ) $\frac{8}{3}\left(\frac{S}{R}\right)^2 \leq \frac{ab\sqrt{ab}}{a+b}+\frac{bc\sqrt{bc}}{b+c}+\frac{ca\sqrt{ca}}{c+a} \leq \frac{8}{3}\left(\frac{S}{2R}\right)^2$

លំហាត់ ២៨

(ភ្នំពេញ, 2015)

ក្នុងរូប $ABCD$ ជាការេដែលមានប្រវែងជ្រុងស្មើនឹង 1។អង្កត់ $[PQ]$ បង្កើតបានមុំ 45° ជាមួយជ្រុង $[AB]$ ហើយ ជាអង្កត់ផ្ចិតនៃកន្លះរង្វង់ដូចរូប។ កន្លះរង្វង់នេះប៉ះនឹងជ្រុងការេត្រង់ចំណុច X និងY ។រកផ្ទៃក្រឡា កន្លះរង្វង់។

លំហាត់ ២៩

រង្វង់ពីរកាត់គ្នាត្រង់ចំណុចA និង B ។ បន្ទាត់ចល័ត (MN) កាត់តាម A ហើយជួបរង្វង់ធំត្រង់ M និង រង្វង់តូចត្រង់ N ។ បង្ហាញថា $\dfrac{BM}{BN}$ មានតម្លៃថេរ កាលណា (MN) វិលជុំវិញចំណុច A។

លំហាត់ ៣០

ត្រីកោណ ABC មួយមានមុំទាំងបីជាមុំស្រួច។ កន្លះបន្ទាត់ពុះក្នុងនៃមុំ $\angle BAC$ ជួបជ្រុង $[BC]$ ត្រង់ D ហើយ ជួបរង្វង់ចារឹកក្រៅត្រីកោណ ABC ត្រង់ E ។ តាមចំណុច Dគេគូសបន្ទាត់កែងនឹងជ្រុង $[AB]$ និង $[AC]$ រៀងគ្នាត្រង់ចំណុចM និងN។
បង្ហាញថា $S_{AMEN} = S_{\triangle ABC}$។

លំហាត់ ៣១

ចំណុច M,K,L ត្រូវគេដៅរៀងគ្នាលើជ្រុង $[AB],[BC],[CA]$ នៃត្រីកោណ ABC ។ បង្ហាញថា យ៉ាង តិចក្រឡាផ្ទៃត្រីកោណមួយក្នុងចំណោមត្រីកោណ MAL, KBM និង LCK តិចជាង រឺ ស្មើនឹង $\dfrac{1}{4}$ នៃត្រីកោណ ABC។

លំហាត់ ៣២

(កម្ពុជា, 2017)

គេឲ្យត្រីកោណ ABC ជាត្រីកោណមុំស្រួច ហើយ $[AD],[BE]$ និង $[CF]$ ជាកម្ពស់នៃត្រីកោណនេះ ។ បង្ហាញថា $DE+EF+FD \leq \dfrac{1}{2}(a+b+c)$ ។

លំហាត់ ៣៣

(កម្ពុជា, 2017)

គេមានរង្វង់មួយដែលមានផ្ចិត O និង P ជាចំណុចមួយនៅក្រៅរង្វង់ ។ PA និង PB ជាបន្ទាត់ប៉ះគូសចេញពី P ទៅប៉ះរង្វង់ផ្ចិត O ត្រង់ A និង B ។ PD ជាបន្ទាត់កាត់គូសចេញពី P ដែលកាត់រង្វង់ត្រង់ C និង D ។ BF ជាបន្ទាត់ស្របនឹង PA ហើយកាត់បន្ទាត់ AC និង AD រៀងគ្នាត្រង់ E និង F ។ ស្រាយបំភ្លឺថា $BE = BF$ ។

ជំពូក III

លំហាត់ និង ដំណោះស្រាយ

លំហាត់ ១
គេឲ្យ A,B និង C ជាមុំក្នុងត្រីកោណមួយ ។ បង្ហាញថា

1. $\sin A+\sin B+\sin C=4\cos\frac{A}{2}\cos\frac{B}{2}\cos\frac{C}{2}$
2. $\sin 2A+\sin 2B+\sin 2C=4\sin A\sin B\sin C$
3. $\sin 3A+\sin 3B+\sin 3C=-4\cos\frac{3A}{2}\cos\frac{3B}{2}\cos\frac{3C}{2}$
4. $\sin 4A+\sin 4B+\sin 4C=-4\sin 2A\sin 2B\sin 2C$
5. $\cos A+\cos B+\cos C=1+4\sin\frac{A}{2}\sin\frac{B}{2}\sin\frac{C}{2}$
6. $\cos A+\cos B+\cos C=-1-4\cos A\cos B\cos C$
7. $\cos 3A+\cos 3B+\cos 3C=1-4\sin\frac{3A}{2}\sin\frac{3B}{2}\sin\frac{3C}{2}$
8. $\tan A+\tan B+\tan C=\tan A\tan B\tan C$
9. $\tan\frac{A}{2}\tan\frac{B}{2}+\tan\frac{B}{2}\tan\frac{C}{2}+\tan\frac{C}{2}\tan\frac{A}{2}=1$
10. $\cot A\cot B+\cot B\cot C+\cot C\cot A=1$
11. $\cot\frac{A}{2}+\cot\frac{B}{2}+\cot\frac{C}{2}=\cot\frac{A}{2}\cot\frac{B}{2}\cot\frac{C}{2}$ ។

សម្រាយ
ដោយ A,B និង C ជាមុំក្នុងត្រីកោណមួយ នោះ $A+B+C=\pi$

1. យើងមាន $\sin A+\sin B+\sin C=2\sin\left(\frac{A+B}{2}\right)\cos\left(\frac{A-B}{2}\right)+2\sin\frac{C}{2}\cos\frac{C}{2}$
$$=2\sin\left(\frac{\pi-C}{2}\right)\cos\left(\frac{A-B}{2}\right)+2\sin\left[\frac{\pi-(A+B)}{2}\right]\cos\frac{C}{2}$$
$$=2\cos\frac{C}{2}\cos\left(\frac{A-B}{2}\right)+2\cos\left(\frac{A+B}{2}\right)\cos\frac{C}{2}$$
$$=2\left[\cos\left(\frac{A-B}{2}\right)+\cos\left(\frac{A+B}{2}\right)\right]\cos\frac{C}{2}$$
$$=4\cos\frac{A}{2}\cos\frac{B}{2}\cos\frac{C}{2}$$
ដូចនេះ $\sin A+\sin B+\sin C=4\cos\frac{A}{2}\cos\frac{B}{2}\cos\frac{C}{2}$

2. យើងមាន

$$\begin{aligned}\sin 2A+\sin 2B+\sin 2C &= 2\sin(A+B)\cos(A-B)+2\sin C\cos C\\ &= 2\sin(\pi-C)\cos(A-B)+2\sin C\cos[\pi-(A+B)]\\ &= 2\sin C\cos(A-B)-2\sin C\cos(A+B)\\ &= 2\sin C[\cos(A-B)-\cos(A+B)]\\ &= -4\sin C\sin A\sin(-B)\end{aligned}$$

ដូចនេះ $\sin 2A+\sin 2B+\sin 2C=4\sin A\sin B\sin C$

3. យើងមាន

$$\begin{aligned}\sin 3A+\sin 3B+\sin 3C &= 2\sin\left(\frac{3A+3B}{2}\right)\cos\left(\frac{3A-3B}{2}\right)+2\sin\frac{3C}{2}\cos\frac{3C}{2}\\ &= 2\sin\left(\frac{3\pi-3C}{2}\right)\cos\left(\frac{3A-3B}{2}\right)+2\sin\frac{3C}{2}\cos\frac{3C}{2}\\ &= -2\cos\frac{3C}{2}\cos\left(\frac{3A-3B}{2}\right)+2\sin\frac{3C}{2}\cos\frac{3C}{2}\\ &= -2\left[\cos\left(\frac{3A-3B}{2}\right)-\sin\frac{3C}{2}\right]\cos\frac{3C}{2}\\ &= -2\left[\cos\left(\frac{3A-3B}{2}\right)+\cos\left(\frac{3A+3B}{2}\right)\right]\cos\frac{3C}{2}\\ &= -4\cos\frac{3A}{2}\cos\frac{3B}{2}\cos\frac{3C}{2}\end{aligned}$$

ដូចនេះ $\sin 3A+\sin 3B+\sin 3C=-4\cos\frac{3A}{2}\cos\frac{3B}{2}\cos\frac{3C}{2}$

4. យើងមាន

$$\begin{aligned}\sin 4A+\sin 4B+\sin 4C &= 2\sin(2A+2B)\cos(2A-2B)+2\sin 2C\cos 2C\\ &= 2\sin(2\pi-2C)\cos(2A-2B)+2\sin 2C\cos 2C\\ &= -2\sin 2C\cos(2A-2B)+2\sin 2C\cos 2C\\ &= -2\sin 2C[\cos(2A-2B)-\cos 2C]\\ &= -2\sin 2C[\cos(2A-2B)-\cos(2A+2B)]\\ &= 4\sin 2C\sin 2A\sin(-2B)\end{aligned}$$

ដូចនេះ $\sin 4A+\sin 4B+\sin 4C=-4\sin 2A\sin 2B\sin 2C$

5. យើងមាន

$$\begin{aligned}\cos A+\cos B+\cos C &= 2\cos\left(\frac{A+B}{2}\right)\cos\left(\frac{A-B}{2}\right)+1-2\sin^2\frac{C}{2}\\ &= 1+2\sin\frac{C}{2}\cos\left(\frac{A-B}{2}\right)-2\sin^2\frac{C}{2}\\ &= 1+2\sin\frac{C}{2}\left[\cos\left(\frac{A-B}{2}\right)-\sin\frac{C}{2}\right]\\ &= 1+2\sin\frac{C}{2}\left[\cos\left(\frac{A-B}{2}\right)-\cos\left(\frac{A+B}{2}\right)\right]\\ &= 1-4\sin\frac{C}{2}\sin\frac{A}{2}\sin\left(\frac{-B}{2}\right)\end{aligned}$$

ដូចនេះ $\cos A+\cos B+\cos C = 1+4\sin\frac{A}{2}\sin\frac{B}{2}\sin\frac{C}{2}$

6. យើងមាន

$$\begin{aligned}\cos 2A+\cos 2B+\cos 2C &= 2\cos(A+B)\cos(A-B)+2\cos^2 C-1\\ &= -1-2\cos C\cos(A-B)+2\cos^2 C\\ &= -1-2\cos C[\cos(A-B)-\cos C]\\ &= -1-2\cos C[\cos(A-B)+\cos(A+B)]\\ &= -1-4\cos A\cos B\cos C\end{aligned}$$

ដូចនេះ $\cos 2A+\cos 2B+\cos 2C = -1-4\cos A\cos B\cos C$

7. យើងមាន

$$\begin{aligned}\cos 3A+\cos 3B+\cos 3C &= 2\cos\left(\frac{3A+3B}{2}\right)\cos\left(\frac{3A-3B}{2}\right)+1-2\sin^2\frac{3C}{2}\\ &= 2\cos\left(\frac{3\pi-3C}{2}\right)\cos\left(\frac{3A-3B}{2}\right)+1-2\sin^2\frac{3C}{2}\\ &= 1-2\sin\frac{3C}{2}\cos\left(\frac{3A-3B}{2}\right)-2\sin^2\frac{3C}{2}\\ &= 1-2\sin\frac{3C}{2}\left[\cos\left(\frac{3A-3B}{2}\right)-\cos\left(\frac{3A+3B}{2}\right)\right]\\ &= 1-4\sin\frac{3A}{2}\sin\frac{3B}{2}\sin\frac{3C}{2}\end{aligned}$$

ដូចនេះ $\cos 3A+\cos 3B+\cos 3C = 1-4\sin\frac{3A}{2}\sin\frac{3B}{2}\sin\frac{3C}{2}$

8. យើងមាន $A+B+C=\pi \Rightarrow B+C=\pi-A$
នោះ $\tan(B+C)=\tan(\pi-A)$
$\Rightarrow \dfrac{\tan B+\tan C}{1-\tan B\tan C}=-\tan A$
$\Rightarrow \tan B+\tan C=-\tan A+\tan A\tan B\tan C$
ដូចនេះ $\tan A+\tan B+\tan C=\tan A\tan B\tan C$

9. យើងមាន $\dfrac{A}{2}+\dfrac{B}{2}+\dfrac{C}{2}=\dfrac{\pi}{2}$
$\Rightarrow \dfrac{A}{2}+\dfrac{B}{2}=\dfrac{\pi}{2}-\dfrac{C}{2}$
នោះ $\tan\left(\dfrac{A}{2}+\dfrac{B}{2}\right)=\tan\left(\dfrac{\pi}{2}-\dfrac{C}{2}\right)$
$\Rightarrow \dfrac{\tan\frac{A}{2}+\tan\frac{B}{2}}{1-\tan\frac{A}{2}\tan\frac{B}{2}}=\dfrac{1}{\tan\frac{C}{2}}$
$\Rightarrow \tan\dfrac{A}{2}\tan\dfrac{C}{2}+\tan\dfrac{B}{2}\tan\dfrac{C}{2}=1-\tan\dfrac{A}{2}\tan\dfrac{B}{2}$
ដូចនេះ $\tan\dfrac{A}{2}\tan\dfrac{B}{2}+\tan\dfrac{B}{2}\tan\dfrac{C}{2}+\tan\dfrac{C}{2}\tan\dfrac{A}{2}=1$

10. ដោយ $A+B+C=\pi \Rightarrow B+C=\pi-A$
នោះ $\cot(B+C)=\cot(\pi-A)$
$\Rightarrow \dfrac{\cot B\cot C-1}{\cot B+\cot C}=-\cot A$
$\Rightarrow \cot B\cot C-1=-\cot A\cot B-\cot A\cot C$
ដូចនេះ $\cot A\cot B+\cot B\cot C+\cot C\cot A=1$

11. យើងមាន $\dfrac{A}{2}+\dfrac{B}{2}+\dfrac{C}{2}=\dfrac{\pi}{2} \Rightarrow \dfrac{A}{2}+\dfrac{B}{2}=\dfrac{\pi}{2}-\dfrac{C}{2}$
នោះ $\cot\left(\dfrac{A}{2}+\dfrac{B}{2}\right)=\cot\left(\dfrac{\pi}{2}-\dfrac{C}{2}\right)$
$\Rightarrow \dfrac{\cot\frac{A}{2}\cot\frac{B}{2}-1}{\cot\frac{A}{2}+\cot\frac{B}{2}}=\dfrac{1}{\cot\frac{C}{2}}$
$\cot\dfrac{A}{2}\cot\dfrac{B}{2}\cot\dfrac{C}{2}-\cot\dfrac{C}{2}=\cot\dfrac{A}{2}+\cot\dfrac{B}{2}$
ដូចនេះ $\cot\dfrac{A}{2}+\cot\dfrac{B}{2}+\cot\dfrac{C}{2}=\cot\dfrac{A}{2}\cot\dfrac{B}{2}\cot\dfrac{C}{2}$

លំហាត់ ២

គេឲ្យ A,B និង C ជាមុំក្នុងត្រីកោណមួយ ។ បង្ហាញថា

1. $\sin A+\sin B+\sin C\leq\dfrac{3\sqrt{3}}{2}$

2. $1 < \cos A + \cos B + \cos C \leq \frac{3}{2}$

3. $\tan A + \tan B + \tan C \geq 3\sqrt{3}$ (A, B និង C ជាមុំស្រួច)

4. $\cot A + \cot B + \cot C \geq \sqrt{3}$

5. $\sin^2 A + \sin^2 B + \sin^2 C \leq \frac{9}{2}$

6. $\cos^2 A + \cos^2 B + \cos^2 C \geq \frac{3}{4}$

7. $\tan^2 A + \tan^2 B + \tan^2 C \geq 9$ (A, B និង C ជាមុំស្រួច)

8. $1 < \sin\frac{A}{2} + \sin\frac{B}{2} + \sin\frac{C}{2} \leq \frac{3}{2}$

9. $2 < \cos\frac{A}{2} + \cos\frac{B}{2} + \cos\frac{C}{2} \leq \frac{3\sqrt{3}}{2}$

10. $\tan\frac{A}{2} + \tan\frac{B}{2} + \tan\frac{C}{2} \geq \sqrt{3}$

11. $\frac{3}{4} \leq \sin^2\frac{A}{2} + \sin^2\frac{B}{2} + \sin^2\frac{C}{2} < 1$

12. $2 < \cos^2\frac{A}{2} + \cos^2\frac{B}{2} + \cos^2\frac{C}{2} \leq \frac{9}{4}$

13. $\tan^2\frac{A}{2} + \tan^2\frac{B}{2} + \tan^2\frac{C}{2} \geq 1$

14. $\sin A \sin B \sin C \leq \frac{3\sqrt{3}}{8}$

15. $\cos A \cos B \cos C \leq \frac{1}{8}$

16. $\sin\frac{A}{2} \sin\frac{B}{2} \sin\frac{C}{2} \leq \frac{1}{8}$

17. $\cos\frac{A}{2} \cos\frac{A}{2} \cos\frac{A}{2} \leq \frac{3\sqrt{3}}{8}$

18. $\tan\frac{A}{2} \tan\frac{B}{2} \tan\frac{C}{2} \leq \frac{1}{3\sqrt{3}}$

សម្រាយ

1. Lemma:

ចំពោះ x, y និង z ផ្ទៀងផ្ទាត់ $0 < x, y, z < \pi$ គេបាន

i- $\dfrac{\sin x + \sin y}{2} \leq \sin\left(\dfrac{x+y}{2}\right)$

ii-$\dfrac{\sin x + \sin y + \sin z}{3} \leq \sin\left(\dfrac{x+y+z}{3}\right)$

សម្រាយ

i- យើងមាន $\sin x + \sin y = 2\sin\left(\dfrac{x+y}{2}\right)\cos\left(\dfrac{x-y}{2}\right)$

ដោយ $0 < x, y < \pi \Rightarrow 0 < \dfrac{x+y}{2} < \pi$ និង $0 \leq \left|\dfrac{x-y}{2}\right| < \dfrac{\pi}{2}$

$\Rightarrow \sin\left(\dfrac{x+y}{2}\right) > 0$ និង $0 < \cos\left(\dfrac{x-y}{2}\right) \leq 1$

នោះ $\dfrac{\sin x + \sin y}{2} \leq \sin\left(\dfrac{x+y}{2}\right)$

ii-យើងមាន

$$\begin{aligned}
\sin\left(\frac{x+y+z}{3}\right) &= \sin\left(\frac{\frac{4x+4y+4z}{3}}{4}\right) \\
&= \sin\left(\frac{x+y+z+\frac{x+y+z}{3}}{4}\right) \\
&= \sin\left(\frac{\frac{x+y}{2}+\frac{z+\frac{x+y+z}{3}}{2}}{2}\right) \\
&\geq \frac{1}{2}\left[\sin\left(\frac{x+y}{2}\right)+\sin\left(\frac{z+\frac{x+y+z}{3}}{2}\right)\right] \\
&\geq \frac{1}{2}\left[\frac{\sin x+\sin y}{2}+\frac{\sin z+\sin\left(\frac{x+y+z}{3}\right)}{2}\right] \\
&\geq \frac{1}{4}\left[\sin x+\sin y+\sin z+\sin\left(\frac{x+y+z}{3}\right)\right] \\
\Rightarrow 4\sin\left(\frac{x+y+z}{3}\right) &\geq \sin x+\sin y+\sin z+\sin\left(\frac{x+y+z}{3}\right) \\
\Rightarrow 3\sin\frac{x+y+z}{3} &\geq \sin x+\sin y+\sin z
\end{aligned}$$

ហេតុនេះ $\dfrac{\sin x + \sin y + \sin z}{3} \leq \sin\left(\dfrac{x+y+z}{3}\right)$

យើងបាន $\dfrac{\sin A+\sin B+\sin C}{3} \leq \sin\left(\dfrac{A+B+C}{3}\right) = \sin\dfrac{\pi}{3} = \dfrac{\sqrt{3}}{2}$

2. $1 < \cos A+\cos B+\cos C \leq \dfrac{3}{2}$
ដោយ A, B និង C ជារង្វាស់មុំនៃត្រីកោណមួយ
យើងបាន $\cos A+\cos B+\cos C \ = 1+4\sin\dfrac{A}{2}\sin\dfrac{B}{2}\sin\dfrac{C}{2}$ (1)
ហើយ $\sin\dfrac{A}{2}, \sin\dfrac{B}{2}$ និង $\sin\dfrac{C}{2} > 0$
ម៉្យាងទៀត

$$\begin{aligned}
&\cos A+\cos B+\cos C+\cos\frac{\pi}{3}\\
&= 2\cos\left(\frac{A+B}{2}\right)\cos\left(\frac{A-B}{2}\right)+2\cos\left(\frac{C}{2}+\frac{\pi}{6}\right)\cos\left(\frac{C}{2}-\frac{\pi}{6}\right)\\
&\leq 2\cos\left(\frac{A+B}{2}\right)+2\cos\left(\frac{C}{2}+\frac{\pi}{6}\right) = 2\left[\cos\left(\frac{A+B}{2}\right)+\cos\left(\frac{C}{2}+\frac{\pi}{6}\right)\right]
\end{aligned}$$

ព្រោះ $0 < \cos\left(\dfrac{A-B}{2}\right)$ និង $\cos\left(\dfrac{C}{2}-\dfrac{\pi}{6}\right) \leq 1$
យើងបាន

$$\begin{aligned}
\cos A+\cos B+\cos C+\cos\frac{\pi}{3} &\leq 4\cos\left(\frac{A+B+C+\frac{\pi}{3}}{4}\right)\cos\left(\frac{A+B-C-\frac{\pi}{3}}{4}\right)\\
&\leq 4\cos\left(\frac{\pi+\frac{\pi}{3}}{4}\right) = 4\cos\frac{\pi}{3}
\end{aligned}$$

ព្រោះ $0 < \cos\left(\dfrac{A+B-C-\frac{\pi}{3}}{4}\right) \leq 1$
យើងបាន $\cos A+\cos B+\cos C \leq 3\cos\dfrac{\pi}{3} = \dfrac{3}{2}$ (2)
តាម (1) និង (2) យើងបាន $1 < \cos A+\cos B+\cos C \leq \dfrac{3}{2}$

3. $\tan A+\tan B+\tan C \geq 3\sqrt{3}$
ដោយ A, B និង C ជាមុំស្រួច នោះ $\tan A, \tan B$ និង $\tan C > 0$
តាមវិសមភាព Cauchy យើងបាន
$\tan A+\tan B+\tan C \geq 3\sqrt[3]{\tan A\tan B\tan C}$
$\Rightarrow (\tan A+\tan B+\tan C)^3 \geq 27(\tan A+\tan B+\tan C)$
$\Rightarrow (\tan A+\tan B+\tan C)^2 \geq 27$
ដូចនេះ $\tan A+\tan B+\tan C \geq 3\sqrt{3}$

4. $\cot A+\cot B+\cot C\geq 3\sqrt{3}$
ដោយ $(x+y+z)^2\geq 3(xy+yz+zx)$
យើងបាន

$$\begin{aligned}(\cot A+\cot B+\cot C)^2 &\geq 3(\cot A\cot B+\cot B\cot C+\cot C\cot A)\\ &=3\end{aligned}$$

ព្រោះ $\cot A\cot B+\cot B\cot C+\cot C\cot A=1$
ដូចនេះ $\cot A+\cot B+\cot C\geq 3\sqrt{3}$

5. $\sin^2 A+\sin^2 B+\sin^2 C\leq \dfrac{9}{4}$
យើងមាន

$$\begin{aligned}&\sin^2 A+\sin^2 B+\sin^2 C\\ &=\frac{1-\cos 2A}{2}+\frac{1-\cos 2B}{2}+1-\cos^2 C\\ &=2-\frac{\cos 2A+\cos 2B}{2}-\cos^2 C\\ &=2-\cos(A+B)\cos(A-B)-\cos^2 C\\ &=2-\cos^2 C+\cos C\cos(A-B)\\ &=2-\cos^2 C+\cos C\cos(A-B)-\frac{1}{4}\cos^2(A-B)+\frac{1}{4}\cos^2(A-B)\\ &=-\left[\cos C-\frac{1}{2}\cos(A-B)\right]^2+\frac{1}{4}[1-\sin^2(A-B)]+2\\ &=-\left[\cos C-\frac{1}{2}\cos(A-B)\right]^2-\frac{1}{4}\sin^2(A-B)+\frac{9}{4}\end{aligned}$$

ព្រោះ $\left[\cos C-\dfrac{1}{2}\cos(A-B)\right]^2\geq 0$ និង $\sin^2(A-B)\geq 0$
ដូចនេះ $\sin^2 A+\sin^2 B+\sin^2 C\leq \dfrac{9}{4}$

6. $\cos^2 A+\cos^2 B+\cos^2 C\geq \dfrac{3}{4}$
យើងមាន $\sin^2 A+\sin^2 B+\sin^2 C\leq \dfrac{9}{4}$
ដោយ $\sin^2 x+\cos^2 x=1\Rightarrow \sin^2 x=1-\cos^2 x$
យើងបាន $1-\cos^2 A+1-\cos^2 B+1-\cos^2 C\leq \dfrac{9}{4}$

នោះ $\cos^2 A+\cos^2 B+\cos^2 C \geq \ 3-\frac{9}{4}=\frac{3}{4}$
ដូចនេះ $\cos^2 A+\cos^2 B+\cos^2 C \geq \frac{3}{4}$

7. $\tan^2 A+\tan^2 B+\tan^2 C \geq 9$
តាមវិសមភាព Cauchy យើងបាន $\tan^2 A+\tan^2 B+\tan^2 C \geq 3\sqrt[3]{(\tan A\tan B\tan C)^2}$
តាម 3 យើងមាន $\tan A\tan B\tan C \geq 3\sqrt{3}$
នោះ $\tan^2 A+\tan^2 B+\tan^2 C \geq 3\sqrt[3]{(3\sqrt{3})^2}=9$
ដូចនេះ $\tan^2 A+\tan^2 B+\tan^2 C \geq 9$

8. $1<\sin\frac{A}{2}+\sin\frac{B}{2}+\sin\frac{C}{2} \leq \frac{3}{2}$
យើងមាន $0<\cos\frac{A}{2},\cos\frac{B}{2}<1$
នោះ

$$\begin{aligned}\sin\frac{A}{2}+\sin\frac{B}{2} &> \sin\frac{A}{2}\cos\frac{B}{2}+\sin\frac{B}{2}\cos\frac{A}{2}\\ &=\sin\left(\frac{A+B}{2}\right)\\ &=\cos\frac{C}{2}\end{aligned}$$

យើងបាន

$$\begin{aligned}&\sin\frac{A}{2}+\sin\frac{B}{2}+\sin\frac{C}{2}\\ &\qquad > \sin\frac{C}{2}+\cos\frac{C}{2}\\ &\qquad =\sqrt{2}\sin\left(\frac{\pi}{4}+\frac{C}{2}\right)\\ &\qquad > \sqrt{2}\left(\frac{\sqrt{2}}{2}\right)=1\end{aligned}$$

នោះ $1<\sin\frac{A}{2}+\sin\frac{B}{2}+\sin\frac{C}{2}$ (1)

ម៉្យាងទៀត

$$\begin{aligned}
&\sin\frac{A}{2}+\sin\frac{B}{2}+\sin\frac{C}{2}+\sin\frac{\pi}{6}\\
&=2\sin\left(\frac{A+B}{4}\right)\cos\left(\frac{A-B}{4}\right)+2\sin\left(\frac{C}{4}+\frac{\pi}{12}\right)\cos\left(\frac{C}{4}-\frac{\pi}{12}\right)\\
&\le \sin\left(\frac{A+B}{4}\right)+2\sin\left(\frac{C}{4}+\frac{\pi}{12}\right)\\
&=2\left[\sin\left(\frac{A+B}{4}\right)+\sin\left(\frac{C}{4}+\frac{\pi}{12}\right)\right]\\
&=4\sin\left(\frac{A+B+C+\frac{\pi}{3}}{8}\right)\cos\left(\frac{A+B-C-\frac{\pi}{3}}{8}\right)\\
&\le 4\sin\left(\frac{\pi+\frac{\pi}{3}}{8}\right)\\
&=4\sin\frac{\pi}{6}=2
\end{aligned}$$

ព្រោះ $0<\cos\left(\frac{A-B}{4}\right),\cos\left(\frac{C}{4}-\frac{\pi}{12}\right)$ និង $\cos\left(\frac{A+B-C-\frac{\pi}{3}}{8}\right)\le 1$

យើងបាន $\sin\frac{A}{2}+\sin\frac{B}{2}+\sin\frac{C}{2}\le 2-\frac{1}{2}=\frac{3}{2} \quad (2)$

តាម (1) និង (2) យើងបាន $1<\sin\frac{A}{2}+\sin\frac{B}{2}+\sin\frac{C}{2}\le\frac{3}{2}$

9. $2<\cos\frac{A}{2}+\cos\frac{B}{2}+\cos\frac{C}{2}\le\frac{3\sqrt{3}}{2}$

យើងមាន $0<\cos\frac{A}{2}<1\Rightarrow\cos\frac{A}{2}>\cos^2\frac{A}{2}$

ដូចគ្នាដែរ $\cos\frac{B}{2}>\cos^2\frac{B}{2}$ និង $\cos\frac{C}{2}>\cos^2\frac{C}{2}$

យើងបាន

$$\begin{aligned}
\cos\frac{A}{2}+\cos\frac{B}{2}+\cos\frac{C}{2}&>\cos^2\frac{A}{2}+\cos^2\frac{B}{2}+\cos^2\frac{C}{2}\\
&=\frac{1+\cos A}{2}+\frac{1+\cos B}{2}+\frac{1+\cos C}{2}\\
&=\frac{3}{2}+\frac{1}{2}(\cos A+\cos B+\cos C)\\
&>\frac{3}{2}+\frac{1}{2}\\
&=2
\end{aligned}$$

$\Rightarrow \cos\frac{A}{2}+\cos\frac{B}{2}+\cos\frac{C}{2} > 2$ (1)

ស្រាយដូច 8 យើងបាន $\cos\frac{A}{2}+\cos\frac{B}{2}+\cos\frac{C}{2} \leq \frac{3\sqrt{3}}{2}$ (2)

តាម (1) និង (2) យើងបាន $2 < \cos\frac{A}{2}+\cos\frac{B}{2}+\cos\frac{C}{2} \leq \frac{3\sqrt{3}}{2}$

10. $\tan\frac{A}{2}+\tan\frac{B}{2}+\tan\frac{C}{2} \geq \sqrt{3}$

    យើងមាន $x^2+y^2+z^2 \geq xy+yz+zx$

    ហេតុនេះ $\tan^2\frac{A}{2}+\tan^2\frac{B}{2}+\tan^2\frac{C}{2} \geq \tan\frac{A}{2}\tan\frac{B}{2}+\tan\frac{B}{2}\tan\frac{C}{2}+\tan\frac{C}{2}\tan\frac{A}{2} = 1$

    ម៉្យាងទៀត $\left(\tan\frac{A}{2}+\tan\frac{B}{2}+\tan\frac{C}{2}\right)^2 = \tan^2\frac{A}{2}+\tan^2\frac{B}{2}+\tan^2\frac{C}{2}+2$

    $\Rightarrow \left(\tan\frac{A}{2}+\tan\frac{B}{2}+\tan\frac{C}{2}\right)^2 \geq 1+2=3$

    ដូចនេះ $\tan\frac{A}{2}+\tan\frac{B}{2}+\tan\frac{C}{2} \geq \sqrt{3}$

11. $\frac{3}{4} \leq \sin^2\frac{A}{2}+\sin^2\frac{B}{2}+\sin^2\frac{C}{2} < 1$

    យើងមាន

$$\begin{aligned}\sin^2\frac{A}{2}+\sin^2\frac{B}{2}+\sin^2\frac{C}{2} &= \frac{1-\cos A}{2}+\frac{1-\cos B}{2}+\frac{1-\cos C}{2}\\ &= \frac{3}{2}-\frac{1}{2}(\cos A+\cos B+\cos C)\end{aligned}$$

    ដោយ $1 < \cos A+\cos B+\cos C \leq \frac{3}{2}$

    យើងបាន $\frac{3}{2}-\frac{1}{2}\left(\frac{3}{2}\right) \leq \sin^2\frac{A}{2}+\sin^2\frac{B}{2}+\sin^2\frac{C}{2} < \frac{3}{2}-\frac{1}{2}$

    ដូចនេះ $\frac{3}{4} \leq \sin^2\frac{A}{2}+\sin^2\frac{B}{2}+\sin^2\frac{C}{2} < 1$

12. $2 < \cos^2\frac{A}{2}+\cos^2\frac{B}{2}+\cos^2\frac{C}{2} \leq \frac{9}{4}$

    យើងមាន

$$\begin{aligned}\cos^2\frac{A}{2}+\cos^2\frac{B}{2}+\cos^2\frac{C}{2} &= 1-\sin^2\frac{A}{2}+1-\sin^2\frac{B}{2}+1-\sin^2\frac{C}{2}\\ &= 3-\left(\sin^2\frac{A}{2}+\sin^2\frac{B}{2}+\sin^2\frac{C}{2}\right)\end{aligned}$$

ដោយ $\frac{3}{4} \leq \sin^2\frac{A}{2} + \sin^2\frac{B}{2} + \sin^2\frac{A}{C} < 1$
យើងបាន $3 - 1 < \cos^2\frac{A}{2} + \cos^2\frac{B}{2} + \cos^2\frac{C}{2} \leq \ 3 - \frac{3}{4}$
ដូចនេះ $2 < \cos^2\frac{A}{2} + \cos^2\frac{B}{2} + \cos^2\frac{C}{2} \leq \frac{9}{4}$

13. $\sin A\sin B\sin C \leq \frac{3\sqrt{3}}{8}$

តាមវិសមភាព Cauchy យើងបាន $\sin A\sin B\sin C \leq \left(\frac{\sin A + \sin B + \sin C}{3}\right)^3$
ដោយ $\sin\frac{A}{2} + \sin\frac{B}{2} + \sin\frac{C}{2} \leq \frac{3\sqrt{3}}{2}$
គេបាន $\sin A\sin B\sin C \leq \left(\frac{\frac{3\sqrt{3}}{2}}{3}\right)^3 = \frac{3\sqrt{3}}{8}$
ដូចនេះ $\sin A\sin B\sin C \leq \frac{3\sqrt{3}}{8}$

14. $\cos A\cos B\cos C \leq \frac{1}{8}$

យើងមាន

$$\begin{aligned}
\cos A\cos B\cos C &= \frac{1}{2}[\cos(A+B) + \cos(A-B)]\cos C \\
&= \frac{1}{2}[-\cos C + \cos(A-B)]\cos C \\
&= \frac{1}{2}\left[-\cos^2 C + \cos C\cos(A-B) - \frac{1}{4}\cos^2(A-B) + \frac{1}{4}\cos^2(A-B)\right] \\
&= -\frac{1}{2}\left[\cos C - \frac{1}{2}\cos(A-B)\right]^2 + \frac{1}{8}\cos^2(A-B) \\
&= -\frac{1}{2}\left[\cos C - \frac{1}{2}\cos(A-B)\right]^2 - \frac{1}{8}\sin^2(A-B) + \frac{1}{8} \leq \frac{1}{8}
\end{aligned}$$

ដូចនេះ $\cos A\cos B\cos C \leq \frac{1}{8}$

15. $\cos\frac{A}{2}\cos\frac{B}{2}\cos\frac{C}{2} \leq \frac{3\sqrt{3}}{8}$

តាមវិសមភាព Cauchy យើងបាន $\cos\frac{A}{2}\cos\frac{B}{2}\cos\frac{C}{2} \leq \left(\frac{\cos\frac{A}{2} + \cos\frac{B}{2} + \cos\frac{C}{2}}{3}\right)^3$

ដោយ $\cos\frac{A}{2}+\cos\frac{B}{2}+\cos\frac{C}{2}\leq\frac{3\sqrt{3}}{2}$

យើងបាន $\cos\frac{A}{2}\cos\frac{B}{2}\cos\frac{C}{2}\leq\left(\frac{\frac{3\sqrt{3}}{2}}{3}\right)^3=\frac{3\sqrt{3}}{8}$

ដូចនេះ $\cos\frac{A}{2}\cos\frac{B}{2}\cos\frac{C}{2}\leq\frac{3\sqrt{3}}{8}$

16. $\tan\frac{A}{2}+\tan\frac{B}{2}+\tan\frac{C}{2}\leq\frac{1}{3\sqrt{3}}$

    តាមវិសមភាព Cauchy យើងបាន $\cot\frac{A}{2}\cot\frac{B}{2}\cot\frac{C}{2}\leq\left(\frac{\cot\frac{A}{2}+\cot\frac{B}{2}+\cot\frac{C}{2}}{3}\right)^3$

    ដោយ $\cot\frac{A}{2}+\cot\frac{B}{2}+\cot\frac{C}{2}=\cot\frac{A}{2}\cot\frac{B}{2}\cot\frac{C}{2}$ (តាម លំហាត់ ១-11)

    គេបាន $\cot\frac{A}{2}\cot\frac{B}{2}\cot\frac{C}{2}\leq\frac{\left(\cot\frac{A}{2}\cot\frac{B}{2}\cot\frac{C}{2}\right)^3}{27}$

    នោះ $\left(\frac{1}{\cot\frac{A}{2}\cot\frac{B}{2}\cot\frac{C}{2}}\right)^2\leq\frac{1}{27}$

    $\Rightarrow\tan\frac{A}{2}\tan\frac{B}{2}\tan\frac{C}{2}\leq\frac{1}{3\sqrt{3}}$

លំហាត់ ៣

ក្នុងត្រីកោណ ABC មួយ ។ បង្ហាញថា

1. $(p-a)(p-b)(p-c)\leq\frac{1}{8}abc$
2. $\frac{1}{p-a}+\frac{1}{p-b}+\frac{1}{p-c}\geq 2\left(\frac{1}{a}+\frac{1}{b}+\frac{1}{c}\right)$
3. $a^2(p-b)(p-c)+b^2(p-c)(p-a)+c^2(p-a)(p-b)\geq 4S^2$
4. $p^2\geq 3\sqrt{3}S$
5. $\frac{a}{b+c-a}+\frac{b}{c+a-b}+\frac{c}{a+b-c}\geq 3$
6. $a^2(b+c-a)+b^2(c+a-b)+c^2(a+b-c)\leq 3abc$
7. $a(b^2+c^2-a^2)+b(c^2+a^2-b^2)+c(a^2+b^2-c^2)\leq 3abc$
8. $a(b-c)^2+b(c-a)^2+c(a-b)^2+4abc>a^3+b^3+c^3$
9. $a(b^2+c^2)+b(c^2+a^2)+c(a^2+b^2)\leq 2(a^3+b^3+c^3)$

10. $\dfrac{a}{b+c}+\dfrac{b}{c+a}+\dfrac{c}{a+b}+\dfrac{3abc}{(a+b)(b+c)(c+a)}<2$

11. $ab+bc+ca \le 9R^2$

12. $ab+bc+ca \ge 36r^2$

13. $\dfrac{1}{a}+\dfrac{1}{b}+\dfrac{1}{c} \ge \sqrt{\dfrac{3}{2Rr}}$

14. $\dfrac{1}{a+b-c}+\dfrac{1}{b+c-a}+\dfrac{1}{c+a-b} \ge \dfrac{3\sqrt[4]{3}}{2\sqrt{S}}$

15. $a^2+b^2+c^2 \le 2(ab+bc+ca)-4\sqrt{3}S$

16. $a^2+b^2+c^2 \ge (a-b)^2+(b-c)^2+(c-a)^2+4\sqrt{3}S$

17. $a^2+b^2+c^2 \ge \dfrac{36}{35}\left(p^2+\dfrac{abc}{p}\right)$

18. $a^4+b^4+c^4 \ge 16S^2$

19. $r \le \dfrac{R}{2}$

20. $\dfrac{1}{a}(l_a+l_b)+\dfrac{1}{b}(l_b+l_c)\dfrac{1}{c}(l_c+l_a) \le 3\sqrt{3}$

21. $l_a+l_b+l_c \le \dfrac{\sqrt{3}}{2}(a+b+c)$

22. $2\sqrt{3}l_a \le \dfrac{2(b+c)-a}{2\sqrt{3}}$

23. $m_a+m_b+m_c \le r+4R$

24. $m_a+m_b+m_c \le \dfrac{9R}{2}$

25. $m_a^2+m_b^2+m_c^2 \ge 3\sqrt{3}S$

26. $\dfrac{1}{(m_a+m_b-m_c)^2}+\dfrac{1}{(m_b+m_c-m_a)^2}+\dfrac{1}{(m_c+m_a-m_b)^2} \ge \dfrac{4}{3R^2}$

27. $\dfrac{4}{5}(m_am_b+m_bm_c+m_cm_a) < ab+bc+ca$

. $< \dfrac{20}{9}(m_am_b+m_bm_c+m_cm_a)$

28. $\frac{m_a}{h_a}+\frac{m_b}{h_b}+\frac{m_c}{h_c}\leq 1+\frac{R}{r}$

29. $\frac{h_a}{h_b}+\frac{h_b}{h_c}+\frac{h_c}{h_a}\geq\frac{h_b}{h_a}+\frac{h_c}{h_b}+\frac{h_a}{h_c}$ ករណី $A\geq B\geq C$

30. $\frac{h_a^2}{bc}+\frac{h_b^2}{ca}+\frac{h_c^2}{ab}\geq\frac{9r^2}{R^2}$

សម្រាយ

1. បង្ហាញថា $(p-a)(p-b)(p-c)\leq\frac{1}{8}abc$
   តាមវិសមភាព Cauchy យើងបាន

$$\begin{aligned}(p-a)(p-b) &\leq \left(\frac{p-a+p-b}{2}\right)^2\\ &= \left(\frac{2p-a-b}{2}\right)^2\\ &= \left(\frac{a+b+c-a-b}{2}\right)^2\\ &= \left(\frac{c}{2}\right)^2=\frac{c^2}{4}\end{aligned}$$

   ដូចគ្នាដែរ $(p-b)(p-c)\leq\frac{a^2}{4}$ និង $(p-c)(p-a)\leq\frac{b^2}{4}$
   គេបាន $[(p-a)(p-b)(p-c)]^2\leq\frac{a^2b^2c^2}{64}$
   ដូចនេះ $(p-a)(p-b)(p-c)\leq\frac{1}{8}abc$

2. បង្ហាញថា $\frac{1}{p-a}+\frac{1}{p-b}+\frac{1}{p-c}\geq 2\left(\frac{1}{b}+\frac{1}{c}+\frac{1}{c}\right)$
   តាមវិសមភាព Cauchy យើងបាន $\frac{1}{p-a}+\frac{1}{p-b}\geq\frac{2}{\sqrt{(p-a)(p-b)}}$ (i)

ដោយ

$$\begin{aligned}(p-a)(p-b) &\le \left(\frac{p-a+p-b}{2}\right)^2\\ &= \left(\frac{2p-a-b}{2}\right)^2\\ &= \left(\frac{a+b+c-a-b}{2}\right)^2\\ &= \left(\frac{c}{2}\right)^2\\ &= \frac{c^2}{4}\\ \Rightarrow \sqrt{(p-a)(p-b)} &\le \frac{c}{2} \quad (ii)\end{aligned}$$

តាម (i) និង (ii) យើងបាន $\frac{1}{p-a}+\frac{1}{p-b} \ge \frac{2}{\frac{c}{2}} = \frac{4}{c}$

ដូចគ្នាដែរ $\frac{1}{p-b}+\frac{1}{p-c} \ge \frac{4}{a}$ និង $\frac{1}{p-c}+\frac{1}{p-a} \ge \frac{4}{b}$

បូកអង្គ និង អង្គយើងបាន $2\left(\frac{1}{p-a}+\frac{1}{p-b}+\frac{1}{p-b}\right) \ge 4\left(\frac{1}{a}+\frac{1}{b}+\frac{1}{c}\right)$

ដូចនេះ $\frac{1}{p-a}+\frac{1}{p-b}+\frac{1}{p-c} \ge 2\left(\frac{1}{a}+\frac{1}{b}+\frac{1}{c}\right)$

3. $a^2(p-b)(p-c)+b^2(p-c)(p-a)+c^2(p-a)(p-b) \ge 4S^2$
តាមវិសមភាព Cauchy យើងបាន

$$\begin{aligned}\frac{a^2}{p-a}+\frac{b^2}{p-b} &\ge \frac{2ab}{\sqrt{(p-a)(p-b)}}\\ &\ge \frac{2ab}{\frac{p-a+p-b}{2}}\\ &= \frac{4ab}{2p-a-b}\end{aligned}$$

នោះ $\frac{a^2}{p-a}+\frac{b^2}{p-b} \ge \frac{4ab}{c}$

ស្រាយដូចគ្នា $\frac{b^2}{p-b}+\frac{c^2}{p-c} \ge \frac{4bc}{a}$ និង $\frac{c^2}{p-c}+\frac{a^2}{p-a} \ge \frac{4ca}{b}$

បូកអង្គ និង អង្គយើងបាន $2\left(\frac{a^2}{p-a}+\frac{b^2}{p-b}+\frac{c^2}{p-c}\right) \ge 4\left(\frac{ab}{c}+\frac{bc}{a}+\frac{ca}{b}\right)$

នោះ

$$\begin{aligned}\frac{a^2}{p-a}+\frac{b^2}{p-b}+\frac{c^2}{p-c} &\geq 2\left(\frac{ab}{c}+\frac{bc}{a}+\frac{ca}{b}\right)\\ &\geq \left(\frac{ab}{c}+\frac{bc}{a}\right)+\left(\frac{bc}{a}+\frac{ca}{b}\right)+\left(\frac{ca}{b}+\frac{ab}{c}\right)\\ &\geq 2b+2c+2a=2(a+b+c)=4p\end{aligned}$$

យើងបាន
$a^2(p-b)(p-c)+b^2(p-c)(p-a)+c^2(p-a)(p-b)\geq 4p(p-a)(p-b)(p-c)=4S^2$

ដូចនេះ វិសមភាពត្រូវបានស្រាយបញ្ជាក់

4. $p^2\geq 3\sqrt{3}S$
តាមវិសមភាព Cauchy យើងបាន

$$\begin{aligned}(p-a)(p-b)(p-c) &\leq \left(\frac{p-a+p-b+p-c}{3}\right)^3\\ &=\left(\frac{p}{3}\right)^3\\ &=\frac{p^3}{27}\end{aligned}$$

នោះ $p^3\geq 27(p-a)(p-b)(p-c)$
$\Rightarrow p^4\geq 27p(p-a)(p-b)(p-c)$
គេបាន $p^4\geq 27S^2$
ដូចនេះ $p^2\geq 3\sqrt{3}S$

5. $\dfrac{a}{b+c-a}+\dfrac{b}{c+a-b}+\dfrac{c}{a+b-c}\geq 3$
តាង $x=b+c-a,\ \ y=c+a-b$ និង $z=a+b-c\Rightarrow x,y,z>0$
នោះ $a=\dfrac{y+z}{2}, b=\dfrac{z+x}{2}$ និង $c=\dfrac{x+y}{2}$
យើងបាន

$$\begin{aligned}\frac{a}{b+c-a}+\frac{b}{c+a-b}+\frac{c}{a+b-c} &= \frac{1}{2}\left(\frac{y+z}{x}\right)+\frac{1}{2}\left(\frac{z+x}{y}\right)+\frac{1}{2}\left(\frac{x+y}{z}\right)\\ &=\frac{1}{2}\left[\left(\frac{x}{y}+\frac{y}{x}\right)+\left(\frac{y}{z}+\frac{z}{y}\right)+\left(\frac{z}{x}+\frac{x}{z}\right)\right]\\ &\geq \frac{1}{2}(2+2+2)=3\end{aligned}$$

ដូចនេះ $\frac{a}{b+c-a}+\frac{b}{c+a-b}+\frac{c}{a+b-c}\geq 3$

6. $a^2(b+c-a)+b^2(c+a-b)+c^2(a+b-c)\leq 3abc$
យើងមាន $(b-c)^2(b+c-a)\geq 0$
នោះ

$$\begin{aligned}&(b^2-2bc+c^2)(b+c-a)\geq 0\\ \Rightarrow\ &b^3+b^2c-ab^2-2b^2c-2bc^2+2abc+bc^2+c^3-ac^2\geq 0\\ \Rightarrow\ &b^3+c^3-b^2c-bc^2-ab^2-ac^2+2abc\geq 0 \quad (1)\end{aligned}$$

ស្រាយដូចគ្នា

$$\begin{aligned}&c^3+a^3-ac^2-a^2c-bc^2-a^2b+2abc\geq 0 \quad (2)\\ &a^3+b^3-ab^2-a^2b-a^2c-b^2c+2abc\geq 0 \quad (3)\end{aligned}$$

បូក (1), (2) និង (3) យើងបាន

$$\begin{aligned}&2a^3+2b^3+2c^3-2ab^2-2a^2b-2ac^2-2a^2c-2bc^2-2b^2c+6abc\geq 0\\ &a^3+b^3+c^3-ab^2-a^2b-ac^2-a^2c-bc^2-b^2c+3abc\geq 0\\ &a^2(a-b-c)+b^2(b-a-c)+c^2(c-a-b)\geq -3abc\end{aligned}$$

ដូចនេះ $a^2(b+c-a)+b^2(c+a-b)+c^2(a+b-c)\leq 3abc$

7. $a(b^2+c^2-a^2)+b(c^2+a^2-b^2)+c(a^2+b^2-c^2)\leq 3abc$
តាមទ្រឹស្តីបទកូស៊ីនុសយើងបាន $\cos A=\frac{b^2+c^2-a^2}{2bc}\Rightarrow b^2+c^2-a^2=2bc\cos A$
ដូចគ្នាដែរ $c^2+a^2-b^2=2ca\cos B$ និង $a^2+b^2-c^2=2ab\cos C$
យើងបាន

$$\begin{aligned}a(b^2+c^2-a^2)+b(c^2+a^2-b^2)+c(a^2+b^2-c^2)&=2abc\cos A+2abc\cos B+2abc\cos C\\ &=2abc(\cos A+\cos B+\cos C)\\ &\leq 2abc\left(\frac{3}{2}\right)=3abc\end{aligned}$$

ព្រោះ $\cos A+\cos B+\cos C\leq\frac{3}{2}$
ដូចនេះ $a(b^2+c^2-a^2)+b(c^2+a^2-b^2)+c(a^2+b^2-c^2)\leq 3abc$

8. $a(b-c)^2+b(c-a)^2+c(a-b)^2+4abc>a^3+b^3+c^3$
យើងមាន

$$\begin{aligned}&a(b-c)^2+b(c-a)^2+c(a-b)^2+4abc-a^3-b^3-c^3\\&=a(b^2+c^2-a^2)+b(c^2+a^2-b^2)+c(a^2+b^2-c^2)-2abc\\&=2abc\cos A+2abc\cos B+2abc\cos C-2abc\\&=2abc(\cos A+\cos B+\cos C-1)>0\end{aligned}$$

ព្រោះ $\cos A+\cos B+\cos C>1$
ដូចនេះ $a(b-c)^2+b(c-a)^2+c(a-b)^2+4abc>a^3+b^3+c^3$

9. $a(b^2+c^2)+b(c^2+a^2)+c(a^2+b^2)\leq 2(a^3+b^3+c^3)$
យើងមាន $(a-b)^2(a+b)\geq 0$
$\Rightarrow (a^2-2ab+b^2)(a+b)\geq 0$
$\Rightarrow a^3+a^2b-2a^2b-2ab^2+ab^2+b^3\geq 0$
$\Rightarrow a^3+b^3\geq a^2b+ab^2$ (1)
ដូចគ្នាដែរ $b^3+c^3\geq b^2c+bc^2$ (2)
និង $c^3+a^3\geq a^2c+ac^2$ (3)
បូក (1), (2) និង (3) យើងបាន
$2(a^3+b^3+c^3)\geq a(b^2+c^2)+b(c^2+a^2)+c(a^2+b^2)$

10. $\dfrac{a}{b+c}+\dfrac{b}{c+a}+\dfrac{c}{a+b}+\dfrac{3abc}{(a+b)(b+c)(c+a)}<2$
យើងមាន $\dfrac{a}{b+c}+\dfrac{b}{c+a}+\dfrac{c}{a+b}+\dfrac{3abc}{(a+b)(b+c)(c+a)}<2$
$\Leftrightarrow \dfrac{a}{b+c}+\dfrac{b}{c+a}+\dfrac{c}{a+b}+\dfrac{3abc}{(a+b)(b+c)(c+a)}-2<0$
$\Leftrightarrow a(a+b)(c+a)+b(a+b)(b+c)+c(b+c)(c+a)+3abc-2(a+b)(b+c)(c+a)<0$
ដោយ $a(a+b)(c+a)+b(a+b)(b+c)+c(b+c)(c+a)+3abc-2(a+b)(b+c)(c+a)$
$=a^3+b^3+c^3+a^2(b+c)+b^2(c+a)+c^2(a+b)+6abc-2a^2(b+c)-2b^2(c+a)-2c^2(a+b)-4abc$
$=a^3+b^3+c^3-a^2(b+c)-b^2(c+a)-c^2(a+b)+2abc$
$=a^2\left[a-(b+c)\right]+b^2\left[b-(c+a)\right]+c^2\left[c-(a+b)\right]+2abc$
$=a^2\left[a-(b+c)\right]+b^2\left[(b+c-a)-2c\right]+c^2\left[(b+c-a)-2b\right]+2abc$
$=-a^2(b+c-a)+b^2(b+c-a)-2b^2c+c^2(b+c-a)-2bc^2+2abc$
$=-a^2(b+c-a)+b^2(b+c-a)+c^2(b+c-a)-2bc(b+c-a)$
$=(b+c-a)[b^2+c^2-2bc-a^2]$
$=(b+c-a)[(b-c)^2-a^2]$

$= (b+c-a)(b-c-a)(a+b-c) < 0$

ដូចនេះ $\dfrac{a}{b+c}+\dfrac{b}{c+a}+\dfrac{c}{a+b}+\dfrac{3abc}{(a+b)(b+c)(c+a)} < 2$

11. $ab+bc+ca \leq 9R^2$

តាមវិសមភាព Cauchy យើងបាន

$$a^2+b^2 \geq 2ab$$
$$b^2+c^2 \geq 2bc$$
$$c^2+a^2 \geq 2ca$$

បូកអង្គ និង អង្គយើងបាន $2(a^2+b^2+c^2) \geq 2(ab+bc+ca)$

នោះ $ab+bc+ca \leq a^2+b^2+c^2$

តាមទ្រឹស្តីបទស៊ីនុស $a = 2R\sin A,\ \ b = 2R\sin B$ និង $c = 2R\sin C$

នោះ $ab+bc+ca \leq 4R^2(\sin^2 A+\sin^2 B+\sin^2 C)$

ដោយ $\sin^2 A+\sin^2 B+\sin^2 C \leq \dfrac{9}{4}$

ដូចនេះ $ab+bc+ca \leq 9R^2$

12. $ab+bc+ca \geq 36r^2$

យើងមាន $S = pr \Rightarrow r = \dfrac{S}{p}$

នោះ

$$\begin{aligned} 36r^2 &= 36\left(\frac{S}{p}\right)^2 \\ &= \frac{36p(p-a)(p-b)(p-c)}{p^2} \\ &= \frac{36(p-a)(p-b)(p-c)}{p} \end{aligned}$$

ដោយ $(p-a)(p-b)(p-c) \leq \dfrac{1}{8}abc$ (លំហាត់ ៣-1)

នោះ $36r^2 \leq \dfrac{36abc}{8p} = \dfrac{9abc}{2p}$

តាមវិសមភាព Cauchy យើងបាន $\dfrac{a+b+c}{3} \geq \sqrt[3]{abc}$ និង $\dfrac{ab+bc+ca}{3} \geq \sqrt[3]{(abc)^2}$

នោះ $abc \leq \dfrac{1}{9}(a+b+c)(ab+bc+ca) = \dfrac{2p(ab+bc+ca)}{9}$

យើងបាន $36r^2 \leq \left(\dfrac{9}{2p}\right)\left[\dfrac{2p(ab+bc+ca)}{9}\right] = ab+bc+ca$

ដូចនេះ $ab+bc+ca \geq 36r^2$

13. $\frac{1}{a}+\frac{1}{b}+\frac{1}{c}\geq\sqrt{\frac{3}{2Rr}}$

តាមវិសមភាព Cauchy យើងបាន $x^2+y^2+z^2\geq xy+yz+zx$

នោះ $(x+y+z)^2\geq 3(xy+yz+zx)$

គេបាន $(ab+bc+ca)^2\geq 3abc(a+b+c)$

នោះ $\frac{(ab+bc+ca)^2}{(abc)^2}\geq\frac{3(a+b+c)}{abc}$

នោះ $\left(\frac{1}{a}+\frac{1}{b}+\frac{1}{c}\right)^2\geq\frac{6p}{abc}$

$\Rightarrow\frac{1}{a}+\frac{1}{b}+\frac{1}{c}\geq\sqrt{\frac{6p}{abc}}$

ដោយ $S=pr=\frac{abc}{4R}\Rightarrow\frac{p}{abc}=\frac{1}{4Rr}$

យើងបាន $\frac{1}{a}+\frac{1}{b}+\frac{1}{c}\geq\sqrt{\frac{6}{4Rr}}=\sqrt{\frac{3}{2Rr}}$

14. $\frac{1}{a+b-c}+\frac{1}{b+c-a}+\frac{1}{c+a-b}\geq\frac{3\sqrt[4]{3}}{\sqrt{S}}$

តាមវិសមភាព Cauchy យើងបាន

$\left(\frac{1}{p-a}+\frac{1}{p-b}+\frac{1}{p-c}\right)[(p-a)+(p-b)+(p-c)]\geq 9$

$\left(\frac{1}{p-a}+\frac{1}{p-b}+\frac{1}{p-c}\right)p\geq 9$

$\frac{1}{p-a}+\frac{1}{p-b}+\frac{1}{p-c}\geq\frac{9}{p}$

$4\left(\frac{1}{p-a}+\frac{1}{p-b}+\frac{1}{p-c}\right)\geq 3\left(\frac{3}{p}+\frac{1}{p-a}+\frac{1}{p-b}+\frac{1}{p-c}\right)$

$\frac{1}{p-a}+\frac{1}{p-b}+\frac{1}{p-c}\geq\frac{3}{4}\left(\frac{3}{p}+\frac{1}{p-a}+\frac{1}{p-b}+\frac{1}{p-c}\right)$

ម៉្យាងទៀត $\frac{3}{p}+\frac{1}{p-a}+\frac{1}{p-b}+\frac{1}{p-c}\geq 4\sqrt[4]{\frac{3}{p(p-a)(p-b)(p-c)}}=4\sqrt[4]{\frac{3}{S^2}}=\frac{4\sqrt[4]{3}}{\sqrt{S}}$

យើងបាន $\frac{1}{p-a}+\frac{1}{p-b}+\frac{1}{p-c}\geq\frac{3}{4}\times\frac{4\sqrt[4]{3}}{\sqrt{S}}$

$\frac{1}{p-a}+\frac{1}{p-b}+\frac{1}{p-c}\geq\frac{3\sqrt[4]{3}}{\sqrt{S}}$

ដូចនេះ $\frac{1}{a+b-c}+\frac{1}{b+c-a}+\frac{1}{c+a-b}\geq\frac{3\sqrt[4]{3}}{\sqrt{S}}$

15. $a^2+b^2+c^2 \le 2(ab+bc+ca)-4\sqrt{3}S$

យើងមាន $S=\frac{1}{2}ab\sin C=\frac{1}{2}bc\sin A=\frac{1}{2}ca\sin B$

នោះ $ab=\frac{2S}{\sin C}, bc=\frac{2S}{\sin A}$ និង $ca=\frac{2S}{\sin B}$

ហើយ $a^2+b^2+c^2=4S(\cot A+\cot B+\cot C)$

យើងបាន $a^2+b^2+c^2-[2(ab+bc+ca)-4\sqrt{3}S]$

$=4S(\cot A+\cot B+\cot C)-4S\left(\frac{1}{\sin A}+\frac{1}{\sin B}+\frac{1}{\sin C}\right)+4\sqrt{3}S$

$=4S\left[\left(\cot A-\frac{1}{\sin A}\right)+\left(\cot B-\frac{1}{\sin B}\right)+\left(\cot C-\frac{1}{\sin C}\right)+\sqrt{3}\right]$

$=4S\left[\frac{\cos A-1}{\sin A}+\frac{\cos B-1}{\sin B}+\frac{\cos C-1}{\sin C}+\sqrt{3}\right]$

$=4S\left(-\tan\frac{A}{2}-\tan\frac{B}{2}-\tan\frac{C}{2}+\sqrt{3}\right)\le 0$

ព្រោះ $\tan\frac{A}{2}+\tan\frac{B}{2}+\tan\frac{C}{2}\ge\sqrt{3}$

ដូចនេះ $a^2+b^2+c^2+2(ab+bc+ca)-4\sqrt{3}S$

16. $a^2+b^2+c^2 \ge (a-b)^2+(b-c)^2+(c-a)^2+4\sqrt{3}S$

តាមលំហាត់ ៣-15 យើងមាន $a^2+b^2+c^2\le 2(ab+bc+ca)-4\sqrt{3}S$

នោះ $-a^2-b^2-c^2\ge -2(ab+bc+ca)+4\sqrt{3}S$

បូកអង្គសងខាងនឹង $2a^2+2b^2+2c^2$ យើងបាន

$a^2+b^2+c^2\ge 2a^2+2b^2+2c^2-2ab-2bc-2ca+4\sqrt{3}S$

ដូចនេះ $a^2+b^2+c^2\ge (a-b)^2+(b-c)^2+(c-a)^2+4\sqrt{3}S$

17. $a^2+b^2+c^2\ge\frac{36}{35}\left(p^2+\frac{abc}{p}\right)$

យើងមាន $a^2+b^2+c^2\ge\frac{36}{35}\left(p^2+\frac{abc}{p}\right)$

$\Leftrightarrow a^2+b^2+c^2\ge\frac{36}{35}\left[\left(\frac{a+b+c}{2}\right)^2+\frac{2abc}{a+b+c}\right]$

$\Leftrightarrow 35(a^2+b^2+c^2)\ge 9(a+b+c)^2+\frac{72abc}{a+b+c}$ (i)

ដើម្បីបង្ហាញវិសមភាពខាងលើ យើងគ្រាន់តែបង្ហាញថាវិសមភាព (i) ពិត

តាមវិសមភាព Cauchy-Schwarz យើងបាន

$9(a+b+c)^2=(3a+3b+3c)^2\le(3^2+3^2+3^2)(a^2+b^2+c^2)$

នោះ $27(a^2+b^2+c^2)\ge 9(a+b+c)^2$ (1)

ម៉្យាងទៀត តាមវិសមភាព Cauchy យើងបាន

$(a^2+b^2+c^2)(a+b+c)\ge 3\sqrt[3]{a^2b^2c^2}\times 3\sqrt[3]{abc}=9abc$

នោះ $a^2+b^2+c^2 \geq \dfrac{9abc}{a+b+c}$

$\Rightarrow 8(a^2+b^2+c^2) \geq \dfrac{72abc}{a+b+c}$ (2)

បូក (1) និង (2) យើងបាន $35(a^2+b^2+c^2) \geq 9(a+b+c)^2 + \dfrac{72abc}{a+b+c}$

ដូចនេះ $a^2+b^2+c^2 \geq \dfrac{36}{35}\left(p^2+\dfrac{abc}{p}\right)$

18. $a^4+b^4+c^4 \geq 16S^2$

តាមវិសមភាព Cauchy យើងបាន $a^4+b^4+c^4 \geq a^2b^2+b^2c^2+c^2a^2$

ដោយ $S=\dfrac{1}{2}ab\sin C=\dfrac{1}{2}bc\sin A=\dfrac{1}{2}ca\sin B$

នោះ $ab=\dfrac{2S}{\sin C},\ \ bc=\dfrac{2S}{\sin A}$ និង $ca=\dfrac{2S}{\sin B}$

យើងបាន

$$\begin{aligned} a^4+b^4+c^4 &\geq \frac{4S^2}{\sin^2 A}+\frac{4S^2}{\sin^2 B}+\frac{4S^2}{\sin^2 C} \\ &= 4S^2\left(\frac{1}{\sin^2 A}+\frac{1}{\sin^2 B}+\frac{1}{\sin^2 C}\right) \\ &\geq 4S^2\left[\frac{3}{\sqrt[3]{(\sin A\sin B\sin C)^2}}\right] \end{aligned}$$

ម្យ៉ាងទៀត $\sin A\sin B\sin C \leq \dfrac{3\sqrt{3}}{8}$

យើងបាន $a^4+b^4+c^4 \geqslant 4S^2\left[\dfrac{3}{\sqrt[3]{\left(\frac{3\sqrt{3}}{8}\right)^2}}\right]$

ដូចនេះ $a^4+b^4+c^4 \geq 16S^2$

19. $r \leq \dfrac{R}{2}$

យើងមាន $S=pr \Rightarrow r=\dfrac{S}{p}$ និង $S=\dfrac{abc}{4R} \Rightarrow\ R=\dfrac{abc}{4S}$

យើងបាន

$$\begin{aligned} \frac{r}{R}=\frac{\frac{S}{p}}{\frac{abc}{4S}}=\frac{4S^2}{pabc} &= \frac{4p(p-a)(p-b)(p-c)}{pabc} \\ &= \frac{4(p-a)(p-b)(p-c)}{abc} \end{aligned}$$

ដោយ $(p-a)(p-b)(p-c)\le \frac{1}{8}abc$ (លំហាត់ ៣-1)

នោះ $\frac{r}{R}\le \frac{4\left(\frac{1}{8}abc\right)}{abc}=\frac{1}{2}$

ដូចនេះ $r\le \frac{R}{2}$

20. $\frac{1}{a}(l_b+l_c)+\frac{1}{b}(l_c+l_a)+\frac{1}{c}(l_a+l_b)\le 3\sqrt{3}$

យើងមាន $\frac{1}{a}(l_b+l_c)+\frac{1}{b}(l_c+l_a)+\frac{1}{c}(l_a+l_b)$

$=\left(\frac{1}{b}+\frac{1}{c}\right)l_a+\left(\frac{1}{c}+\frac{1}{a}\right)l_b+\left(\frac{1}{a}+\frac{1}{b}\right)l_c$

$=\left(\frac{b+c}{bc}\right)l_a+\left(\frac{c+a}{ca}\right)l_b+\left(\frac{a+b}{ab}\right)l_c$

តាមទ្រឹស្តីបទកន្លះបន្ទាត់ពុះមុំ

$l_a=\frac{2bc}{b+c}\cos\frac{A}{2},\ \ l_b=\frac{2ca}{c+a}\cos\frac{B}{2}$ និង $l_c=\frac{2ab}{a+b}\cos\frac{C}{2}$

នោះ $\frac{1}{a}(l_b+l_c)+\frac{1}{b}(l_c+l_a)+\frac{1}{c}(l_a+l_b)$

$=\left(\frac{b+c}{bc}\right)\left(\frac{2bc}{b+c}\right)\cos\frac{A}{2}+\left(\frac{c+a}{ca}\right)\left(\frac{2ca}{c+a}\right)\cos\frac{B}{2}+\left(\frac{a+b}{ab}\right)\left(\frac{2ab}{a+b}\right)\cos\frac{C}{2}$

$=2\left(\cos\frac{A}{2}+\cos\frac{B}{2}+\cos\frac{C}{2}\right)$

ដោយ $\cos\frac{A}{2}+\cos\frac{B}{2}+\cos\frac{C}{2}\le 3\sqrt{3}$

យើងបាន $\frac{1}{a}(l_b+l_c)+\frac{1}{b}(l_c+l_a)+\frac{1}{c}(l_a+l_b)\le 3\sqrt{3}$

21. $l_a+l_b+l_c\le \frac{\sqrt{3}}{2}(a+b+c)$

យើងមាន $l_a=\frac{2bc}{b+c}\cos\frac{A}{2}$

ដោយ $\cos\frac{A}{2}=\sqrt{\frac{p(p-a)}{bc}}$

នោះ $l_a=\frac{2bc}{b+c}\sqrt{\frac{p(p-a)}{bc}}=\frac{2\sqrt{bc}\sqrt{p(p-a)}}{b+c}$

ម្យ៉ាងទៀត តាមវិសមភាព Cauchy $b+c\ge 2\sqrt{bc}\Rightarrow \frac{2\sqrt{bc}}{b+c}\le 1$

យើងបាន $l_a\le\sqrt{p(p-a)}$

ដូចគ្នាដែរ $l_b\le\sqrt{p(p-b)}$ និង $l_c\le\sqrt{p(p-c)}$

គេបាន

$$\begin{aligned} l_a+l_b+l_c &\le \sqrt{p(p-a)}+\sqrt{p(p-b)}+\sqrt{p(p-c)} \\ &= \sqrt{p}(\sqrt{p-a}+\sqrt{p-b}+\sqrt{p-c}) \end{aligned}$$

តាមវិសមភាព Cauchy-Schwarz យើងបាន

$\sqrt{p-a}+\sqrt{p-b}+\sqrt{p-c} \le \sqrt{3}\sqrt{p-a+p-b+p-c} = \sqrt{3p}$

នោះ $l_a+l_b+l_c \le \sqrt{p}(\sqrt{3p}) = p\sqrt{3} = \left(\dfrac{a+b+c}{2}\right)\sqrt{3}$

ដូចនេះ $l_a+l_b+l_c \le \dfrac{\sqrt{3}}{2}(a+b+c)$

22. $l_a \le \dfrac{2(b+c)-a}{2\sqrt{3}}$

តាមទ្រឹស្តីបទកន្លះបន្ទាត់ពុះមុំ $l_a = \dfrac{2bc}{b+c}\cos\dfrac{A}{2}$

គេបាន $l_a^2 = \dfrac{4b^2c^2}{(b+c)^2}\cos^2\dfrac{A}{2}$

ដោយ $\cos^2\dfrac{A}{2} = \dfrac{p(p-a)}{bc}$

នោះ $l_a^2 = \dfrac{4b^2c^2}{(b+c)^2}\left[\dfrac{p(p-a)}{bc}\right] = \dfrac{4bcp(p-a)}{(b+c)^2} = \dfrac{bc(a+b+c)(b+c-a)}{(b+c)^2}$

តាមវិសមភាព Cauchy យើងបាន

$bc(b+c-a) \le \left(\dfrac{b+c+b+c-a}{3}\right)^3 = \dfrac{(2b+2c-a)^3}{27}$ នោះ

$$\begin{aligned} l_a^2 &\le \frac{(a+b+c)(2b+2c-a)^3}{27(b+c)^2} \\ &= \frac{(a+b+c)(2b+2c-a)(2b+2c-a)^2}{27(b+c)^2} \end{aligned}$$

ម្យ៉ាងទៀត

$$\begin{aligned} (a+b+c)(2b+2c-a) &\le \left(\frac{a+b+c+2b+2c-a}{2}\right)^2 \\ &= \left(\frac{3b+3c}{2}\right)^2 = \frac{9(b+c)^2}{4} \end{aligned}$$

នោះ $l_a^2 \le \frac{9(b+c)^2}{4}\left[\frac{(2b+2c-a)^2}{27(b+c)^2}\right] = \frac{(2b+2c-a)^2}{4\times 3}$

$\Rightarrow l_a \le \frac{2b+2c-a}{2\sqrt{3}}$

ដូចនេះ $l_a \le \frac{2(b+c)-a}{2\sqrt{3}}$

23. $m_a+m_b+m_c \le r+4R$



យក M ជាចំនុចកណ្តាលនៃ $[BC]$ នោះ $\angle MOC = \angle A$
អនុវត្តវិសមភាពត្រីកោណចំពោះត្រីកោណ AOM យើងបាន

$$AM \le OM + OA = R\cos\angle MOC + R$$
$$\Rightarrow m_a \le R + R\cos A$$

ដូចគ្នាដែរ $m_b = R+R\cos B$ និង $m_c = R + R\cos C$
យើងបាន $m_a+m_b+m_c \le 3R + R(\cos A+\cos B+\cos C)$
ដោយ $\cos A+\cos B+\cos C = 1+\frac{r}{R}$
គេបាន $m_a+m_b+m_c \le 3R+R(1+\frac{r}{R})$
ដូចនេះ $m_a+m_b+m_c \le r+4R$

24. $m_a+m_b+m_c \le \frac{9R}{2}$

តាមវិសមភាព Cauchy-Schwarz យើងបាន

$$\begin{aligned}(m_a+m_b+m_c)^2 &\leq (1^2+1^2+1^2)(m_a^2+m_b^2+m_c^2)\\ &= 3(m_a^2+m_b^2+m_c^2)\end{aligned}$$

ដោយ

$$\begin{aligned}m_a^2+m_b^2+m_c^2 &= \frac{3}{4}(a^2+b^2+c^2)\\ &= \frac{3}{4}\left[(2R\sin A)^2+(2R\sin B)^2+(2R\sin C)^2\right]\\ &= \frac{3}{4}(4R^2\sin^2 A+4R^2\sin^2 B+4R^2\sin^2 C)\\ &= 3R^2(\sin^2 A+\sin^2 B+\sin^2 C)\end{aligned}$$

យើងបាន $(m_a+m_b+m_c)^2 \leq 9R^2(\sin^2 A+\sin^2 B+\sin^2 C)$
ម្យ៉ាងទៀត $\sin^2 A+\sin^2 B+\sin^2 C \leq \frac{9}{4}$
គេបាន $(m_a+m_b+m_c)^2 \leq 9R^2\left(\frac{9}{4}\right) = \left(\frac{9R}{2}\right)^2$
ដូចនេះ $m_a+m_b+m_c \leq \frac{9R}{2}$

25. $m_a^2+m_b^2+m_c^2 \geq 3\sqrt{3}S$
យើងមាន $a^2+b^2+c^2 = 4S(\cot A+\cot B+\cot C)$
ដោយ $\cot A+\cot B+\cot C \geq \sqrt{3}$
គេបាន $a^2+b^2+c^2 \geq 4\sqrt{3}S$
ហេតុនេះ

$$\begin{aligned}m_a^2+m_b^2+m_c^2 &= \frac{3}{4}(a^2+b^2+c^2)\\ &\geq \frac{3}{4}(4\sqrt{3}S) = 3\sqrt{3}S\end{aligned}$$

ដូចនេះ $m_a^2+m_b^2+m_c^2 \geq 3\sqrt{3}S$

26. $\frac{1}{(m_a+m_b-m_c)^2}+\frac{1}{(m_b+m_c-m_a)^2}+\frac{1}{(m_c+m_a-m_b)^2} \geq \frac{4}{3R^2}$
ដោយមេដ្យានទាំងបីនៃត្រីកោណមួយផ្គុំបានត្រីកោណមួយ
យើងបាន $(m_a+m_b-m_c)(m_b+m_c-m_a)(m_c+m_a-m_b) \leq m_am_bm_c$

ម្យ៉ាងទៀត តាមវិសមភាព Cauchy យើងបាន

$$
\begin{aligned}
&\frac{1}{(m_a+m_b-m_c)^2}+\frac{1}{(m_b+m_c-m_a)^2}+\frac{1}{(m_c+m_a-m_b)^2}\\
&\geq 3\sqrt[3]{\frac{1}{[(m_a+m_b-m_c)(m_b+m_c-m_a)(m_c+m_a-m_b)]^2}}\\
&\geq \frac{3}{\sqrt[3]{(m_am_bm_c)^2}}=\frac{3}{\sqrt[3]{m_a^2m_b^2m_c^2}}\\
&\geq \frac{3}{\frac{m_a^2+m_b^2+m_c^2}{3}}=\frac{9}{m_a^2+m_b^2+m_c^2}
\end{aligned}
$$

ដោយ

$$
\begin{aligned}
m_a^2+m_b^2+m_c^2 &= \frac{3}{4}(a^2+b^2+c^2)\\
&= 3R(\sin^2 A+\sin^2 B+\sin^2 C)\\
&\leq 3R^2\left(\frac{9}{4}\right)=\frac{27R^2}{4}
\end{aligned}
$$

ព្រោះ $\sin^2 A+\sin^2 B+\sin^2 C\leq \frac{9}{4}$

យើងបាន $\frac{1}{(m_a+m_b-m_c)^2}+\frac{1}{(m_b+m_c-m_a)^2}+\frac{1}{(m_c+m_a-m_b)^2}\geq \frac{9}{\frac{27R^2}{4}}=\frac{4}{3R^2}$

ដូចនេះ $\frac{1}{(m_a+m_b-m_c)^2}+\frac{1}{(m_b+m_c-m_a)^2}+\frac{1}{(m_c+m_a-m_b)^2}\geq \frac{4}{3R^2}$

27.

$$
\begin{aligned}
\frac{4}{5}(m_am_b+m_bm_c+m_cm_a) &< ab+bc+ca\\
&< \frac{20}{9}(m_am_b+m_bm_c+m_cm_a)
\end{aligned}
$$

Lemma:

ក្នុងត្រីកោណ ABC មួយ គេបាន $m_a<\frac{b+c}{2}$។

សម្រាយ



បន្លាយ $[AM)$ ឲ្យបាន $AM = MD$ ដូចរូប
ដោយ $BM = MC$ (M ជាចំនុចកណ្ដាលនៃ $[BC]$)
និង $\angle BMA = \angle DMC$ (មុំទល់កំពូល)
គេបាន $\triangle AMD$ ប៉ុន $\triangle DMC$
វិបាក $CD = AB = c$
តាមវិសមភាពត្រីកោណ $AD < AC + CD \Rightarrow 2m_a < b + c$
ហេតុនេះ $m_a < \dfrac{b+c}{2}$
យើងមាន $m_a < \dfrac{b+c}{2},\ \ m_b < \dfrac{c+a}{2}$ និង $m_c < \dfrac{a+b}{2}$
នោះ

$$m_a + m_b + m_c < a + b + c$$

$$\Rightarrow m_a^2 + m_b^2 + m_c^2 + 2m_am_b + 2m_bm_c + 2m_cm_a < a^2 + b^2 + c^2 + 2ab + 2bc + 2ca$$

ដោយ $m_a^2 + m_b^2 + m_c^2 = \dfrac{3}{4}(a^2 + b^2 + c^2)$
នោះ

$$\frac{3}{4}(a^2 + b^2 + c^2) + 2m_am_b + 2m_bm_c + 2m_cm_a < a^2 + b^2 + c^2 + 2ab + 2bc + 2ca$$

$$\Rightarrow 2m_am_b + 2m_bm_c + 2m_cm_a < \frac{1}{4}(a^2 + b^2 + c^2) + 2ab + 2bc + 2ca$$

ម្យ៉ាងទៀត $a > |b - c|,\ \ b > |c - a|$ និង $c > |a - b|$
នោះ $a^2 + b^2 + c^2 < 2(ab + bc + ca)$

យើងបាន

$$\begin{aligned}2m_am_b+2m_bm_c+2m_cm_a &< \frac{2(ab+bc+ca)}{4}+2ab+2bc+2ca\\ m_am_b+m_bm_c+m_cm_a &< \frac{(ab+bc+ca)}{4}+ab+bc+ca\\ &= \frac{5}{4}(ab+bc+ca)\end{aligned}$$

យើងបាន $\frac{4}{5}(m_am_b+m_bm_c+m_cm_a)<ab+bc+ca$ (i)



យក C'' ជាចំនុចកណ្តាលនៃ $[GC]$

យើងមាន $A'G=\frac{1}{3}m_a,\quad A'C''=\frac{BG}{2}=\frac{\frac{2}{3}m_b}{2}=\frac{1}{3}m_b$

និង $GC''=\frac{GC}{2}=\frac{\frac{2}{3}m_c}{2}=\frac{1}{3}m_c$

យក $[A'A'']$ជាមេដ្យាននៃត្រីកោណ $GA'C''$

នោះ A'' ជាចំនុចកណ្តាលនៃ $[GC''] \Rightarrow A''$ ជាចំនុចកណ្តាលនៃ $[CC']$

យើងបាន $[A'A'']$ ជាបាតមធ្យមនៃត្រីកោណ $CC'B$

នោះ $m'_a=A'A''=\frac{1}{2}BC'=\frac{1}{2}\left(\frac{c}{2}\right)=\frac{1}{4}c$

ដូចគ្នាដែរ $m_g=\frac{1}{4}b$ និង $m''_c=\frac{1}{4}a$

តាម (i) យើងបាន

$$\left(\frac{1}{3}m_a\right)\left(\frac{1}{3}m_b\right)+\left(\frac{1}{3}m_b\right)\left(\frac{1}{3}m_c\right)+\left(\frac{1}{3}m_c\right)\left(\frac{1}{3}m_a\right)$$
$$>\frac{4}{5}\left[\left(\frac{1}{4}a\right)\left(\frac{1}{4}b\right)+\left(\frac{1}{4}b\right)\left(\frac{1}{4}c\right)+\left(\frac{1}{4}c\right)\left(\frac{1}{4}a\right)\right]$$

នោះ $\frac{1}{9}(m_a m_b + m_b m_c + m_c m_a) > \frac{1}{20}(ab + bc + ca)$

$\Rightarrow m_a m_b + m_b m_c + m_c m_a > \frac{9}{20}(ab + bc + ca) \quad (ii)$

តាម (i) និង (ii) សំណើត្រូវបានស្រាយបញ្ជាក់។

28. $\frac{m_a}{h_a}+\frac{m_b}{h_b}+\frac{m_c}{h_c}\leq 1+\frac{R}{r}$



យើងមាន $S=\frac{1}{2}ah_a=\frac{1}{2}bh_b=\frac{1}{2}ch_c$

$\Rightarrow \frac{1}{h_a}=\frac{a}{2S},\quad \frac{1}{h_b}=\frac{b}{2S}$ និង $\frac{1}{h_c}=\frac{c}{2S}$

នោះ $\frac{1}{h_a}+\frac{1}{h_b}+\frac{1}{h_c}=\frac{a}{2S}+\frac{b}{2S}+\frac{c}{2S}=\frac{a+b+c}{2S}=\frac{2p}{2pr}=\frac{1}{r}$

$\Rightarrow \frac{R}{h_a}+\frac{R}{h_b}+\frac{R}{h_c}=\frac{R}{r}\qquad (1)$

ម្យ៉ាងទៀត

$$\frac{[BOC]}{S}+\frac{[COA]}{S}+\frac{[AOB]}{S}=\frac{d_a}{h_a}+\frac{d_b}{h_b}+\frac{d_c}{h_c}$$
$$\Rightarrow \frac{S}{S}=\frac{d_a}{h_a}+\frac{d_b}{h_b}+\frac{d_c}{h_c}$$
$$\Rightarrow \frac{d_a}{h_a}+\frac{d_b}{h_b}+\frac{d_c}{h_c}=1\qquad (2)$$

បូក (1) និង (2) យើងបាន $\frac{R+d_a}{h_a}+\frac{R+d_b}{h_b}+\frac{R+d_c}{h_c}=1+\frac{R}{r}$

តាមវិសមភាពត្រីកោណ $OA+OM\geq AM\Rightarrow R+d_a\geq m_a$

ដូចគ្នាដែរ $R+d_b\geq m_b$ និង $R+d_c\geq m_c$

នោះ $\frac{R+d_a}{h_a}+\frac{R+d_b}{h_b}+\frac{R+d_c}{h_c}\geq\frac{m_a}{h_a}+\frac{m_b}{h_b}+\frac{m_c}{h_c}$

ដូចនេះ $\frac{m_a}{h_a}+\frac{m_b}{h_b}+\frac{m_c}{h_c}\le 1+\frac{R}{r}$

សម្គាល់

តាមវិសមភាព Cauchy យើងបាន $(h_a+h_b+h_c)\left(\frac{1}{h_a}+\frac{1}{h_b}+\frac{1}{h_c}\right)\ge 9$

ដោយ $\frac{1}{h_a}+\frac{1}{h_b}+\frac{1}{h_c}=\frac{1}{r}\Rightarrow \frac{h_a+h_b+h_c}{r}\ge 9$

នោះ $h_a+h_b+h_c\ge 9r$

29. $\frac{h_a}{h_b}+\frac{h_b}{h_c}+\frac{h_c}{h_a}\ge \frac{h_b}{h_a}+\frac{h_c}{h_b}+\frac{h_a}{h_c}$

យើងមាន $S=\frac{1}{2}ah_a=\frac{1}{2}bh_b=\frac{1}{2}ch_c$

$\Rightarrow h_a=\frac{2S}{a}, h_b=\frac{2S}{b}$ និង $h_c=\frac{2S}{c}$

យើងបាន

$$\begin{aligned}
&\frac{h_a}{h_b}+\frac{h_b}{h_c}+\frac{h_c}{h_a}\ge \frac{h_b}{h_a}+\frac{h_c}{h_b}+\frac{h_a}{h_c}\\
\Leftrightarrow\ &\frac{b}{a}+\frac{c}{b}+\frac{a}{c}\ge \frac{a}{b}+\frac{b}{c}+\frac{c}{a}\\
\Leftrightarrow\ &b^2c+ac^2+a^2b\ge a^2c+ab^2+bc^2\\
\Leftrightarrow\ &b^2c-bc^2+ac^2-a^2c+a^2b-ab^2\ge 0\\
\Leftrightarrow\ &bc(b-c)-a(b^2-c^2)+a^2(b-c)\ge 0\\
\Leftrightarrow\ &(b-c)(bc-ab-ac+a^2)\ge 0\\
\Leftrightarrow\ &(b-c)[b(c-a)-a(c-a)]\ge 0\\
\Leftrightarrow\ &(b-c)(b-a)(c-a)\ge 0
\end{aligned}$$

ពិត ព្រោះ $A\ge B\ge C\Rightarrow a\ge b\ge c$

30. $\frac{h_a^2}{bc}+\frac{h_b^2}{ca}+\frac{h_c^2}{ab}\ge \frac{9r^2}{R^2}$

យើងមាន

$$S=\frac{1}{2}bc\sin A=\frac{1}{2}ah_a$$
$$\Rightarrow \frac{h_a}{bc}=\frac{\sin A}{a}=\frac{1}{2R}$$

នោះ $\frac{h_a^2}{bc}=\frac{h_a}{2R}$

ដូចគ្នាដែរ $\dfrac{h_b^2}{ca}=\dfrac{h_b}{2R}$ និង $\dfrac{h_c^2}{ab}=\dfrac{h_c}{2R}$

យើងបាន $\dfrac{h_a^2}{bc}+\dfrac{h_b^2}{ca}+\dfrac{h_c^2}{ab}=\dfrac{1}{2R}(h_a+h_b+h_c)$

ដោយ $h_a+h_b+h_c\geq 9r$

គេបាន $\dfrac{h_a^2}{bc}+\dfrac{h_b^2}{ca}+\dfrac{h_c^2}{ab}\geq\dfrac{9r}{2R}=9\left(\dfrac{r}{2R}\right)$

ម្យ៉ាងទៀត $R\geq 2r\Rightarrow 1\geq\dfrac{2r}{R}\Rightarrow\dfrac{r}{2R}\geq\dfrac{r^2}{R^2}$

ដូចនេះ $\dfrac{h_a^2}{bc}+\dfrac{h_b^2}{ca}+\dfrac{h_c^2}{ab}\geq\dfrac{9r^2}{R^2}$

លំហាត់ ៤

គេអោយត្រីកោណ ABC មួយ។ បង្ហាញថា

1. $\left(\dfrac{1}{a}+\dfrac{1}{b}\right)l_c+\left(\dfrac{1}{b}+\dfrac{1}{c}\right)l_a+\left(\dfrac{1}{c}+\dfrac{1}{a}\right)l_b=2\left(\cos\dfrac{A}{2}+\cos\dfrac{B}{2}+\cos\dfrac{C}{2}\right)$

2. $r=p\tan\dfrac{A}{2}\tan\dfrac{B}{2}\tan\dfrac{C}{2}$

3. $r=\dfrac{a\sin\frac{B}{2}\sin\frac{C}{2}}{\cos\frac{A}{2}}$

4. $\dfrac{r}{4R}=\sin\dfrac{A}{2}\sin\dfrac{B}{2}\sin\dfrac{C}{2}$

5. $R=\dfrac{p}{4\cos\frac{A}{2}\cos\frac{B}{2}\cos\frac{C}{2}}$

6. $a\cos A+b\cos B+c\cos C=\dfrac{2pr}{R}$

7. $\dfrac{r+4R}{p}=\tan\dfrac{A}{2}+\tan\dfrac{B}{2}+\tan\dfrac{C}{2}$

8. $a\cot A+b\cot B+c\cot C=2(r+R)$

សម្រាយ

1. តាមទ្រឹស្តីបទកន្លះបន្ទាត់ពុះមុំយើងបាន

$$\begin{aligned} l_a = \frac{2bc}{b+c}\cos\frac{A}{2} \Rightarrow \left(\frac{1}{b}+\frac{1}{c}\right) l_a &= \left(\frac{1}{b}+\frac{1}{c}\right)\left(\frac{2bc}{b+c}\right)\cos\frac{A}{2} \\ &= \left(\frac{b+c}{bc}\right)\left(\frac{2bc}{b+c}\cos\frac{A}{2}\right) \\ &= 2\cos\frac{A}{2} \end{aligned}$$

ស្រាយដូចគ្នាយើងបាន $\left(\frac{1}{c}+\frac{1}{a}\right) l_b = 2\cos\frac{B}{2}$ និង $\left(\frac{1}{a}+\frac{1}{b}\right) l_b = 2\cos\frac{C}{2}$ ហេតុនេះ

$$\begin{aligned} \left(\frac{1}{a}+\frac{1}{b}\right) l_c + \left(\frac{1}{b}+\frac{1}{c}\right) l_a + \left(\frac{1}{c}+\frac{1}{a}\right) l_b &= 2\cos\frac{A}{2} + 2\cos\frac{B}{2} + 2\cos\frac{C}{2} \\ &= 2\left(\cos\frac{A}{2}+\cos\frac{B}{2}+\cos\frac{C}{2}\right) \end{aligned}$$

2. យើងមាន

$$\begin{aligned} r &= (p-a)\tan\frac{A}{2} \\ r &= (p-b)\tan\frac{B}{2} \\ r &= (p-c)\tan\frac{C}{2} \end{aligned}$$

នោះ $r^3 = (p-a)(p-b)(p-c)\tan\frac{A}{2}\tan\frac{B}{2}\tan\frac{C}{2}$

ដោយ $r = \sqrt{\frac{(p-a)(p-b)(p-c)}{p}} \Rightarrow (p-a)(p-b)(p-c) = pr^2$

យើងបាន $r^3 = pr^2\tan\frac{A}{2}\tan\frac{B}{2}\tan\frac{C}{2}$

ដូចនេះ $r = p\tan\frac{A}{2}\tan\frac{B}{2}\tan\frac{C}{2}$

3. .



យើងមាន $BC = BD + DC = r\cot\dfrac{B}{2} + r\cot\dfrac{C}{2}$

$\Rightarrow a = r\left(\cot\dfrac{B}{2} + \cot\dfrac{C}{2}\right) = \dfrac{r\sin\left(\frac{B+C}{2}\right)}{\sin\frac{B}{2}\sin\frac{C}{2}} = \dfrac{r\cos\frac{A}{2}}{\sin\frac{B}{2}\sin\frac{C}{2}}$

ដូចនេះ $\quad r = \dfrac{a\sin\frac{B}{2}\sin\frac{C}{2}}{\cos\frac{A}{2}}$

4. តាម 3) យើងមាន $r = \dfrac{a\sin\frac{B}{2}\cos\frac{C}{2}}{\cos\frac{A}{2}}$ នោះ $a = \dfrac{r\cos\frac{A}{2}}{\sin\frac{B}{2}\sin\frac{C}{2}}$

ដោយ $\quad a = 2R\sin A = 4R\sin\dfrac{A}{2}\cos\dfrac{A}{2}$

នោះ $4R\sin\dfrac{A}{2}\cos\dfrac{A}{2} = \dfrac{r\cos\frac{A}{2}}{\sin\frac{B}{2}\sin\frac{C}{2}}$

ដូចនេះ $\dfrac{r}{4R} = \sin\dfrac{A}{2}\sin\dfrac{B}{2}\sin\dfrac{C}{2}$

សម្គាល់

របៀបទី២ សូមមិត្តអ្នកអានមើលលំហាត់ ៧(ក)

5. តាមទ្រឹស្តីបទស៊ីនុស

$$\begin{aligned} 2R &= \frac{a}{\sin A} = \frac{b}{\sin B} = \frac{c}{\sin C} \\ &= \frac{a+b+c}{\sin A + \sin B + \sin C} \end{aligned}$$

ដោយ $\sin A+\sin B+\sin C=4\cos\frac{A}{2}\cos\frac{B}{2}\cos\frac{C}{2}$
នោះ $2R=\dfrac{2p}{4\cos\frac{A}{2}\cos\frac{B}{2}\cos\frac{C}{2}}$
ដូចនេះ $R=\dfrac{p}{4\cos\frac{A}{2}\cos\frac{B}{2}\cos\frac{C}{2}}$

6. តាមទ្រឹស្តីបទស៊ីនុស $a=2R\sin A, b=2R\sin B$ និង $c=2R\sin C$
នោះ

$$
\begin{aligned}
a\cos A+b\cos B+c\cos C &= 2R\sin A\cos A+2R\sin B\cos B+2\sin C\cos C\\
&= R\sin 2A+R\sin 2B+R\sin 2C\\
&= R(\sin 2A+\sin 2B+\sin 2C)
\end{aligned}
$$

ដោយ $\sin 2A+\sin 2B+\sin 2C=4\sin A\sin B\sin C$
យើងបាន

$$
\begin{aligned}
a\cos A+b\cos B+c\cos C &= 4R\sin A\sin B\sin C\\
&= 4R\left(\frac{a}{2R}\right)\left(\frac{b}{2R}\right)\left(\frac{c}{2R}\right)\\
&= \frac{2}{R}\left(\frac{abc}{4R}\right)\\
&= \frac{2S}{R}\\
&= \frac{2pr}{R}
\end{aligned}
$$

ដូចនេះ $a\cos A+b\cos B+c\cos C=\dfrac{2pr}{R}$

7. តាមលំហាត់ ៤-4 យើងមាន

$$
\begin{aligned}
\frac{r}{4R} &= \sin\frac{A}{2}\sin\frac{B}{2}\sin\frac{C}{2}\\
\Rightarrow r &= 4R\sin\frac{A}{2}\sin\frac{B}{2}\sin\frac{C}{2}
\end{aligned}
$$

និង

$$
\begin{aligned}
2p=a+b+c &= 2R\sin A+2R\sin B+2R\sin C\\
&= 2R(\sin A+\sin B+\sin C)
\end{aligned}
$$

យើងបាន $p=R(\sin A+\sin B+\sin C)$
នោះ

$$\begin{aligned}\frac{r+4R}{p}&=\frac{4R\sin\frac{A}{2}\sin\frac{B}{2}\sin\frac{C}{2}+4R}{R(\sin A+\sin B+\sin C)}\\&=\frac{1+4\sin\frac{A}{2}\sin\frac{B}{2}\sin\frac{C}{2}+3}{4\cos\frac{A}{2}\cos\frac{B}{2}\cos\frac{C}{2}}\\&=\frac{\cos A+\cos B+\cos C+3}{4\cos\frac{A}{2}\cos\frac{B}{2}\cos\frac{C}{2}}\end{aligned}$$

$$\begin{aligned}&=\frac{1+\cos A+1+\cos B+1+\cos C}{4\cos\frac{A}{2}\cos\frac{B}{2}\cos\frac{C}{2}}\\&=\frac{2\cos^2\frac{A}{2}+2\cos^2\frac{B}{2}+2\cos^2\frac{C}{2}}{4\cos\frac{A}{2}\cos\frac{B}{2}\cos\frac{C}{2}}\\&=\frac{1}{2}\left(\frac{\cos\frac{A}{2}}{\cos\frac{B}{2}\cos\frac{C}{2}}+\frac{\cos\frac{B}{2}}{\cos\frac{C}{2}\cos\frac{A}{2}}+\frac{\cos\frac{C}{2}}{\cos\frac{A}{2}\cos\frac{B}{2}}\right)\\&=\frac{1}{2}\left[\frac{\cos\left(\frac{B}{2}+\frac{C}{2}\right)}{\cos\frac{B}{2}\cos\frac{C}{2}}+\frac{\cos\left(\frac{C}{2}+\frac{A}{2}\right)}{\cos\frac{C}{2}\cos\frac{A}{2}}+\frac{\cos\left(\frac{A}{2}+\frac{B}{2}\right)}{\cos\frac{A}{2}\cos\frac{B}{2}}\right]\\&=\frac{1}{2}\left(\tan\frac{B}{2}+\tan\frac{C}{2}+\tan\frac{C}{2}+\tan\frac{A}{2}+\tan\frac{A}{2}+\tan\frac{B}{2}\right)\\&=\frac{1}{2}\left(2\tan\frac{A}{2}+2\tan\frac{B}{2}+2\tan\frac{C}{2}\right)\\&=\tan\frac{A}{2}+\tan\frac{B}{2}+\tan\frac{C}{2}\end{aligned}$$

ដូចនេះ $\frac{r+4R}{p}=\tan\frac{A}{2}+\tan\frac{B}{2}+\tan\frac{C}{2}$

8. តាមទ្រឹស្តីបទស៊ីនុស
យើងបាន $a=2R\sin A,\ \ b=2R\sin B$ និង $c=2R\sin C$
នោះ

$$\begin{aligned}a\cot A+b\cot B+c\cot C&=2R\sin A\cot A+2R\sin B\cot B+2R\sin C\cot C\\&=2R(\cos A+\cos B+\cos C)\end{aligned}$$

ដោយ $\cos A+\cos B+\cos C=1+\frac{r}{R}$
យើងបាន $a\cot A+b\cot B+c\cot C=2R\left(1+\frac{r}{R}\right)=2(R+r)$

ដូចនេះ $a\cot A+b\cot B+c\cot C=2(R+r)$ ។

លំហាត់ ៥
គេឲ្យត្រីកោណ ABC មានរង្វាស់ជ្រុង $BC=a, CA=b$ និង $AB=c$។
បង្ហាញថា $\cot A+\cot B+\cot C=\dfrac{a^2+b^2+c^2}{4S}$។
សម្រាយ
បង្ហាញថា $\cot A+\cot B+\cot C=\dfrac{a^2+b^2+c^2}{4S}$
តាមទ្រឹស្តីបទកូស៊ីនុស

$$\begin{aligned} a^2 &= b^2+c^2-2bc\cos A \\ &= b^2+c^2-2bc\sin A\times\frac{\cos A}{\sin A} \end{aligned}$$

ដោយ $S=\dfrac{1}{2}bc\sin A \quad \Rightarrow bc\sin A=2S$
នោះ

$$\begin{aligned} a^2 &= b^2+c^2-2\times 2S\cot A \\ \Rightarrow a^2 &= b^2+c^2-4S\cot A \qquad (1) \end{aligned}$$

ស្រាយដូចគ្នាយើងបាន
$b^2=c^2+a^2-4S\cot B$ (2)
និង $c^2=a^2+b^2-4S\cot C$ (3)
បូក (1),(2) និង (3) យើងបាន

$$a^2+b^2+c^2=2(a^2+b^2+c^2)-4S(\cot A+\cot B+\cot C)$$
$$\Rightarrow 4S(\cot A+\cot B+\cot C)=a^2+b^2+c^2$$

ដូចនេះ $\cot A+\cot B+\cot C=\dfrac{a^2+b^2+c^2}{4S}$
លំហាត់ ៦
គេឲ្យចតុកោណប៉ោង $ABCD$ មានក្រលាផ្ទៃ S និងកន្លះបរិមាត្រស្មើនឹង 2។
បង្ហាញថា $S\le 1$ ។

សម្រាយ



បង្ហាញថា $S \leq 1$

យក $AB = a, BC = b, CD = c$ និង $DA = d$

យើងមាន $S = [ABD] + [BCD] = \frac{1}{2}ad\sin A + \frac{1}{2}bc\sin C$

ដោយ $\sin A,\ \sin C \leq 1$

នោះ $S \leq \frac{1}{2}ad + \frac{1}{2}bc$ (1)

ម្យ៉ាងទៀត $S = [ABC] + [ADC] = \frac{1}{2}ab\sin B + \frac{1}{2}cd\sin D$

នោះ $S \leq \frac{1}{2}ab + \frac{1}{2}cd$ (2)

បូក (1) និង (2) យើងបាន

$$\begin{aligned} 2S &\leq \frac{1}{2}a(b+d) + \frac{1}{2}c(b+d) \\ &= \frac{1}{2}(a+c)(b+d) \\ \Rightarrow S &\leq \frac{1}{4}(a+c)(b+d) \end{aligned}$$

តាមវិសមភាព Cauchy $(a+c)(b+d) \leq \left(\frac{a+b+c+d}{2}\right)^2 = 2^2 = 4$

នោះ $S \leq \frac{1}{4} \times 4 = 1$

ដូចនេះ $S \leq 1$

លំហាត់ ៧

យក I ជាផ្ចិតរង្វង់ចារឹកក្នុងត្រីកោណ ABC ។ R និង r ជាកាំរង្វង់ចារឹកក្រៅ និងចារឹកក្នុងនៃត្រីកោណ ABC ។ បង្ហាញថា

ក) $r=4R\sin\frac{A}{2}\sin\frac{B}{2}\sin\frac{C}{2}$

ខ) $IA\times IB\times IC=4Rr^2$ ។

សម្រាយ



បង្ហាញថា

ក) $r=4R\sin\frac{A}{2}\sin\frac{B}{2}\sin\frac{C}{2}$

យើងមាន $S=pr=\frac{abc}{4R}\quad\Rightarrow r=\frac{abc}{4Rp}=\frac{abc}{2R(a+b+c)}$

តាមទ្រឹស្តីបទស៊ីនុស $a=2R\sin A,\ \ b=2R\sin B$ និង $c=2R\sin C$

យើងបាន $r=\frac{8R^3\sin A\sin B\sin C}{4R^2(\sin A+\sin B+\sin C)}=2R\left(\frac{\sin A\sin B\sin C}{\sin A+\sin B+\sin C}\right)$

ម្យ៉ាងទៀត

$$\begin{aligned}\sin A+\sin B+\sin C &= 2\sin\left(\frac{A+B}{2}\right)\cos\left(\frac{A-B}{2}\right)+2\sin\frac{C}{2}\cos\frac{C}{2}\\ &= 2\sin\left(\frac{\pi}{2}-\frac{C}{2}\right)\cos\left(\frac{A-B}{2}\right)+2\sin\frac{C}{2}\cos\frac{C}{2}\\ &= 2\cos\frac{C}{2}\cos\left(\frac{A-B}{2}\right)+2\sin\frac{C}{2}\cos\frac{C}{2}\\ &= 2\cos\frac{C}{2}\left[\cos\left(\frac{A-B}{2}\right)+\cos\left(\frac{\pi}{2}-\frac{C}{2}\right)\right]\\ &= 4\cos\frac{C}{2}\cos\left(\frac{A-B+\pi-C}{4}\right)\cos\left(\frac{A-B-\pi+C}{4}\right)\\ &= 4\cos\frac{C}{2}\cos\frac{A}{2}\cos\frac{B}{2}\end{aligned}$$

និង

$$\begin{aligned}\sin A\sin B\sin C &= \left(2\sin\frac{A}{2}\cos\frac{A}{2}\right)\left(2\sin\frac{B}{2}\cos\frac{B}{2}\right)\left(2\sin\frac{C}{2}\cos\frac{C}{2}\right)\\ &= 8\sin\frac{A}{2}\sin\frac{B}{2}\sin\frac{C}{2}\cos\frac{A}{2}\cos\frac{B}{2}\cos\frac{C}{2}\end{aligned}$$

យើងបាន $r=2R\left(\dfrac{\sin\frac{A}{2}\cos\frac{A}{2}\sin\frac{B}{2}\cos\frac{B}{2}\sin\frac{C}{2}\cos\frac{C}{2}}{4\cos\frac{A}{2}\cos\frac{B}{2}\cos\frac{C}{2}}\right)=4R\sin\dfrac{A}{2}\sin\dfrac{B}{2}\sin\dfrac{C}{2}$

ដូចនេះ $r=4R\sin\dfrac{A}{2}\sin\dfrac{B}{2}\sin\dfrac{C}{2}$

ខ) $IA\times IB\times IC=4Rr^2$

យើងបាន $\sin\dfrac{A}{2}=\dfrac{r}{IA}$ នោះ $r=IA\sin\dfrac{A}{2}$

ដូចគ្នាដែរ $r=IB\sin\dfrac{B}{2}$ និង $r=IC\sin\dfrac{C}{2}$

នោះ $r^3=IA\times IB\times\ IC\sin\dfrac{A}{2}\sin\dfrac{B}{2}\sin\dfrac{C}{2}$

ដោយ $r=4R\sin\dfrac{A}{2}\sin\dfrac{B}{2}\sin\dfrac{C}{2}$ នោះ $\sin\dfrac{A}{2}\sin\dfrac{B}{2}\sin\dfrac{C}{2}=\dfrac{r}{4R}$

យើងបាន $\dfrac{r}{4R}\times IA\times IB\times IC=r^3$

ដូចនេះ $IA\times IB\times IC=4Rr^2$

លំហាត់ ៨

តាមចំណុចមួយនៅក្នុងត្រីកោណមួយ គេគូសបន្ទាត់ស្របទៅនឹងជ្រុងទាំងបីនៃត្រីកោណនោះ។ បន្ទាត់ ទាំងនេះចែកត្រីកោណជា ៦ ចំណែក ក្នុងនោះមានបីចំណែកជាត្រីកោណមានក្រលាផ្ទៃ

តាង ដោយ S_1, S_2 និង S_3។ គណនាក្រលាផ្ទៃនៃត្រីកោណជាអនុគមន៍នៃ S_1, S_2 និង S_3។
សម្រាយ



គូស $[DE],[GF]$ និង $[IH]$ ស្របទៅនឹងជ្រុង $[BC],[CA]$ និង $[AB]$ រៀងគ្នា
យើងបាន $AFJI, DBHJ$ និង $JGCE$ ជាប្រលេឡូក្រាម
ហើយត្រីកោណ FDJ, IJE, JHG និង ABC សុទ្ធតែជាត្រីកោណដូចគ្នា
ចំពោះត្រីកោណ FDJ និងត្រីកោណ ABC

$$\frac{S_3}{S} = \left(\frac{DJ}{BC}\right)^2 \Rightarrow \sqrt{\frac{S_3}{S}} = \frac{DJ}{BC}$$

ដូចគ្នាដែរ $\sqrt{\frac{S_2}{S}} = \frac{EJ}{BC}$ និង $\sqrt{\frac{S_1}{S}} = \frac{HG}{BC}$

យើងបាន

$$\begin{aligned} \sqrt{\frac{S_1}{S}} + \sqrt{\frac{S_2}{S}} + \sqrt{\frac{S_3}{S}} &= \frac{HG+EJ+DJ}{BC} \\ \Rightarrow \frac{\sqrt{S_1}+\sqrt{S_2}+\sqrt{S_3}}{\sqrt{S}} &= \frac{HG+GC+BH}{BC} \\ &= \frac{BC}{BC} = 1 \end{aligned}$$

$$\Rightarrow \sqrt{S} = \sqrt{S_1} + \sqrt{S_2} + \sqrt{S_3}$$

ដូចនេះ $S = (\sqrt{S_1} + \sqrt{S_2} + \sqrt{S_3})^2$

លំហាត់ ៩

គេឲ្យ $ABCD$ ជាការេមួយហើយ P ជាចំណុចមួយនៅក្នុងការេនេះដែល $\angle PAB = \angle PBA = 15^\circ$។
បង្ហាញថា PCD ជាត្រីកោណសម័ង្ស។
សម្រាយ



យក F ជាចំណោលកែងនៃ D លើ $[AP]$
និង G ជាចំណុចមួយនៅលើ $[FD]$ ដែល $\angle FAG = 60^\circ$
យើងបាន $\angle AGD = 150^\circ$
ក្នុងត្រីកោណ AGD និង APB មាន
$\angle AGD = \angle APB = 150^\circ$
$\angle ADG = \angle PAB = 15^\circ$ (មុំមានជ្រុងត្រូវគ្នាកែងរៀងគ្នា)
និង $AD = AB$ (ជ្រុងការេ $ABCD$)
នោះត្រីកោណ AGD ប៉ុនត្រីកោណ APB
វិបាក $AP = AG$
តែ $AF = \dfrac{AG}{2} \Rightarrow AF = \dfrac{AP}{2} \Rightarrow F$ ជាចំណុចកណ្ដាលនៃ $[AP]$
គេបានកម្ពស់ $[DF]$ ក្លាយជាមេដ្យាននៃត្រីកោណ ADP
នោះ ADP ជាត្រីកោណសមបាតកំពូល D
យើងបាន $PD = AD = DC$
ដូចគ្នាដែរ $PC = BC = DC$ ហេតុនេះ $PD = PC = CD$
ដូចនេះ PCD ជាត្រីកោណសម័ង្ស

លំហាត់ ១០
ត្រីកោណ ABC មានមុំទាំងបីជាមុំស្រួច។ យក $[AM],[BN]$ និង $[CL]$ ជាកម្ពស់ ហើយ H ជាអរតូសង់នៃត្រីកោណនេះ។ បង្ហាញថា

ក) $\dfrac{HM}{AM}+\dfrac{HN}{BN}+\dfrac{HL}{CL}=1$

ខ) $\dfrac{AM}{HM}+\dfrac{BN}{HN}+\dfrac{CL}{HL}\geq 9$

គ) $AM\times HM\leq\dfrac{BC^2}{4}$ ។



សម្រាយ

បង្ហាញថា

ក) $\dfrac{HM}{AM}+\dfrac{HN}{BN}+\dfrac{HL}{CL}=1$

យើងមាន $[ABC]=\dfrac{1}{2}CL\times AB$ និង $[ABH]=\dfrac{1}{2}HL\times AB$

$\Rightarrow \dfrac{[ABH]}{[ABC]}=\dfrac{HL}{CL}$

ដូចគ្នាដែរ $\dfrac{[BHC]}{[ABC]}=\dfrac{HM}{AM}$ និង $\dfrac{[CHA]}{[ABC]}=\dfrac{HN}{BN}$

យើងបាន $\dfrac{HM}{AM}+\dfrac{HN}{BN}+\dfrac{HL}{CL}=\dfrac{[ABH]}{[ABC]}+\dfrac{[BHC]}{[ABC]}+\dfrac{[CHA]}{[ABC]}=\dfrac{[ABC]}{[ABC]}=1$

ដូចនេះ $\dfrac{HM}{AM}+\dfrac{HN}{BN}+\dfrac{HL}{CL}=1$

ខ) $\frac{AM}{HM}+\frac{BN}{HN}+\frac{CL}{HL}\geq 9$

តាមវិសមភាព $AM-HM$ យើងបាន

$$\frac{\frac{AM}{HM}+\frac{BN}{HN}+\frac{CL}{HL}}{3}\geq \frac{3}{\frac{HM}{AM}+\frac{HN}{BN}+\frac{HL}{CL}}=3 \text{ ព្រោះ } \frac{HM}{AM}+\frac{HN}{BN}+\frac{HL}{CL}=1$$

ដូចនេះ $\frac{AM}{HM}+\frac{BN}{HN}+\frac{CL}{HL}\geq 9$

គ) $AM\times HM\leq \frac{BC^2}{4}$

ត្រីកោណកែង ABM និង HMC មាន

$\angle BAM=\angle HCM$ (មុំមានជ្រុងត្រូវគ្នាកែងរៀងគ្នា)

យើងបាន $\triangle ABM\sim\triangle CHM$

វិបាក $\frac{AM}{MC}=\frac{BM}{HM}\Rightarrow AM\times HM=BM\times MC$

ដោយ $BM\times MC\leq\left(\frac{BM+MC}{2}\right)^2=\frac{BC^2}{4}$

ដូចនេះ $AM\times HM\leq\frac{BC^2}{4}$

លំហាត់ ១១

គេឲ្យត្រីកោណ ABC មួយ ហើយ O ជាចំណុចមួយនៅក្នុងត្រីកោណនេះ។ បន្ទាត់ $(OA),(OB)$ និង (OC) កាត់ជ្រុង $[BC],[CA]$ និង $[AB]$ ត្រង់ P,Q និង R រៀងគ្នា។ បង្ហាញថា

ក) $\frac{OP}{AP}+\frac{OQ}{BQ}+\frac{OR}{CR}=1$

ខ) $\frac{AP}{OP}+\frac{BQ}{OQ}+\frac{CR}{OR}\geq 9$ ។



សម្រាយ

បង្ហាញថា

ក) $\dfrac{OP}{AP}+\dfrac{OQ}{BQ}+\dfrac{OR}{CR}=1$

យក $[AH]$ ជាកម្ពស់នៃត្រីកោណ ABC

និង $[OH']$ ជាកម្ពស់នៃត្រីកោណ BOC

នោះ $[AH]//[OH']$

តាមទ្រឹស្តីបទ Thales យើងបាន $\dfrac{OH'}{AH}=\dfrac{OP}{AP}$

ដោយ $\dfrac{[BOC]}{[ABC]}=\dfrac{OH'}{AH}\Rightarrow\dfrac{[BOC]}{[ABC]}=\dfrac{OP}{AP}$

ដូចគ្នាដែរយើងបាន $\dfrac{[AOC]}{[ABC]}=\dfrac{OQ}{BQ}$ និង $\dfrac{[AOB]}{[ABC]}=\dfrac{OR}{CR}$

នោះ $\dfrac{OP}{AP}+\dfrac{OQ}{BQ}+\dfrac{OR}{CR}=\dfrac{[BOC]+[AOC]+[AOB]}{[ABC]}=\dfrac{[ABC]}{[ABC]}=1$

ដូចនេះ $\dfrac{OP}{AP}+\dfrac{OQ}{BQ}+\dfrac{OR}{CR}=1$

ខ) $\dfrac{AP}{OP}+\dfrac{BQ}{OQ}+\dfrac{CR}{OR}\geq 9$

តាមវិសមភាព $AM-HM$ យើងបាន

$$\frac{\frac{AP}{OP}+\frac{BQ}{OQ}+\frac{CR}{OR}}{3}\geq\frac{3}{\frac{OP}{AP}+\frac{OQ}{BQ}+\frac{OR}{CR}}=3$$

ដូចនេះ $\frac{AP}{OP}+\frac{BQ}{OQ}+\frac{CR}{OR}\geq 9$

លំហាត់ ១២

គេឲ្យត្រីកោណ ABC មួយមានមេដ្យាន m_a, m_b និង m_c គូសចេញពីកំពូល A, B និងC រៀងគ្នា។ បង្ហាញថា $m_am_bm_c \leq \frac{27R^3}{8}$ ។

សម្រាយ

បង្ហាញថា $m_am_bm_c \leq \frac{27R^3}{8}$

តាមរូបមន្តមេដ្យាន $m_a^2=\frac{b^2+c^2}{2}-\frac{a^2}{4}$

$m_b^2=\frac{c^2+a^2}{2}-\frac{b^2}{4}$

និង $m_c^2=\frac{a^2+b^2}{2}-\frac{c^2}{4}$

យើងបាន $m_a^2+m_b^2+m_c^2=\frac{3}{4}(a^2+b^2+c^2)$

តាមទ្រឹស្តីបទស៊ីនុស $a=2R\sin A, b=2R\sin B$ និង$c=2R\sin C$

គេបាន

$$\begin{aligned} m_a^2+m_b^2+m_c^2 &= \frac{3}{4}(4R^2\sin^2 A+4R^2\sin^2 B+4R^2\sin^C) \\ &= 3R^2(\sin^2 A+\sin^2 B+\sin^2 C) \end{aligned}$$

ដោយ $\sin^2 A+\sin^2 B+\sin^2 C\leq \frac{9}{2}$

យើងបាន $m_a^2+m_b^2+m_c^2\leq 3R^2\left(\frac{9}{4}\right)$ នោះ $m_a^2+m_b^2+m_c^2\leq \frac{27R^2}{4}$ (1)

ម្យ៉ាងទៀត តាមវិសមភាព $Cauchy$ យើងបាន

$m_a^2+m_b^2+m_c^2\geq 3\sqrt[3]{(m_am_bm_c)^2}$

$\Rightarrow m_am_bm_c\leq \sqrt{\left(\frac{m_a^2+m_b^2+m_c^2}{3}\right)^3}$

តាម (1) យើងបាន $m_am_bm_c\leq \sqrt{\left(\frac{\frac{27R^2}{4}}{3}\right)^3}=\sqrt{\left(\frac{9R^2}{4}\right)^3}=\frac{27R^3}{8}$

ដូចនេះ $m_am_bm_c\leq \frac{27R^3}{8}$

លំហាត់ ១៣

គេឲ្យត្រីកោណ ABC មានមុំទាំងបីជាមុំស្រួច ។ បង្ហាញថា

ក) $h_a+h_b+h_c\geq 9r$

ខ) $\frac{1}{m_a}+\frac{1}{m_b}+\frac{1}{m_c}\geq\frac{2}{R}$ ។

សម្រាយ

បង្ហាញថា

ក) $h_a+h_b+h_c\geq 9r$

យើងមាន $S=\frac{1}{2}ah_a\Rightarrow h_a=\frac{2S}{a}$

ដូចគ្នាដែរ $h_b=\frac{2S}{b}$ និង $h_c=\frac{2S}{c}$

នោះ $h_a+h_b+h_c=\frac{2S}{a}+\frac{2S}{b}+\frac{2S}{c}=2S\left(\frac{1}{a}+\frac{1}{b}+\frac{1}{c}\right)$

ដោយ $S=pr\Rightarrow h_a+h_b+h_c=2pr\left(\frac{1}{a}+\frac{1}{b}+\frac{1}{c}\right)=r(a+b+c)\left(\frac{1}{a}+\frac{1}{b}+\frac{1}{c}\right)$

តាមវិសមភាព $AM-HM$ យើងបាន $\frac{1+b+c}{3}\geq\frac{3}{\frac{1}{a}+\frac{1}{b}+\frac{1}{c}}$

$\Rightarrow(a+b+c)\left(\frac{1}{a}+\frac{1}{b}+\frac{1}{c}\right)\geq 9$

ដូចនេះ $h_a+h_b+h_c\geq 9r$

ខ) $\frac{1}{m_a}+\frac{1}{m_b}+\frac{1}{m_c}\geq\frac{2}{R}$



ត្រីកោណ AOM មាន $AM\leq OA+OM$

នោះ $OA\geq AM-OM$

$\Rightarrow\frac{OA}{AM}\leq 1-\frac{OM}{AM}$ ដោយ $AH\geq AM\Rightarrow\frac{1}{AM}\leq\frac{1}{AH}$

នោះ $\frac{OA}{AM} \geq 1 - \frac{OM}{AH} = 1 - \frac{[BOC]}{[ABC]}$

រឺ $\frac{R}{m_a} \geq 1 - \frac{[BOC]}{[ABC]}$

ស្រាយដូចគ្នាយើងបាន $\frac{R}{m_b} = 1 - \frac{[AOC]}{[ABC]}$ និង $\frac{R}{m_c} = 1 - \frac{[AOB]}{[ABC]}$

នោះ $\frac{R}{m_a} + \frac{R}{m_b} + \frac{R}{m_c} \geq 3 - \frac{[BOC]}{[ABC]} - \frac{[AOC]}{[ABC]} - \frac{[AOB]}{[ABC]}$

$= 3 - \frac{[ABC]}{[ABC]} = 3 - 1 = 2$

ដូចនេះ $\frac{1}{m_a} + \frac{1}{m_b} + \frac{1}{m_c} \geq \frac{2}{R}$

លំហាត់ ១៤

គេឲ្យត្រីកោណមួយមានរង្វាស់ជ្រុង a, b, c ហើយ l_a, l_b, l_c ជាប្រវែងកន្លះបន្ទាត់ពុះមុំក្នុងទាំងបី នៃត្រីកោណនេះ។ បង្ហាញថា $\frac{1}{a} + \frac{1}{b} + \frac{1}{c} < \frac{1}{l_a} + \frac{1}{l_b} + \frac{1}{l_c}$ ។

សម្រាយ

បង្ហាញថា $\frac{1}{a} + \frac{1}{b} + \frac{1}{c} < \frac{1}{l_a} + \frac{1}{l_b} + \frac{1}{l_c}$

<u>របៀបទី ១</u>

តាមទ្រឹស្តីបទកន្លះបន្ទាត់ពុះមុំ

$$l_a = \frac{2bc}{b+c} \cos \frac{A}{2}$$

$$\Rightarrow \frac{1}{l_a} = \frac{1}{2} \left(\frac{b+c}{bc} \right) \frac{1}{\cos \frac{A}{2}}$$

$$= \frac{1}{2} \left(\frac{1}{b} + \frac{1}{c} \right) \frac{1}{\cos \frac{A}{2}}$$

ដោយ $0 < \cos \frac{A}{2} < 1 \Rightarrow \frac{1}{\cos \frac{A}{2}} > 1$

នោះ $\frac{1}{l_a} > \frac{1}{2} \left(\frac{1}{b} + \frac{1}{c} \right)$

ស្រាយដូចគ្នា យើងបាន $\frac{1}{l_b} > \frac{1}{2} \left(\frac{1}{c} + \frac{1}{a} \right)$ និង $\frac{1}{l_c} > \frac{1}{2} \left(\frac{1}{a} + \frac{1}{b} \right)$

ហេតុនេះ $\frac{1}{l_a} + \frac{1}{l_b} + \frac{1}{l_c} > \frac{1}{2} \left(\frac{1}{b} + \frac{1}{c} + \frac{1}{c} + \frac{1}{a} + \frac{1}{a} + \frac{1}{b} \right) = \frac{1}{a} + \frac{1}{b} + \frac{1}{c}$

ដូចនេះ $\frac{1}{a} + \frac{1}{b} + \frac{1}{c} < \frac{1}{l_a} + \frac{1}{l_b} + \frac{1}{l_c}$

<u>របៀបទី ២</u>



យក $[AD)$ ជាកន្លះបន្ទាត់ពុះមុំនៃ$\angle A$
និង E ជាចំណុចមួយនៅលើ $(AC]$ ដែល $[BE]//[AD]$
យើងបាន $\angle AEB = \angle DAC$ (មុំត្រូវគ្នា)
